**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# សុំកូន

ស្រាវជ្រាវចាប់ពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ឡា សុទ្ធានាថ**

សាស្ត្រាចារ្យណែនាំ

លោក **ហ៊ីង គឹមឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ឡា សុទ្ធានាថ** ជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៨-២០១៩។

នាងខ្ញុំសូមអនុញ្ញាតសម្តែងនូវការគោរពដឹងគុណដោយស្មោះត្រង់អស់ពីដួងចិត្តចំពោះ **លោកឪពុក ទេព គីឡា** និង **អ្នកម្តាយ អ៊ុន សុម៉ាលី** ដែលជាអ្នកមានគុណធ្ងន់លើសអ្វីៗ លោកទាំងពីរជាអ្នកផ្តល់កំនើត និងចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុងដល់នាងខ្ញុំចាប់តាំងពីចាប់កំនើតរហូតដល់ធំដឹងក្តី ពោរពេញទៅដោយការស្រលាញ់ ភាពកក់ក្តៅ ការអនុគ្រោះគ្រប់សព្វបែបយ៉ាង។ លើសពីនេះ លោកទាំងពីរ តែងតែខិតខំយកចិត្តទុកដាក់ លះបង់ទាំងកំលាំងកាយកំលាំងចិត្ត ពុះពារជំនះគ្រប់ឧបសគ្គ ដើម្បីបញ្ជូនកូនទៅសាលារៀនចាប់តាំងពីបឋមសិក្សា រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាតប័ត្រប្រកបដោយជោគជ័យ ដោយឥតមានការរារែកចិត្ត ដើម្បីអោយកូនទទួលបាននូវចំនេះដឹង ជាផ្លូវឆ្ពោះទៅរកអនាគតល្អនៅថ្ងៃក្រោយ។ រាល់ដំបូន្មានល្អៗ ការប្រៀនប្រដៅរបស់អ្នកមានគុណកន្លងមក កូនតែងតែចងចាំជានិច្ច។

នាងខ្ញុំក៏សូមថ្លែងអំណរអរគុណ យ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងបុគ្គលគ្រប់ជាន់ថ្នាក់ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្ហាញផ្តល់នូវចំនេះដឹងតាំងពីឆ្នាំទីមួយ រហូតដល់ទទួលបានជោគជ័យក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រនេះ។ ជាពិសេសសាស្ត្រាចារ្យ ហ៊ីង គឹមឡេង ដែលបានបង្ហាត់បង្រៀន ព្រមទាំងណែនាំដោយផ្តល់ដំបូន្មានល្អៗដល់នាងខ្ញុំក្នុងការសរសេរសារណានេះ ចាប់តាំងពីចាប់ផ្តើមរហូតដល់សម្រេចជាលទ្ធផល លោកបានលះបង់នូវពេលវេលាដ៏មានតម្លៃរបស់លោកមកជួយកែសម្រួលរាល់កំហុសខុសឆ្គងនានារបស់នាងខ្ញុំអោយកាន់តែល្អ និងមានភាពប្រសើរឡើង។

ជាចុងបញ្ចប់ នាងខ្ញុំសូមបួងសួង និង ប្រសិទ្ធិពរជ័យដល់លោកអ្នកមានគុណទាំងទ្វេ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងបុគ្គលគ្រប់ជាន់ថ្នាក់ទាំងអស់អោយជួបប្រទះពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីអាកខានឡើយ។

# អារម្ភកថា

តាមរយៈការសិក្សាថ្នាក់បរិញ្ញាបត្រក្នុងផ្នែកនីតិសាស្រ្តអស់រយៈពេលបួនឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចរួចមក នាងខ្ញុំបានទទួលនូវចំនេះដឹងផ្នែកច្បាប់ដែលមនុស្សគ្រប់គ្នា គួរមានការយល់ដឹងអោយកាន់តែស៊ីជម្រៅ។ ក្នុងចំណោមមុខវិជ្ជាដែលបានសិក្សាកន្លងមក នាងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើវិស័យរដ្ឋប្បវេណី ដូច្នេះនាងខ្ញុំក៏បានសម្រេចចិត្ត និងមានការណែនាំពីសាស្រ្តាចារ្យជាអ្នកជួយសម្របសម្រួល ក៏បានរៀបចំសារណាមួយនេះឡើង ដែលនិយាយពីប្រធានបទ ស៊ុំកូន នេះឡើង។

សារណានេះបានបង្ហាញពីនីតិវិធី និងដំណើរការនៃការស៊ុំកូនទាំងអស់នៅក្នុងប្រទេស និងស៊ុំកូនអន្តរប្រទេស ដែលផ្តោតសំខាន់ទៅលើឧត្តមប្រយោជន៍នៃទារក និងកុមារ ជាពិសេសកុមារដែលត្រូវការការការពារជាពិសេសពីមជ្ឍដ្ឋានជុំវិញខ្លួនរបស់ពួកគេ ដើម្បីទទួលបាននូវអនាគតភ្លឺស្វាង ដែលជាកត្តាជំរុញនូវការអភិវឌ្ឍន៍ប្រទេសជាតិទាំងមូល។ នាងខ្ញុំសង្ឃឹមថា ការតាក់តែងនូវស្នាដៃមួយនេះឡើងអាចផ្តល់នូវគំនិតបំពេញបន្ថែមអោយកាន់តែល្អប្រសើរទៅលើបញ្ហាស៊ុំកូន និងចំណេះដឹងជាមូលដ្ឋានសម្រាប់ប្រជាជនទាំងមូលផងដែរ។

ជាចុងបញ្ចប់ នាងខ្ញុំសូមអភ័យទោសទុកជាមុន ចំពោះរាល់កំហុសឆ្គងកើតឡើងដោយអចេតនាមិនអាចជៀសវាងបាន ដោយប្រការណាមួយ ដែលត្រូវការជាចាំបាច់នូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ សាស្រ្តាចារ្យ រៀមច្បង និងប្រិយមិត្តអ្នកអានទាំងអស់ ដើម្បីអោយស្នាដៃនេះកាន់តែមានភាពល្អប្រសើរឡើងទៀត។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ស្មុំកូនពេញលេញ**

**ផ្នែកទី១ ៖ សញ្ញាណទូទៅនៃស្មុំកូនពេញលេញ** ........ ៣

១.១. និយមន័យ ........ ៣

១.២. គោលបំនងនៃការបង្កើតស្មុំកូនពេញលេញ ........ ៣

**ផ្នែកទី២ ៖ លក្ខខណ្ឌនៃការបង្កើតស្មុំកូនពេញលេញ** ........ ៣

២.១. លក្ខខណ្ឌចំពោះឪពុកម្តាយចិញ្ចឹម ........ ៤

២.២. លក្ខខណ្ឌចំពោះកូនស្មុំពេញលេញ ........ ៤

២.៣. លក្ខខណ្ឌផ្សេងៗ ........ ៥

**ផ្នែកទី៣ ៖ អានុភាពនៃស្មុំកូនពេញលេញ** ........ ៦

៣.១. ការកាត់ផ្តាច់ទំនាក់ទំនងញាតិ ........ ៦

៣.២. ការបង្កើតទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម ........ ៦

**ផ្នែកទី៤ ៖ ការកាត់កាល់ស្មុំកូនពេញលេញ** ........ ៧

៤.១. មូលហេតុនៃការកាត់កាល់ ........ ៧

៤.២. លក្ខខណ្ឌនៃការកាត់កាល់ ........ ៨

៤.៣. អានុភាពនៃការកាត់កាល់ស្មុំកូនពេញលេញ ........ ៨

**ជំពូកទី២**

**ស្មុំកូនធម្មតា**

**ផ្នែកទី១ ៖ សញ្ញាណទូទៅនៃស្មុំកូនធម្មតា** ........ ១០

១.១. និយមន័យ ........ ១០

១.២. លក្ខណៈពិសេសនៃស្មុំកូនធម្មតា ........ ១០

**ផ្នែកទី២ ៖ លក្ខខណ្ឌនៃការបង្កើតសុំកូនធម្មតា** ........ ១០
២.១. អាយុនិងស្ថានភាពរបស់ឪពុកម្ដាយចិញ្ចឹម ........ ១១
២.២. អាយុនិងស្ថានភាពរបស់កូនសុំ ........ ១១
២.៣. មូលដ្ឋានវិនិច្ឆ័យដែលតុលាការនឹងពិចារណា ........ ១២
**ផ្នែកទី៣ ៖ អានុភាពនៃសុំកូនធម្មតា** ........ ១២
៣.១. ការបង្កើតញាតិភាពជាមួយឪពុកម្ដាយចិញ្ចឹម ........ ១២
៣.២. ការបន្តញាតិភាពជាមួយឪពុកម្ដាយបង្កើត ........ ១៣
**ផ្នែកទី៤ ៖ ការកាត់កាល់សុំកូនធម្មតា** ........ ១៣
៤.១. មូលហេតុនិងការវិនិច្ឆ័យនៃការកាត់កាល់សុំកូនធម្មតា ........ ១៣
៤.២. ពាក្យសុំអោយកាត់កាល់សុំកូនធម្មតា ........ ១៣
៤.៣. លក្ខខណ្ឌនៃការកាត់កាល់សុំកូនធម្មតា ........ ១៤
៤.៤. អានុភាពនៃការកាត់កាល់សុំកូនធម្មតា ........ ១៤
**ជំពូកទី៣**
**សុំកូនអន្តរប្រទេស**
**ផ្នែកទី១ ៖ សញ្ញាណទូទៅនៃការសុំកូនអន្តរប្រទេស** ........ ១៥
១.១. និយមន័យ ........ ១៥
១.២. គោលបំនងនៃការសុំកូនអន្តរប្រទេស ........ ១៥
១.៣. គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស ........ ១៥
**ផ្នែកទី២ ៖ លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស** ........ ១៧
២.១. អំពីកូនសុំ ........ ១៧
២.២. អំពីឪពុកម្ដាយបង្កើត ឬអាណាព្យាបាល ........ ១៨
២.៣. អំពីអ្នកសុំ ........ ២០
**ផ្នែកទី៣ ៖ អាជ្ញាធរមានសមត្ថកិច្ចក្នុងកិច្ចការសុំកូនអន្តរប្រទេស** ........ ២១
៣.១. អាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេស ........ ២១
៣.២ . រដ្ឋបាលសុំកូនអន្តរប្រទេស ........ ២៣

៣.៣. ភ្នាក់ងារសុំកូនអន្តរប្រទេស ........................................................................ ២៥
៣.៤. អាជ្ញាធរផ្តល់ការអនុញ្ញាតអោយទីភ្នាក់ងារសុំកូនអន្តរប្រទេស ..................... ២៦
**ផ្នែកទី៤៖ នីតិវិធីសុំកូនអន្តរប្រទេស**.............................................................. ២៧
៤.១. នីតិវិធីរដ្ឋបាលនៃការសុំកូនអន្តរប្រទេស...................................................... ២៧
៤.២. សោហ៊ុយលើការសុំកូន.................................................................................... ៣២
៤.៣. នីតិវិធីតុលាការ.............................................................................................. ៣២
៤.៤ ចំណាត់ការក្រោយពីបញ្ចប់នីតិវិធីសុំកូនអន្តរប្រទេស.................................... ៣៤
៤.៥ ការទុកដាក់សំណុំឯកសារសុំកូន........................................................................ ៣៥
៤.៦. ការអនុញ្ញាតអោយកូនសុំមើលលិខិតសុំកូន ................................................. ៣៦
៤.៧. ទណ្ឌកម្ម.......................................................................................................... ៣៦
**ផ្នែកទី៥ ៖ គុណប្រយោជន៍នៃការសុំកូនអន្តរប្រទេស** ....................................... ៣៩
**សេចក្តីសន្និដ្ឋាន**............................................................................................... ៤០
**អនុសាសន៍**......................................................................................................... ៤២
**ឯកសារយោង**...................................................................................................... ៤៣
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

កុមារ គឺជាសសរទ្រូងដ៏រឹងមាំនៃអនាគតប្រទេសជាតិ ហើយកុមារក៏ជាធនធានមនុស្សដែលមិនអាចខ្វះបានសម្រាប់ជាផ្នែកមួយក្នុងការអភិវឌ្ឍប្រទេសជាតិនាពេលអនាគត ។ បន្ថែមពីនេះទៅទៀត ប្រសិនបើធនធានមនុស្សប្រកបទៅដោយសក្តានុពលច្បាស់លាស់នោះនឹងធ្វើអោយប្រទេសជាតិមានលទ្ធផលល្អជាទីគាប់ប្រសើរនៅពេលអនាគត។ ដោយឡែក កុមារក៏ត្រូវការការការពារមើលថែយ៉ាងពិសេសពីសមាជិកក្រុមគ្រួសារ ក៏ដូចជាមនុស្សដែលនៅជុំវិញខ្លួនរបស់ពួកគេ ដោយរស់នៅក្នុងមជ្ឍដ្ឋានសមស្របដែលមានការអភិវឌ្ឍន៍ពេញលេញសំរាប់ជីវិតរបស់ពួកគេ។ ក៏ប៉ុន្តែក៏មានកុមារមួយចំនួនដែលកំពុងខ្វះភាពជាគ្រួសារមួយដ៏ពេញលេញ ខ្វះភាពកក់ក្តៅ ការមើលថែទាំពីសមាជិកក្រុមគ្រួសារ ចំនែកឯគ្រួសារមួយចំនួនទៀត ក៏ប្រាថ្នាចង់មានកូនរស់នៅជាមួយពួកគេដើម្បីមកបំពេញអោយគ្រប់លក្ខណៈជាគ្រួសារដ៏មានសុភមង្គលផងដែរ ដូច្នេះយើងសង្កេតឃើញថាគ្រួសារដែលមិនមានកូនមួយចំនួន តែងតែសុំកូនពីគ្រួសារដទៃមកធ្វើជាកូនរបស់ខ្លួន ដោយតាមបែបបទផ្សេងៗគ្នា ដូចជាមានតាមច្បាប់នៅក្នុងប្រទេស តាមទម្រង់បែបបទត្រឹមត្រូវដែលច្បាប់បានកំណត់ ខ្លះទៀតក៏ពុំបានត្រឹមត្រូវតាមច្បាប់ រីឯខ្លះទៀតក៏ទៅតាមប្រពៃណីទំនៀមទំលាប់តពីបុរាណកាលមក ។ ដោយហេតុនេះ នាងខ្ញុំសុំលើកយកប្រធានបទ ≪ សុំកូន ≫ មកធ្វើការសិក្សាស្រាវជ្រាវនៅក្នុងសារណាមួយនេះ។

សុំកូន គឺជាកិច្ចការយ៉ាងពិសេសមួយ ដែលពាក់ព័ន្ធទៅនឹងកុមារ ដែលមានឪពុកម្តាយដែលមានជីវភាពក្រីក្រលំបាកក្នុងជីវភាពប្រចាំថ្ងៃ ឬ កុមារកំព្រាឪពុកម្តាយ ខ្វះភាពកក់ក្តៅពីមនុស្សទាំងពួង ហើយដើម្បីផ្តល់សុខុមាលភាព និងសុភមង្គលទៅលើកុមារទាំងអស់នោះផងដែរ ។ ដោយប្រទេសកម្ពុជាមានបទដ្ឋានគតិយុត្តិជាតិ និងអន្តរជាតិជាច្រើន សម្រាប់គ្រប់គ្រងលើវិស័យមួយនេះ។ ដោយសុំកូនបានកំនត់នូវចំនុចសំខាន់ៗមួយចំនួនដូចជាលក្ខខណ្ឌនៃការបង្កើតដែលឈានទៅរកអានុភាពនៃការសុំហើយក៏អាចឈានទៅរកការបញ្ចប់នៃសុំកូនផងដែរ គឺ នៅត្រង់ចំនុចនៃការកាត់កាល់សុំកូន។

លើសពីនេះទៅទៀត សុំកូនគឺមានគោលបំនងក្នុងការធានាអោយបាននូវការការពារសិទ្ធិជាមូលដ្ឋាន ជាពិសេសកុមារដែលស្ថិតនៅក្នុងគ្រួសារដែលមានជីវភាពក្រីក្រ ឬកុមារដែលកំព្រាខ្វះភាពកក់ក្តៅពីគ្រួសារ ព្រោះកុមារពិតជាត្រូវការការការពារនេះ ដើម្បីទទួលបាននូវការស្រលាញ់ថែទាំយកចិត្តទុកដាក់យ៉ាងពិសេសពីក្រុមគ្រួសារ ឬមនុស្សដែលនៅជុំវិញខ្លួនរបស់ពួកគេ ដើម្បីទទួលបាននូវមជ្ឈដ្ឋានមួយដែលសមស្របដូចកុមារដទៃទៀត និងអភិវឌ្ឍខ្លួនអោយមានអនាគតភ្លឺស្វាងដើម្បីចូលរួមជាចំនែកមួយនៅក្នុងការអភិវឌ្ឍប្រទេស ក៏ដូចជាប្រយោជន៍សំរាប់ក្រុមគ្រួសារ

និងខ្លួនឯងផងដែរ។ជាពិសេសគឺ ដើម្បីការពារកុមារអោយរួចផុតពីការរំលោភបំពានផ្សេងៗ ដូចជាការជួញដូរកុមារខុសច្បាប់ និងការកេងប្រវ័ញ្ចកំលាំងពលកម្មពីកុមារជាដើម។

ការស្រាវជ្រាវនេះ មានគោលបំនងបង្ហាញអោយឃើញពីគោលការណ៍មនុស្សធម៌ ដោយមានការការពារពីច្បាប់គតិយុត្តិជាមូលដ្ឋានចំបងផ្សាភ្ជាប់ទៅនឹងការយកចិត្តទុកដាក់ដល់កុមារទាំងពួងដែលកំពុងត្រូវការការយកចិត្តទុកដាក់ ផ្តល់នូវការស្រលាញ់ដែលមិនចេះរីងស្ងួត ផ្តល់នូវការអប់រំរៀនសូត្រ ព្រមទាំងសេវាថៃទាំសុខភាពទាំងផ្លូវកាយនិងផ្លូវចិត្ត ជាពិសេសគឺផ្អែកទៅលើសិទ្ធិជាមូលដ្ឋានរបស់កុមារតែម្តង។

ដោយសារណាមួយនេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះវិស័យសុំកូននៅកម្ពុជាពីព្រោះក្នុងសារណាមួយក្បាលនេះបានបង្ហាញដំណើរការនៃនីតិវិធីទាំងស្រុងនៃការសុំកូននៅកម្ពុជា ជាពិសេសសុំកូនអន្តរប្រទេសដែលមានភាពតឹងរឹង និងស្មុគស្មាញជាងគេ ហើយសុទ្ធតែជាប់ពាក់ព័ន្ធទៅនឹងអាជ្ញាធរមានសមត្ថកិច្ច ដោយតម្រូវអោយមានការជួយជ្រោមជ្រែងយ៉ាងសស្រាក់សស្រាំ និងតម្រូវអោយមានចំនេះដឹងគ្រប់គ្រាន់ទៅលើវិស័យមួយនេះ ។ ដូច្នេះហើយទើបរាល់លិខិតបទដ្ឋានដែលទាក់ទងទៅនឹងវិស័យសុំកូនប្រជាជនគ្រប់រូប គួរតែសិក្សាស្វែងយល់ជាសាធារណៈ ដើម្បីទទួលបានចំនេះដឹងយ៉ាងទូលំទូលាយពីវិស័យនេះទុកជាប្រយោជន៍នៅពេលត្រូវការជាចាំបាច់។

ដើម្បីបកស្រាយអំពីប្រធានបទ ≪សុំកូន≫ នេះអោយបានគ្រប់ជ្រុងជ្រោយ នាងខ្ញុំបានបែងចែកជា ៣ ជំពូកសំខាន់ៗ ។ ដោយ **ជំពូកទី១** រៀបរាប់ពីសុំកូនពេញលេញ ដែលនិយាយពីសញ្ញាណទូទៅរួមទាំងលក្ខខណ្ឌនៃការបង្កើត អនុភាព និងការកាត់កាល់ជាដើម។ ចំនែកឯ **ជំពូកទី២** គឺរៀបរាប់ពីសុំកូនធម្មតាចំពោះនីតិវិធីក្នុងទម្រង់នេះ មានលក្ខណៈស្រដៀងនឹងសុំកូនពេញលេញគ្រាន់តែមិនសូវតឹងរឹងដូចសុំកូនពេញលេញនោះទេ ។ ចំពោះ **ជំពូកទី៣** គឺមានលក្ខណៈទូលំទូលាយនិងស្មុគស្មាញខ្លាំងជាងគេ គឺនិយាយអំពីសុំកូនអន្តរប្រទេសដែលនីតិវិធីជាប់ពាក់ព័ន្ធនឹងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសអ្នកសុំទៀតផង។ ដូច្នេះ សូមអ្នកទាំងអស់គ្នាធ្វើការអានស្វែងយល់នូវគ្រប់ជំពូកដូចខាងក្រោមនេះ ។

# ជំពូកទី១
# សុំកូនពេញលេញ

## ផ្នែកទី១ ៖ សញ្ញាណទូទៅនៃសុំកូនពេញលេញ

### ១.១. និយមន័យ

សុំកូនពេញលេញ គឺសំដៅដល់ការសុំអនីតិជនដែលមានអាយុក្រោម៨ឆ្នាំយកមកធ្វើជាកូនសុំ ដោយមានការបង្កើតទំនាក់ទំនងឪពុកម្ដាយនឹងកូនជាមួយឪពុកម្ដាយចិញ្ចឹម និងបញ្ចប់ញាតិភាពនៃលោហិត រួមទាំងសិទ្ធិ និងកាតព្វកិច្ចរវាងកុមារ និងឪពុកម្ដាយបង្កើត ឬអាណាព្យាបាលកុមារ ហើយការសុំនេះត្រូវធ្វើតាមសេចក្ដីសម្រេចរបស់តុលាការតាមនីតិវិធីច្បាប់។

ដោយរបបសុំកូនពេញលេញត្រូវកាត់ផ្ដាច់រាល់ទំនាក់ទំនងគតិយុត្តិទាំងអស់រវាងកុមារនឹងឪពុកម្ដាយបង្កើត ឬអាណាព្យាបាលរបស់ខ្លួន រួចបង្កើតទំនាក់ទំនងជាមួយឪពុកម្ដាយចិញ្ចឹមវិញ។ លើសពីនេះ អានុភាពនៃកូនសុំត្រូវមានឋានៈដូចគ្នាទៅនឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម និងត្រូវទទួលបាននូវរាល់សិទ្ធិ និង ករណីកិច្ចដូចគ្នាទាំងអស់ជាមួយកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឪពុកម្ដាយចិញ្ចឹម។

### ១.២. គោលបំណងនៃការបង្កើតសុំកូនពេញលេញ

ដោយកូនសុំពេញលេញ បានបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ ជាមួយឪពុកម្ដាយចិញ្ចឹម ដោយទទួលបាននូវសិទ្ធិ និងករណីកិច្ចពីឪពុកម្ដាយចិញ្ចឹមទៅតាមច្បាប់ត្រឹមត្រូវ ជាពិសេសទទួលបាននូវការរស់នៅនៅក្នុងមជ្ឍដ្ឋានថ្មី ដែលមានភាពល្អប្រសើរជាងមុនដែលមានឪពុកម្ដាយចិញ្ចឹមផ្ដល់នូវអនាគតភ្លឺស្វាង ដោយគេចផុតពីការរស់នៅក្នុងភាពក្រីក្រ ជីវភាពមិនសមរម្យជាមួយឪពុកម្ដាយបង្កើត ។ ដោយលើសពីនេះទៅទៀត គឺមានការសម្រេចដោយតុលាការដែលមានច្បាប់ទទួលស្គាល់។

## ផ្នែកទី២ ៖ លក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញ

ដើម្បីអាចបង្កើតសុំកូនពេញលេញបាន លុះត្រាតែបានបំពេញតាមលក្ខខណ្ឌ ដែលបានកំណត់ដោយច្បាប់ ហើយមានលក្ខខណ្ឌជាច្រើន ដែលលក្ខខណ្ឌទាំងនេះទាក់ទងនឹងអាយុរបស់ឪពុកម្ដាយចិញ្ចឹម និងកូនសុំ ការចូលរួមរបស់ភាគីដែលមានផលប្រយោជន៍ពាក់ព័ន្ធ-ល-។ ដោយការបង្កើតសុំកូនពេញលេញគឺមិនមែនមានតែភាគីម្ខាងៗនោះទេគឺមានទាំងចំពោះឪពុកម្ដាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬម្ដាយចិញ្ចឹម ក៏ដូចជាភាគីកូនសុំ និងនៅមានលក្ខខណ្ឌដទៃមួយចំនួនផងដែរ។

### ២.១. លក្ខខណ្ឌចំពោះឪពុកម្ដាយចិញ្ចឹម

បើយោងទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ការសុំកូនពេញលេញអាចប្រព្រឹត្តទៅបានលុះត្រាតែឪពុកម្ដាយចិញ្ចឹមទាំងពីរមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌដែលបានកំនត់ ហើយត្រូវមានសេចក្ដីសម្រេចរបស់តុលាការអោយមានការសុំកូនពេញលេញនោះ ទើបការសុំកូនកើតចេញជារូបរាងបានដូចជា៖

#### ក.អាយុរបស់ឪពុកម្ដាយចិញ្ចឹម

ដូចជានៅក្នុងមាត្រា១០០៩នៃក្រមរដ្ឋប្បវេណី ពុំបានបញ្ជាក់ថាឪពុកម្ដាយចិញ្ចឹមត្រូវមានអាយុ២៥ឆ្នាំគិតចាប់ពីពេលណានោះទេ ប៉ុន្តែគោលគំនិតនេះនៃមាត្រានេះ គឺគិតចាប់ពីពេលដែលកើតឡើងនូវអានុភាពនៃដីកាសម្រេចដែលថាបុគ្គលដែលដាក់ពាក្យសុំត្រូវមានអាយុ២៥ឆ្នាំឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច២០ឆ្នាំ[1] ទើបអាចបង្កើតសុំកូនពេញលេញបាន ។ ប្រសិនបើអាយុឪពុកម្ដាយចិញ្ចឹមតិចពេក នោះលទ្ធភាព និងបទពិសោធន៍នៃការថែទាំកូននៅមានកម្រិតដែលកូននឹងមិនអាចទទួលបានការថែទាំដែលត្រឹមត្រូវ ម៉្យាងវិញទៀតពួកគេមិនអាចផ្ដល់នូវគ្រួសារដែលល្អប្រសើរជាងឪពុកម្ដាយបង្កើតបាន ហេតុនេះហើយទើបច្បាប់មានការតឹងរឹងចំពោះលក្ខខណ្ឌនៃអាយុរបស់ឪពុកម្ដាយដែលសុំកូនពេញលេញនេះ។

#### ខ.ភាពមានសហព័ទ្ធនិងសហការរបស់ឪពុកម្ដាយចិញ្ចឹម

បុគ្គលដែលក្លាយជាឪពុកចិញ្ចឹម ឬម្ដាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ន្ធ[2]។ដោយត្រូវមានការសហការ និងឯកភាពយល់ព្រមរវាងប្ដីប្រពន្ធ បើមិនដូច្នេះទេប្ដី ឬប្រពន្ធតែម្ខាងមិនអាចក្លាយជាឪពុក ឬម្ដាយចិញ្ចឹមគេបានឡើយ បើសហព័ន្ធម្ខាងទៀតមិនមែនជាឪពុក ឬម្ដាយចិញ្ចឹមនៃកូនសុំនោះ [3] ។តែលើកលែងចំពោះសហព័ន្ធក្លាយជាឪពុក ឬម្ដាយចិញ្ចឹមនៃកូនបង្កើតរបស់សហព័ន្ធម្ខាងទៀត ក្នុងករណីនេះគឺមានន័យថាប្រសិនបើសហព័ទ្ធម្ខាង ចង់សុំកូនរបស់សហ័ទ្ធម្ខាងទៀតមកធ្វើជាកូនសុំ នោះពុំចាំបាច់មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតឡើយ។

[1] មាត្រា ១០០៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[2] កថាខ័ណ្ឌទី១ ក្នុងមាត្រា១០០៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[3] កថាខ័ណ្ឌទី២ ក្នុងមាត្រា១០០៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ២.២. លក្ខខណ្ឌចំពោះកូនសុំពេញលេញ

ដោយនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ គឺមិនបានចែងកំណត់ពីចំនួននៃកូនសុំនោះទេ ។ហើយជាគោលការណ៍កូនសុំត្រូវមានអាយុតិចជាង៨ឆ្នាំ[4] ។ដោយសារតែរបបសុំកូនពេញលេញគឺជារបបដែលបង្កើតឡើងរវាងឪពុកម្តាយចិញ្ចឹម និងកុមារតូចក្នុងការបង្កើតញាតិថ្មី និងផ្តាច់កូនសុំនោះពីញាតិចាស់ហើយកូនសុំត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយចិញ្ចឹមទាំងស្រុង ដើម្បីទទួលបាននូវលក្ខខណ្ឌគ្រួសារដ៏ល្អប្រសើរមួយ ដូច្នេះប្រសិនបើកូនសុំមានអាយុច្រើនល្មមនឹងអាចយល់ដឹងបាន នោះច្បាស់ជាបង្កើតជាបញ្ហារំខានក្រោយពេលសុំកូនជាមិនខាន។

### ២.៣. លក្ខខណ្ឌផ្សេងៗ

ដើម្បីបង្កើតសុំកូនពេញលេញបានលុះត្រាតែ មានការយល់ព្រមពីឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់កុមារដែលត្រូវជាកូនសុំនោះ ប៉ុន្តែក្នុងករណីឪពុកម្តាយរបស់កូនសុំមិនអាចបង្ហាញឆន្ទះបាន ឬមានករណីមានការធ្វើបាបដោយឪពុកម្តាយ បានបោះបង់កូនដោយគំនិតទុច្ចរិត ឬហេតុផលផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ដោយក្នុងករណីនេះសុំកូនពេញលេញអាចបង្កើតបាន ដោយមិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយបង្កើតឡើយ។ ការយល់ព្រមរបស់ឪពុកម្តាយបង្កើតអាចដកវិញនៅពេលណាក៏បាន មុនពេលដីកាសម្រេចបង្កើតសុំកូនពេញលេញចូលជាស្ថាពរ ក្នុងករណីឪពុកម្តាយបង្កើតរបស់កូនសុំបានដកនូវការយល់ព្រមតុលាការ ត្រូវលើកចោលពាក្យសុំបង្កើតនូវសុំកូនពេញលេញ លើកលែងតែការដកការយល់ព្រមនោះបំពានដល់ផលប្រយោជន៍ធ្ងន់ធ្ងររបស់កូនសុំនោះ ដូចមូលហេតុដែលមានចែងនៅក្នុងមាត្រា១០១១វាក្យខណ្ឌទី២នៃក្រមរដ្ឋប្បវេណី។

ដោយនៅក្នុងមាត្រា១០១៣បានចែងថា ដើម្បីបង្កើតសុំកូនពេញលេញបាន តុលាការត្រូវពិចារណាលើស្ថានភាពបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម បានធ្វើក្នុងការគ្រប់គ្រងថែរក្សាកុមារនឹងក្លាយជាកូនសុំជាគោលការណ៍យ៉ាងតិច៦ខែ (ប្រាំមួយ)ខែ។

បន្ថែមពីនេះទៅទៀត សុំកូនពេញលេញមានអានុភាពតាមច្បាប់ លុះត្រាតែបានបង្កើតតាមផ្លូវតុលាការ គឺមានន័យថាបុគ្គលដែលមានបំនងបង្កើតសុំកូនពេញលេញ ត្រូវតែដាក់ពាក្យសុំទៅតុលាការ។

---

[4] មាត្រា ១០១០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ផ្នែកទី៣ ៖ អានុភាពនៃសុំកូនពេញលេញ

យើងអាចឃើញថារបបសុំកូន បង្កើតអានុភាពនៅពេលដីកាសម្រេចសុំកូនចូលជាស្ថាពរ។ ហើយនៅពេលចូលជាស្ថាពរនៃដីកាសម្រេចនេះ វាក៏បានបង្កើតនូវអានុភាពគតិយុត្តិមួយចំនួនផងដែរ មានដូចជា ការកាត់ផ្តាច់ទំនាក់ទំនងញាតិ និង ការបង្កើតទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹមជាដើម។

### ៣.១. ការកាត់ផ្តាច់ទំនាក់ទំនងញាតិ

នៅពេលដែលដីកាសម្រេចសុំកូនពេញលេញចូលជាស្ថាពរ នោះញាតិភាពរវាងឪពុកម្តាយបង្កើតក៏ត្រូវបានបញ្ចប់ [5] គឺមានន័យថាឪពុកម្តាយ នឹងកូនបង្កើតក្លាយជាអ្នកដទៃលែងមានជាប់សាច់ឈាមនឹងគ្នាតទៅទៀត ទាំងសិទ្ធិនិងករណីកិច្ចផ្សេងៗត្រូវបានកាត់ផ្តាច់ទាំងស្រុង លើកលែងតែករណីកូនសុំជាកូនរបស់សហព័ទ្ធម្ខាងទៀត។ ហេតុនេះ សិទ្ធិធ្វើសន្តតិកម្មចំពោះគ្នាទៅវិញទៅមក ត្រូវបានបាត់បង់នឹងមិនអាចទទួលកាតព្វកិច្ចទៅវិញទៅមក ថែមទាំងមិនអាចមានសិទ្ធិសួរសុខទុក្ខកូនបានផងដែរ។ ការកំនត់បែបនេះ ដោយហេតុជាគោលបំនងនៃការបង្កើតសុំកូនពេញលេញគឺបង្កើតញាតិថ្មីមួយ នៅក្នុងមជ្ឈដ្ឋាននៃគ្រួសាររបស់ឪពុកម្តាយចិញ្ចឹមដែលមានលក្ខណៈល្អប្រសើរ ហើយកូនសុំ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុង របស់ឪពុកម្តាយចិញ្ចឹមប្រៀបដូចជាកូនបង្កើត ដូច្នេះដើម្បីជៀសវាងការរំខាន ឬការជ្រៀតជ្រែកដោយកាយវិការមិនសមរម្យរបស់ឪពុកម្តាយបង្កើតដោយប្រការណាមួយ គឺត្រូវតែបញ្ចប់ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតផងដែរ។ ការកំនត់បែបនេះ ជាមូលដ្ឋានសមរម្យនៅពេលដែលសុំកូនពេញលេញបានបង្កើតឡើង ព្រោះដើម្បីផលប្រយោជន៍ទាំងកូនដែលត្រូវសុំ និងឪពុកម្តាយចិញ្ចឹមផងដែរ។ប៉ុន្តែទោះបីទំនាក់ទំនងញាតិនេះត្រូវបញ្ចប់ដោយការកំនត់របស់ច្បាប់ក៏ដោយ ប៉ុន្តែញាតិភាពជាមួយឪពុកម្តាយបង្កើតនិងញាតិភាពជាមួយញាតិលោហិតរបស់ឪពុកម្តាយបង្កើតជាឈាមជ័រតាមធម្មជាតិ ដូច្នេះការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ជាមួយញាតិលោហិត នៅតែបន្ត[6]។

### ៣.២. ការបង្កើតទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម

ទំនាក់ទំនងរវាងកូនចិញ្ចឹមនិងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះ នឹងត្រូវបង្កើតនូវញាតិភាពដូចគ្នានឹងញាតិភាពលោហិត នៅពេលដីកាសម្រេចចាប់ផ្តើម

[5] មាត្រា១០១៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[6] មាត្រា៩៥១ កថាខ័ណ្ឌទី២ នៃក្រមរដ្ឋប្បវេណី

សុំកូនមានអានុភាពចូលជាស្ថាពរ[7]។ ដោយកូនសុំមានឋានៈដូចគ្នានឹងកូនបង្កើត គឺត្រូវទទួលបានសិទ្ធិ និងករណីកិច្ចដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម ហើយកូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលរបស់ខ្លួនមុនបាន[8]។ កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម[9]។ ម៉្យាងទៀតក្នុងករណីដែលប្តីប្រពន្ធណាម្ខាងក្លាយជាឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹមរបស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬម្តាយបង្កើត និងឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម[10]។

## ផ្នែកទី៤ ៖ ការកាត់កាល់សុំកូនពេញលេញ

ការកាត់កាល់គឺជាការបញ្ចប់ទំនាក់ទំនងញាតិរវាងកូនសុំ នឹងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម។ ការស្នើសុំកាត់កាល់កូនសុំពេញលេញបានលុះត្រាតែក្នុងករណីដែលត្រូវនឹងចំនុចដែលកំនត់នៅក្នុងមាត្រា១០១៦នៃក្រមរដ្ឋប្បវេណីដូចខាងក្រោម៖

### ៤.១. មូលហេតុនៃការកាត់កាល់

ទោះបីកូនសុំមិនមែនជាកូនបង្កើតក៏ពិតមែន ប៉ុន្តែក្នុងច្បាប់បានកំណត់យ៉ាងច្បាស់លាស់ពីសិទ្ធិនិងករណីយកិច្ចដែលកូនសុំទទួលបានបន្ទាប់បីដីកាសម្រេចរបស់តុលាការចូលជាស្ថាពរ ហេតុនេះកូនសុំមានលក្ខណៈដូចនឹងកូនបង្កើតដែរ ដូច្នេះឪពុកម្តាយចិញ្ចឹម និងកូនសុំក៏មិនអាចបញ្ចប់ទំនាក់ទំនងនឹងគ្នាដោយងាយៗនោះទេ ។ ម៉្យាងវិញទៀត សុំកូនគ្រាន់តែជាកូនដែលសន្មតតាមច្បាប់ នៅតែមិនមែនជាកូនបង្កើតដែលកើតចេញមកតាមខ្សែលោហិត ដូចនេះសុំកូនអាចបញ្ចប់ទៅវិញដោយការកាត់កាល់ ដែលមានលក្ខខណ្ឌថែងយ៉ាងតឹងរឹងនៅក្នុងមាត្រា១០១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៧ ។

សុំកូនកើតឡើង ដោយសារតែចង់ជួយសង្គ្រោះកុមារអោយទទួលបានគ្រួសារថ្មីដែលមានសុភមង្គលពេញលេញ ពោរពេញទៅដោយការរស់នៅដោយសមរម្យ ប៉ុន្តែប្រសិនបើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬហេតុផលផ្សេងៗទៀតដែលបំពានដល់ផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ឬមិនទទួលបានចិញ្ចឹមបីបាច់ថែរក្សាយ៉ាងត្រឹមត្រូវពីឪពុកម្តាយចិញ្ចឹម នោះកូនសុំអាចធ្វើពាក្យបណ្តឹងទាមទារនៃកាត់កាល់បាន ។ក្រៅពីនេះក៏នៅមានករណីមួយទៀតដែលជាមូលហេតុនៃការកាត់កាល់នេះ គឺប្រសិនបើឪពុកម្តាយបង្កើតមានលទ្

[7] មាត្រា ៩៤០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[8] មាត្រា១០១៥ កថាខ័ណ្ឌទី១និងទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[9] មាត្រា១០១៥ កថាខ័ណ្ឌទី៣ វាក្យខណ្ឌទី១ និងមត្រា១០៣៥ នៃក្រមដ្ឋប្បវេណី

[10] មាត្រា១០១៥ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី

ភាពគ្រប់គ្រាន់ក្នុងការថែរក្សាកូនបង្កើតបានឡើងវិញបាន។ លើសពីនេះ ក៏នៅមានចំនុចមួយចំនួនផ្សេងទៀតដែលជាមូលហេតុនៃបណ្តឹងទាមទារនៃការកាត់កាល់ផងដែរ គឺអាស្រ័យទៅលើឆន្ទានុសិទ្ធិរបស់តុលាការ។

### ៤.២. លក្ខខណ្ឌនៃការកាត់កាល់

ដោយការកាត់កាល់ ត្រូវធ្វើឡើងតាមផ្លូវតុលាការ ដោយបណ្តឹងទាមទារអោយកាត់កាល់ ហើយការសម្រេចអំពីការកាត់កាល់ ត្រូវអនុលោមតាមច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ ហើយអ្នកដែលមានសិទ្ធប្តឹងនឹងការកាត់កាល់ស្មុំកូនពេញលេញបានគឺមានៈ តំណាងអយ្យការ ឪពុកម្តាយបង្កើត និងភាគីកូនសុំ[11]

#### ក. តំណាងអយ្យការ

តុលាការជាអ្នកមានអំណាចសម្រេចលើការកាត់កាល់ភាគីនៃកូនសុំបាន បើសិនឃើញថាការកាត់កាល់នេះពិតជាមានភាពមិនបំរើផលប្រយោជន៍របស់កូនសុំតាមពាក្យរបស់កូនសុំ។

#### ខ.ឪពុកម្តាយបង្កើត

បើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនចោលដោយគំនិតទុច្ចរិត ឬហេតុផលផ្សេងៗដែលបំពានផលប្រយោជន៍កូនសុំយ៉ាងធ្ងន់ធ្ងរហើយឪពុកម្តាយបង្កើត អាចគ្រប់គ្រងថែរក្សាដោយសមរម្យ។

#### គ.កូនសុំ

ប្រសិនបើឪពុកម្តាយចិញ្ចឹមមិនអាចមើលថែរក្សាកូនសុំអោយសមស្របទៅតាមការស្នើសុំនោះ ភាគីកូនសុំអាចធ្វើការប្តឹងនឹងការកាត់កាល់ស្មុំកូនពេញលេញបាន ដោយផ្អែកទៅតាមមាត្រា ១០១៦ នៃក្រមរដ្ឋប្បវេណី ធ្វើបែបនេះគឺដើម្បីការពារនូវផលប្រយោជន៍នៃកូនចិញ្ចឹម។

ការកាត់កាល់ត្រូវធ្វើឡើងតាមនីតិវិធីបណ្តឹងឋានៈបុគ្គហើយតុលាការធ្វើការសម្រេចសេចក្តីដោយចេញសាលក្រម។

### ៤.៣. អានុភាពនៃការកាត់កាល់ស្មុំកូនពេញលេញ

តាមក្រមរដ្ឋប្បវេណីកម្ពុជា ទទួលស្គាល់នូវការបង្កើតឡើងវិញ ដោយស្វ័យប្រវត្តិនូវញាតិភាពរវាងកូនសុំ នឹងឪពុកម្តាយបង្កើត និងញាតិភាពនៃឪពុកម្តាយបង្កើត នឹងកូនសុំក្រោយពីបញ្ចប់ដោយស្មុំកូនពេញលេញត្រូវកើតឡើងវិញគិតចាប់ពីថ្ងៃបានកាត់កាល់។ រីឯញាតិភាពរវាងកូនចិញ្ចឹមសហាព័ទ្ធរបស់ជននោះ បច្ចាញាតិផ្ទាល់ និង សហាព័ទ្ធរបស់បច្ចាញាតិផ្ទាល់នោះ ជាមួយឪពុក

[11] មាត្រា ១០០៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ម្តាយចិញ្ចឹម និងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះ ត្រូវបានបញ្ចប់ដោយការកាត់កាល់ ឬលែងទទួលស្គាល់។

សរុបសេចក្តីមក អានុភាពនៃសាលក្រមសម្រេចកាត់កាល់សុំកូនពេញលេញ នឹងធ្វើអោយកាត់ផ្តាច់ទំនាក់ទំនងញាតិរវាងឪពុកម្តាយចិញ្ចឹម នឹងកូនសុំ និងបានបង្កើតឡើងវិញនូវទំនាក់ទំនងញាតិជាមួយឪពុកម្តាយបង្កើត[12] ។

[12] មាត្រា ១០១៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូកទី២

# សុំកូនធម្មតា

## ផ្នែកទី១ ៖ សញ្ញាណទូទៅនៃសុំកូនធម្មតា

សុំកូនធម្មតា គឺជាការសុំកូនមួយប្រភេទដែលញាតិរវាងកូនសុំ និងឪពុកម្ដាយបង្កើតនៅតែបន្តអត្ថិភាពមិនមានការកាត់ផ្ដាច់ មានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក ហើយកូនសុំ និង ឪពុកម្ដាយបង្កើតមានសិទ្ធិទាមទារ និងករណីយកិច្ចផ្គត់ផ្គង់អាហារកិច្ច ។ ម្យ៉ាងវិញទៀត កូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬនាមត្រកូលមុនសុំកូនបាន ហើយកូនសុំត្រូវទទួលបានឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម នឹងត្រូវទទួលបានសិទ្ធិ និងករណីកិច្ចដូចគ្នា និងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឪពុកម្ដាយចិញ្ចឹម។

### ១.១. និយមន័យ

សុំកូនធម្មតា សំដៅដល់ការសុំកូនដែលកូននោះ អាចជាអនីតិជន ឬនីតិជនដោយមិនកាត់ផ្ដាច់ញាតិភាពពីឪពុកម្ដាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។

### ១.២. លក្ខណៈពិសេសនៃសុំកូនធម្មតា

ដោយសារតែសុំកូនធម្មតាមិនមានលក្ខណៈតឹងរឹងដូចសុំកូនពេញលេញ ដូច្នេះលក្ខខណ្ឌផ្សេងៗដែលទាក់ទងនឹងករណីកិច្ច និងសិទ្ធិក៏ងាយស្រួលក្នុងការទទួលយកផងដែរ ដូចជាញាតិភាពរវាងកូនសុំ និងឪពុកម្ដាយបង្កើតត្រូវបន្តអត្ថិភាពរហូត ហើយកូនសុំនិងឪពុកម្ដាយបង្កើតមានសិទ្ធិធ្វើសន្តតកម្មទៅវិញទៅមក។ កូនសុំធម្មតានឹងទទួលបានគ្រប់លក្ខខណ្ឌ ដែលកូនបង្កើតនៃឪពុកម្ដាយចិញ្ចឹមទទួលបានទាំងសិទ្ធិ និងករណីកិច្ច។

## ផ្នែកទី២ ៖ លក្ខខណ្ឌនៃការបង្កើតសុំកូនធម្មតា

លក្ខខណ្ឌនៃការបង្កើតសុំកូនធម្មតាក៏មិនខុសពីលក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញប៉ុន្មានដែរ មានដូចជាអាយុរបស់ឪពុកម្ដាយចិញ្ចឹម និងកូនសុំ ការចូលរួមរបស់សហព័ទ្ធម្ខាងរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយ ឬម្ដាយចិញ្ចឹមក្នុងករណីបុគ្គលនោះមានសហព័ទ្ធ ការចូលរួមរបស់ឪពុកម្ដាយបង្កើត និងមូលដ្ឋានវិនិច្ឆ័យដែលតុលាការនឹងវិចារណា។

### ២.១. អាយុនិងស្ថានភាពរបស់ឪពុកម្ដាយចិញ្ចឹម

បុគ្គលដែលមានអាយុចាប់ពី២៥ (ម្ភៃប្រាំឆ្នាំ) ឡើងទៅ [13] អាចដាក់ពាក្យជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំ។ ប៉ុន្តែបុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ឬបុគ្គលដែលមានអាយុច្រើនជាងបុគ្គលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមឡើយ។ក្នុងករណីដែលបុគ្គលនឹងក្លាយជាកូនសុំជាអនីតិជន អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវដាក់ពាក្យសុំដែលបានកំណត់ខាងលើនេះ ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ក្នុងមាត្រា១០២០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

សុំកូនធម្មតា អាចបង្កើតបានទោះបីជាបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមមាន ឬគ្មានសហព័ទ្ធក៏ដោយ។ ប៉ុន្តែប្រសិនបើភាគីម្ខាងបានដាក់ពាក្យជាមួយសហព័ទ្ធម្ខាងទៀត ឬសហព័ទ្ធម្ខាងទៀតមិនអាចបង្ហាញឆន្ទៈយល់ព្រមបាន នោះសុំកូនធម្មតាអាចបង្កើតបាន។ បើបុគ្គលដែលមានសហព័ទ្ធសុំកូនជាអនីតិជន បុគ្គលនោះត្រូវដាក់ពាក្យសុំរួមគ្នាជាមួយសហព័ទ្ធទើបអាចបង្កើតសុំកូនធម្មតាបាន ។ ប៉ុន្តែក្នុងករណីយកកូនរបស់សហព័ទ្ធមកធ្វើជាកូនសុំ ឬសហព័ទ្ធម្ខាងទៀតមិនអាចបង្ហាញឆន្ទៈបាន សុំកូនអាចបង្កើតឡើងបានត្រឹមអ្នកដាក់ពាក្យសុំតែម្ខាងឯងប៉ុណ្ណោះ។

### ២.២. អាយុនិងស្ថានភាពរបស់កូនសុំ

ដោយនៅក្នុងលក្ខខណ្ឌសុំកូនធម្មតាមិនបានកំនត់ជាដាច់ខាតឡើយពីអាយុនៃកូនសុំ ដូច្នេះកូនសុំអាចជាអនីតិជន ឬនីតិជន ប៉ុន្តែចំនុចសំខាន់គឺមិនត្រូវអោយបុគ្គលដែលនឹងក្លាយជាកូនសុំមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមឡើយ។

ករណីបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន តុលាការអាចអោយបង្កើតសុំកូនបាន លុះត្រាតែយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់អនីតិជននោះ ។ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន បើឪពុកម្ដាយបង្កើតរបស់បុគ្គលនោះបានលែងលះហើយ តុលាការត្រូវសួរយោបល់របស់ឪពុក ឬ ម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបា ដើម្បីវិនិច្ឆ័យ អំពីចំណុចដែលបានកំនត់ក្នុងចំនុចខាងលើ យោងតាមមាត្រា១០២៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។

បើអនីតិជនបានដល់អាយុ១៥ឆ្នាំ (ដប់ប្រាំ) ឆ្នាំ ដើម្បីបង្កើតការសុំកូន ត្រូវទទួលការយល់ព្រមពីអនីតិជននោះ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ១៥ (ដប់ប្រាំ) ឆ្នាំក៏ដោយ បើអនីតិ

[13] មាត្រា ១០២០ កថខណ្ឌទី១ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវេណី

ជននោះអាចបង្ហាញឆន្ទះរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំនត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ។

### ២.៣. មូលដ្ឋានវិនិច្ឆ័យដែលតុលាការនឹងពិចារណា

តុលាការអាចអោយ បង្កើតសុំកូនធម្មតាបាន លុះត្រាតែករណីទាំងអស់នោះឈរផ្អែកលើមូលដ្ឋានដូចខាងក្រោម ៖

ក. មានការបញ្ជាក់អំពីឆន្ទះពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្តាយ និងកូន។

ខ. តុលាការមិនត្រូវអោយបង្កើតសុំកូនឡើយ បើយល់ឃើញថាសុំកូនត្រូវបានបំពានក្នុងគោលបំនងរៀបអាពាហ៍ពិពាហ៍ រវាងភេទផ្សេងគ្នា ឬភេទដូចគ្នា ឬក្នុងគោលបំនងមិនត្រឹមត្រូវផ្សេងទៀត[14]។

គ. ប្រសិនបើកូនសុំ ជាអនីតិជនតុលាការអាចអោយបង្កើតសុំកូនបានលុះត្រា តែយល់ឃើញថាមានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូនសុំ ដែលជាអនីតិជននោះ។ តុលាការត្រូវពិចារណាអំពីឆន្ទះរបស់អនីតិជន កាលបើអនីតិជនមានអាយុ១៥ឆ្នាំ ហើយទោះបីជាពុំមានអាយុ១៥ឆ្នាំក៏ដោយក៏តុលាការអាចសួរយោបល់ពីអនីតិជនបានដែរ។ លើសពីនេះទៅទៀត ក្នុងករណីឪពុកម្តាយបង្កើតលែងលះគ្នា មុននឹងបង្កើតសុំកូនធម្មតា តុលាការត្រូវសួរយោបល់ឪពុក ឬម្តាយបង្កើតដែលមិនមែនជាអ្នកមានអំណាចមេបា។

## ផ្នែកទី៣ ៖ អានុភាពនៃសុំកូនធម្មតា

ក្រោយពីការសុំកូនធម្មតាបានសម្រេចចូលជាស្ថាពរ នោះអានុភាពមួយចំនួនក៏បានកើតឡើងដែរ ដោយនៅក្នុងនោះមានដូចជា ការបង្កើតញាតិភាពជាមួយឪពុកម្តាយចិញ្ចឹម និងការបន្តញាតិភាពជាមួយឪពុកម្តាយបង្កើត។

### ៣.១. ការបង្កើតញាតិភាពជាមួយឪពុកម្តាយចិញ្ចឹម

ដូចគ្នានឹងសុំកូនពេញលេញដែរ ក្រោយពីការបង្កើតសុំកូនរួច ញាតិភាពរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំត្រូវបានបង្កើតឡើង ដោយកូនសុំមានឋានៈដូចគ្នានឹងកូនបង្កើតនៃឪពុកម្តាយចិញ្ចឹមផងដែរ ដោយត្រូវទទួលបានសិទ្ធិ និងករណីកិច្ចដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម។ កូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬនាមត្រកូលមុនសុំកូន

[14] មាត្រា ១០២៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក៏បាន [15] ។ក្នុងករណីដែលកូនសុំជាអនីតិជន កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម។ ប៉ុន្តែក្នុងករណីយកកូនបង្កើតរបស់សហព័ទ្ធមកធ្វើជាកូនសុំ កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬម្តាយចិញ្ចឹមនៃសហព័ទ្ធនោះ[16]។

### ៣.២. ការបន្តញាតិភាពជាមួយឪពុកម្តាយបង្កើត

ដោយសុំកូនធម្មតាមានភាពខុសគ្នានឹងសុំកូនពេញលេញត្រង់ថា សុំកូនធម្មតានៅអាចបន្តញាតិភាពជាមួយឪពុកម្តាយបង្កើតបាន ហេតុនេះកូនសុំនិងឪពុកម្តាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្មអោយគ្នាទៅវិញទៅមក ហើយក៏មានសិទ្ធិទាមទារ និងករណីកិច្ចផ្គត់ផ្គង់អាហារកិច្ចចំពោះគ្នាទៅវិញទៅមកផងដែរ[17]។

គេអាចនិយាយបានថា សុំកូនធម្មតាកូនសុំនោះគឺមានទាំងឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹមផង ហេតុនេះទំនាក់ទំនងទាំងសិទ្ធិធ្វើសន្តតិកម្មទៅវិញទៅមកនៅតែមាន។ ក្នុងករណីកូនសុំជាអនីតិជន អ្នកមានអំណាចមេបាលើកូនសុំគឺឪពុកម្តាយចិញ្ចឹម។

## ផ្នែកទី៤ ៖ ការកាត់កាល់សុំកូនធម្មតា

### ៤.១. មូលហេតុនិងការវិនិច្ឆ័យនៃការកាត់កាល់សុំកូនធម្មតា

ការកាត់កាល់ សំដៅដល់ការបោះបង់លែងរាប់អានតទៅទៀត គឺមានន័យថាបើមានពាក្យសុំកាត់កាល់សុំកូនធម្មតា តុលាការអាចសម្រេចអោយ កាត់កាល់បានក្នុងករណីដែលភាគីទាំងសងខាងមានបំណងពិតប្រាកដមែន ក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្តាយនឹងកូន ដោយយោង តាមមាត្រា១០៣០នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។ លើសពីនេះបុគ្គលដែលអាចដាក់ពាក្យបណ្តឹងទាមទារអោយកាត់កាល់បាន លុះត្រាតែភាគីម្ខាងទៀតបានប្រព្រឹត្តដូចក្នុងបញ្ញត្តិនៃមាត្រា១០៣១នៃក្រមរដ្ឋប្បវេណី ដែលចែងពីមូលហេតុនៃការកាត់កាល់សុំកូនធម្មតានេះ

### ៤.២. ពាក្យសុំអោយកាត់កាល់សុំកូនធម្មត

ភាគីនៃសុំកូន អាចដាក់ពាក្យសុំទៅតុលាការអោយកាត់កាល់សុំកូនធម្មតាបាន ក្នុងករណីដែលភាគីសងខាងព្រមព្រៀងអំពីការកាត់កាល់នេះ។ ក្នុងករណីដែលកូនសុំជាអនីតិជន ពាក្យសុំកាត់កាល់ត្រូវធ្វើឡើងដោយមានការព្រមព្រៀងគ្នានោះ ត្រូវធ្វើឡើងដោយឪពុកម្តាយចិញ្ចឹម និងបុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ ក្រោយពេលកាត់កាល់។ ប៉ុន្តែបើកូនសុំដល់អាយុ១៥ (ដប់ប្រាំ)ឆ្នាំហើយ ត្រូវទទួលបានការយល់ព្រមពីកូនសុំនោះ។ ទោះបីជាអនីតិជនមិន

[15] មាត្រា ១០២៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[16] មាត្រា ១០២៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី

[17] មាត្រា ១០២៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទាន់ដល់អាយុ១៥ឆ្នាំក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាននោះតុលាការត្រូវសួរយោបល់របស់អនីតិជននោះផងដែរ។ ក្នុងករណីដែលឪពុកម្តាយបង្កើតរបស់កូនសុំបានលែងលះគ្នាហើយ ឪពុកម្តាយបង្កើតរបស់កូនសុំនោះត្រូវពិភាក្សាគ្នា និងកំណត់ថាឪពុក ឬម្តាយបង្កើតជាអ្នកដែលត្រូវក្លាយជាអ្នកមានអំណាចមេបានៅក្រោយពេលកាត់កាល់ ប៉ុន្តែបើការពិភាក្សាខាងលើ ពុំបានសម្រេច ឬពុំអាចពិភាក្សាបាន តុលាការត្រូវកំនត់បុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបាដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូនសុំ[18]។

### ៤.៣. លក្ខខណ្ឌនៃការកាត់កាល់សុំកូនធម្មតា

ភាគីម្ខាងនៃសុំកូន អាចដាក់ពាក្យបណ្តឹងទាមទារអោយកាត់កាល់បាន លុះត្រាតែក្នុងករណីដែលភាគីម្ខាងត្រូវបានបោះបង់ចោលដោយម្ខាងទៀតដោយទុច្ចរិត។ ក្នុងអំឡុងពេលយ៉ាងតិច១ឆ្នាំថាភាគីម្ខាងទៀត មិនច្បាស់ថានៅរស់ ឬទទួលមរណភាព ។ បើមានមូលហេតុធ្ងន់ធ្ងរផ្សេងទៀតដែលបណ្តាលអោយមានការពិបាកក្នុងការបន្តសុំកូនជាដើម។

ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជននោះឪពុកម្តាយចិញ្ចឹមមិនអាចដាក់ពាក្យបណ្តឹងសុំកាត់កាល់ចំពោះកូនសុំបានឡើយ។

ទោះបីក្នុងករណីកូនសុំជាអនីតិជនក៏ដោយក៏កូនសុំអាចដាក់ពាក្យបណ្តឹងចំពោះឪពុកម្តាយចិញ្ចឹមបានដែរ ប្រសិនបើមានដូចលក្ខខណ្ឌដែលបានកំនត់នៅក្នុងចំនុចខាងលើ[19]។

### ៤.៤. អានុភាពនៃការកាត់កាល់សុំកូនធម្មតា

ដោយអានុភាពទាំងឡាយនៃសុំកូនធម្មតា ត្រូវបញ្ចប់ទៅពេលអនាគត ដោយការកាត់កាល់នេះ ហើយក្រោយការកាត់កាល់ កូនសុំអាចទទួលវិញនូវនាមត្រកូលមុនសុំកូនក៏បាន ឬអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន។

[18] មាត្រា ១០២៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[19] មាត្រា ១០៣១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូកទី៣

# សុំកូនអន្តរប្រទេស

## ផ្នែកទី១ ៖ សញ្ញាណទូទៅនៃការសុំកូនអន្តរប្រទេស

### ១.១. និយមន័យ

សុំកូនអន្តរប្រទេសក៏មិនខុសពីសុំកូនពេញលេញដែរ ពោលគឺជាការសុំអនីតិជនដែលមានអាយុក្រោម៨ (ប្រាំបី) ឆ្នាំ យកមកធ្វើជាកូនចិញ្ចឹមដែលមានឋានៈស្មើនឹងកូនបង្កើត ហើយត្រូវបញ្ចប់ញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត និងញាតិភាពជាមួយញាតិលោហិតរបស់ឪពុកម្តាយបង្កើត ហើយការសុំកូននេះក៏ត្រូវសម្រេចដោយតុលាការពីប្រទេសដែលសុំកូននោះ រួចធ្វើដំនើរទៅរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសរបស់អ្នកសុំ។

សរុបសេចក្តីមក សុំកូនអន្តរប្រទេសគឺជាការសុំទារក ឬកុមារកំព្រាដែលមានសញ្ជាតិកម្ពុជាដែលមានលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេស ហើយអ្នកសុំកូនទៅចិញ្ចឹមត្រូវនៅប្រទេសដទៃដែលជាលំនៅអចិន្ត្រៃយ៍របស់ខ្លួន ជាពិសេសត្រូវទទួលស្គាល់ដោយច្បាប់ប្រទេសនោះ។

### ១.២. គោលបំនងនៃការសុំកូនអន្តរប្រទេស

គោលបំនងនៃការសុំកូននេះគឺដើម្បីឧត្តមប្រយោជន៍ និងការពារសិទ្ធិជាមូលដ្ឋានរបស់កុមារដែលកុមារគ្រប់រូបត្រូវទទួលបាននូវការរីកចំរើននៅក្នុងមជ្ឈដ្ឋានថ្មីនៅក្នុងគ្រួសារថ្មីដែលគប្បីត្រូវទទួលបានប្រកបដោយសុភមង្គល ការស្រលាញ់យកចិត្តទុកដាក់ សេចក្តីសុខពីឪពុកម្តាយថ្មីដែលជាអ្នកសុំ ដើម្បីអោយកុមារមានការអភិវឌ្ឍន៍ពេញលេញស្របទៅតាមបុគ្គលិកលក្ខណៈរបស់ខ្លួន ជាពិសេសគឺកុមារដែលត្រូវការនូវការថៃទាំជាពិសេសពីមនុស្សនៅជុំវិញខ្លួន។

### ១.៣. គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស

ដើម្បីអនុវត្តនូវការសុំកូនអន្តរប្រទេសអោយមានប្រសិទ្ធិភាព គេត្រូវគោរពទៅតាមគោលការណ៍មួយចំនួនដែលបានចែងនៅក្នុងច្បាប់ស្តីពីការសុំកូនអន្តរប្រទេសដែលក្នុងនោះមានដូចជា៖

- កុមារត្រូវរីកចំរើនធំធាត់នៅក្នុង បរិយាកាសគ្រួសារមានសុភមង្គល មានសេចក្តីស្រលាញ់ និងការយោគយល់ ដើម្បីអោយមានការអភិវឌ្ឍពេញលេញ និងយ៉ាងសុខដុមនូវបុគ្គលិកលក្ខណៈរបស់ខ្លួន។
- សុំកូនអន្តរប្រទេស អាចអនុញ្ញាតបានក្រោយពីលទ្ធភាពផ្តល់ការឧបត្ថម្ភគាំទ្រ ដើម្បីអោយកុមាររស់នៅក្នុងគ្រួសារកំនើត ។

- ស្មុំកូនអន្តរប្រទេសអាចប្រព្រឹត្តទៅបានលុះត្រាតែជាស្មុំកូនពេញលេញដែលបង្កើតនូវទំនាក់ទំនងរវាងអ្នកសុំ និងកូនសុំជាអចិន្ត្រៃយ៍ និងផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និងកាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះ។
- មិនរើសអើងអំពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិកំណើត ឋានៈក្នុងសង្គម ធនធាន ពិការភាព ឬស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬរបស់ឪពុកម្តាយ ឬរបស់ឪពុក ឬរបស់ម្តាយ ឬរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ។
- រាល់ការសម្រេច និងសកម្មភាពទាក់ទងនឹងដំណើរការស្មុំកូនអន្តរប្រទេសត្រូវគិតគូរអោយបានច្រើនលើសលប់ដល់ឧត្តមប្រយោជន៍របស់កុមារ។
- តុលាការ និងអជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងដំណើរការស្មុំកូនអន្តរប្រទេសត្រូវធានាថា នៅពេលកំពុងដំណើរការនីតិវិធីស្មុំកូន កុមារដែលមានសមត្ថភាពអាចដឹងខុសត្រូវ ត្រូវបានពិគ្រោះយោបល់ និងពន្យល់ណែនាំអោយបានត្រឹមត្រូវអំពីអានុភាពនានាដែលកើតចេញពីស្មុំកូននេះដោយគិតគូរដល់សេចក្តីប្រាថ្នា និងមតិរបស់កុមារដើម្បីឧត្តមប្រយោជន៍របស់កុមារ។
- ហាមការធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពយកផលកម្រៃពីស្មុំកូនអន្តរប្រទេស។អាជីវកម្ម ឬសកម្មភាពយកផលកម្រៃពីស្មុំកូនអន្តរប្រទេសមាន ៖
    + អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬឪពុក ឬម្តាយអោយបោះបង់ទារកដែលកើតមកហើយ ឬដែលនឹងកើតដើម្បីអោយប្រគល់កូនតាមរយៈស្មុំកូនអន្តរប្រទេស។
    + អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈស្មុំកូនអន្តរប្រទេស និងឪពុក ឬម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬនឹងកើត។
    + អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈស្មុំកូនអន្តរប្រទេស និង ស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅអោយអ្នកសុំ។
- អាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធក្នុងនីតិវិធីស្មុំកូនអន្តរប្រទេស ត្រូវធានាថាដំណើរការស្មុំកូនអន្តរប្រទេស មិនបណ្តាលអោយមានការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនស្របច្បាប់ និងត្រូវបង្ការមិនអោយមានការចាប់ពង្រត់ ការលក់

និង ការជួញដូរកុមារក្នុងពេលកំពុងដំណើរការសុំកូនអន្តរប្រទេស។ មានតែប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាន ដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះដែលត្រូវបង់[20]។

## ផ្នែកទី២ ៖ លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស

### ២.១. អំពីកូនសុំ

ដោយកូនសុំគឺជាកម្មវត្ថុនៃដំណើរការសុំកូនអន្តរប្រទេស ដែលទាមទារនូវលក្ខខណ្ឌអោយស្របទៅនឹងច្បាប់ដែលចូលជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ហើយកុមារដែលមានអត្តសញ្ញាណត្រឹមត្រូវត្រូវមានលក្ខខណ្ឌដូចខាងក្រោម ៖

- កុមារមានសញ្ជាតិខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។
- កុមារមានអាយុក្រោម ៨ (ប្រាំបី)ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែករណីកុមារត្រូវការនូវការថែទាំពិសេស ដែលអនុញ្ញាតបានដល់អាយុក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ។
- ក្នុងករណី កុមារមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម៨ (ប្រាំបី) ឆ្នាំ អាចអនុញ្ញាតអោយសុំកុមារនោះរួមជាមួយនឹងបងប្អូនបង្កើត ដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។
- កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬ រស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀត ដែលត្រួតពិនិត្យដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។
- កុមារទាំងនោះស្ថិតនៅក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬ កុមារដែលស្ថិតនៅក្រោមអំណាចមេបាដែលមានស្ថានភាពលំបាកបំផុត។
- កុមារនោះត្រូវបានប្រកាសថាអាចសុំជាកូនចិញ្ចឹមបាន ដោយអនុលោមតាមមាត្រា ១៣នៃច្បាប់សុំកូនអន្តរប្រទេសដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤។

ក្នុងករណី ដែលសុំកូនដោយសាច់ញាតិ សុំកូនអាចអនុញ្ញាតបានចំពោះកុមារមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលរស់នៅក្នុង ឬក្រៅមណ្ឌលកុមារកំព្រា[21]។

ក្នុងករណីដែលកុមារត្រូវបានរកឃើញ និងបញ្ជូនមកមណ្ឌលកុមារកំព្រាហើយរកមិនឃើញឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ ឬអាណាព្យាបាលសម្រាប់អនីតិជននោះ ប្រធានមណ្ឌល

[20] មាត្រា៥ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

[21] មាត្រា១០ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

កុមារកំព្រាត្រូវជូនដំណឹងទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ពីវត្តមានកុមារ យ៉ាងយូរបំផុត ៧ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលកុមារមកដល់មណ្ឌល។ មន្ទីរទទួលបន្ទុក ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចដើម្បីបញ្ចូលឈ្មោះកុមារក្នុងបញ្ជីស្តីពីកុមារដែលត្រូវបានរាយការណ៍ថា ត្រូវបានគេបោះបង់ចោល។

មន្ទីរទទួលបន្ទុក ត្រូវប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីស្វែងរកសាច់ញាតិរបស់កុមារនោះ តាមរយៈប្រព័ន្ធផ្សព្វផ្សាយជាសាធារណៈទៅតាមលទ្ធភាព។ បន្ទាប់ពីផ្សព្វផ្សាយដំនឹងរយៈពេល៥ខែ នៅតែរកមិនឃើញសាច់ញាតិអនីតិជននោះ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវតែផ្ញើរបាយការណ៍ស្តីពីការខិតខំស្រាវជ្រាវនេះ ហើយត្រូវផ្ញើមួយច្បាប់ទៅក្រសួងទទួលវិស័យសង្គមកិច្ច ដើម្បីចុះឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារដែលត្រូវបោះបង់ចោល។

ចាប់ពីពេលដែលកុមារត្រូវបានរកឃើញ និងរហូតដល់តុលាការបានជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ប្រធានមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានីខេត្ត គឺជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន[22]។

ប្រសិនបើអ្នកដែលមានអំណាចមេបានៃកុមារនោះ មានជីវភាពក្រលំបាក មិនអាចចិញ្ចឹមកុមារបាន ហើយបានធ្វើការទុកដាក់កុមារអោយនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនោះ ត្រូវបញ្ចូលឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារ ដែលត្រូវបានធ្វើការទុកដាក់អោយនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច[23]។

### ២.២. អំពីឪពុកម្តាយបង្កើត ឬអាណាព្យាបាល

#### ក. ការយល់ព្រមរបស់ឪពុកម្តាយ ឬអាណាព្យាបាល

ការយល់ព្រមរបស់ឪពុកម្តាយបង្កើត ឬអាណាព្យាបាលទៅលើដំនើរការសុំកូនពិតជាត្រូវការជាចាំបាច់ ដោយការយល់ព្រមនេះត្រូវស្ថិតនៅក្រោមរូបភាពដែលមិនមានការបង្ខិតបង្ខំ ការឆបោក ឬការបញ្ចុះបញ្ចូលដែលផ្តល់ផលប្រយោជន៍តបស្នងអ្វីឡើយ និងឪពុកម្តាយបង្កើត ឬអាណាព្យាបាលសុទ្ធ តែបានដឹងច្បាស់ពីផលវិបាកនៃការយល់ព្រមរបស់ខ្លួនចំពោះសុំកូនអន្តរប្រទេសនេះ។ដូចនេះ ដំនើរការសុំកូនអាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារតាមករណីដូចជា៖

- ក្នុងករណីកុមារមានចំណងបុត្តភាពជាមួយឪពុក និងម្តាយ ការយល់ព្រមត្រូវផ្តល់ដោយឪពុក និងម្តាយរបស់កុមារនោះ។

[22] មាត្រា១១ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[23] មាត្រា១២ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

- ក្នុងករណីដែលឪពុក ឬម្តាយណាមួយរបស់កុមារបានស្លាប់ ឬស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទះបាន ឬត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយឪពុក ឬម្តាយតែម្ខាងដែលមានអំណាចមេបាជាការគ្រប់គ្រាន់។
- ក្នុងករណីដែលឪពុកម្តាយរបស់កុមារបានស្លាប់ ឬស្ថិតនៅក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទះបាន ឬត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនោះ[24]។

ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវប្រាប់យ៉ាងច្បាស់លាស់ ដល់អ្នកដែលត្រូវផ្តល់ការយល់ព្រមអំពីអានុភាពនៃការយល់ព្រម នូវការបញ្ចប់នូវបុត្តភាពព្រមទាំងការបញ្ចប់នូវសិទ្ធិ និងកាតព្វកិច្ចជាអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន និងត្រូវប្រាប់អំពីបែបបទ និងរយៈពេលបញ្ឈប់នៃការយល់ព្រមនេះ។

ទោះក្នុងករណីណាក៏ដោយការយល់ព្រមត្រូវផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរនៅចំពោះមុខមេឃុំ ឬចៅសង្កាត់ខាងទីលំនៅរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ[25]។

**ខ.ការបញ្ឈប់ការយល់ព្រមលើសុំកូន**

ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារអាចបញ្ឈប់ការយល់ព្រមរបស់ខ្លួនវិញបានរហូតដល់មុនពេលសេចក្តីសម្រេចរបស់តុលាការស្តីពីសុំកូនចូលជាស្ថាពរ។ការបញ្ឈប់ការយល់ព្រមឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននេះអាចត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់នៅចំពោះមុខមេឃុំ ឬចៅសង្កាត់ខាងលំនៅឋានរបស់ខ្លួន។ មេឃុំ ឬចៅសង្កាត់ខាងលំនៅឋានរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនកុមារ ត្រូវធ្វើកំណត់ហេតុអំពីកិច្ចការនេះ ហើយត្រូវបញ្ជូនកំណត់ហេតុនេះ ទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ប្រធានមណ្ឌលកុមារកំព្រាដែលពាក់ព័ន្ធ និងត្រូវប្រគល់កំណត់ហេតុចម្លង ដែលមានសេចក្តីបញ្ជាក់នៅលើកំណត់ហេតុនោះទៅអោយឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ[26]។

---

[24] មាត្រា១៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

[25] មាត្រា១៦ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

[26] មាត្រា១៧ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

**គ. ការដកហូតអំណាចមេបាដោយមានការយល់ព្រមពីតុលាការ**

ដោយសារតែដំណើរការនៃស្មុំកូនអន្តរប្រទេស បានធ្វើអោយកាត់ផ្តាច់នូវទំនាក់ទំនងសាច់ញាតិដូចនឹងស្មុំកូនពេញលេញដែរ ដូច្នេះមានករណីខ្លះឪពុកម្តាយបង្កើតមានការរារែកចិត្តក្នុងការយល់ព្រមទៅលើដំនើរការស្មុំកូនអន្តរប្រទេសនេះ ។ ដោយនៅក្នុងមាត្រា១៩ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេសក៏បានចែងពី ករណីដែលឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារបដិសេធការយល់ព្រម ឬបញ្ឈប់ការយល់ព្រមរបស់ខ្លួន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចប្តឹងសុំអោយតុលាការប្រកាសដកហូតអំណាចមេបាពីឪពុកម្តាយ ឬឪពុក ឬម្តាយ ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ក្នុងករណីពិនិត្យឃើញថា ការបដិសេធ ឬការបញ្ឈប់ការយល់ព្រមនេះធ្វើអោយបាត់បង់ផលប្រយោជន៍របស់កុមារ ឬ បណ្តាលអោយប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬសីលធម៌របស់កុមារ។

ដោយពាក្យបណ្តឹងទៅតុលាការត្រូវធ្វើក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារបដិសេធ ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន។

**២.៣. អំពីអ្នកសុំ**

អ្នកសុំដែលអាចអនុញ្ញាតអោយសុំទារក ឬកុមារទៅចិញ្ចឹមបានជាកូនបាន ត្រូវសមស្របនឹងលក្ខខណ្ឌមួយចំនួនដូចជា ៖

- អ្នកសុំជាប្តីប្រពន្ធត្រូវមានអាយុចាប់ពី៣០ (សាមសិប)ឆ្នាំ និងមានអាយុលើសកូនសុំយ៉ាងតិច ២២ (ម្ភៃពីរ)ឆ្នាំ និងយ៉ាងច្រើនបំផុត ៤៥ (សែសិបប្រាំ)ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំកូន។
- បើអ្នកសុំមិនបានបំពេញតាមចំណុច១ ខាងលើ ហើយក្នុងករណីស្មុំកូនឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារនោះ ស្មុំកូនអាចអនុញ្ញាតអោយបានក្នុងករណីអ្នកសុំមានដើមកំណើតសញ្ជាតិខ្មែរ សុំកុមារដែលជាសាច់ញាតិរបស់ខ្លួន ឬអ្នកសុំជាសហព័ន្ធដែលសុំកូននៃសហព័ន្ធម្ខាងទៀត ឬ អ្នកសុំបានសុំកុមារដែលត្រូវការការថែទាំពិសេស ឬស្ថានភាពផ្សេងទៀតដែលបម្រើឧត្តមប្រយោជន៍របស់កុមារ។
- ក្នុងករណីអ្នកសុំមានប្តី ឬប្រពន្ធ ការសុំកូនត្រូវធ្វើដោយសហព័ន្ធទាំងពីររួមគ្នា លើកលែងតែករណីដែលសហព័ន្ធណាម្ខាងសុំកូនបង្កើតនៃសហព័ន្ធម្ខាងទៀត។
- ច្បាប់ជាតិរបស់អ្នកសុំនីមួយៗ និងច្បាប់ប្រទេសនៃលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំបានទទួលស្គាល់ និងអនុញ្ញាតនូវបុគ្គភាពនៃស្មុំកូនពេញលេញ។

- ប្រទេសនៃសញ្ជាតិ ឬប្រទេសលំនៅឋានអចិន្ត្រៃយ៍នៃអ្នកសុំ ត្រូវតែជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា។
- អ្នកសុំត្រូវមានលក្ខណៈសម្បត្តិ និងលក្ខខណ្ឌជាសារវន្តនានាសម្រាប់សុំកូនស្របទៅតាមច្បាប់ប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន។
- អ្នកសុំត្រូវជាជនពុំធ្លាប់ត្រូវបានផ្តន្ទាទោស ឬ កំពុងត្រូវប្តឹងអំពីកំហុសទាក់ទងទៅនឹងកិរិយាមារយាទ ឬការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមណាមួយនៅក្នុងប្រទេសនៃសញ្ជាតិរបស់ខ្លួន ឬប្រទេសលំនៅឋានអចិន្ត្រៃយ៍ ឬក្នុងប្រទេសណាមួយដែលខ្លួនបានស្នាក់នៅចុងក្រោយ។
- អ្នកសុំត្រូវតែជាអ្នកមានសមត្ថភាពផ្តល់ការថែទាំសមស្រប និង ការគាំទ្រចាំបាច់ដល់កូនសុំ។
- អ្នកសុំត្រូវបានអនុញ្ញាតអោយសុំកូនបាន លុះត្រាតែអ្នកសុំកូនគ្មានកូន ឬមានកូនតែម្នាក់នៅក្នុងបន្ទុក។ អ្នកសុំអាចសុំកូនបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតអាចអនុញ្ញាតអោយសុំច្រើននាក់បាន[27]។

## ផ្នែកទី៣ ៖ អាជ្ញាធរមានសមត្ថកិច្ចក្នុងកិច្ចការសុំកូនអន្តរប្រទេស

ជាទូទៅនៅក្នុងដំណើរការនីតិវិធីណាក៏ដោយគឺត្រូវមានអង្គការ ឬភ្នាក់ងារដែលមានសមត្ថកិច្ចគ្រប់គ្រាន់ក្នុងការគ្រប់គ្រងក៏ដូចជាជួយដោះស្រាយនៅពេលមានបញ្ហាណាមួយកើតឡើង និងជាអាជ្ញាធរកណ្តាលជួយសម្រួលដល់ដំណើរការអោយកាន់តែប្រសើរនិងងាយស្រួល ដោយមានដូចជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស រដ្ឋបាលសុំកូនអន្តរប្រទេស និងទីភ្នាក់ងារសុំកូនអន្តរប្រទេសជាដើម ។

### ៣.១. អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកបំពេញតួនាទីអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ដែលមានសមត្ថកិច្ចចម្បងមួយដ៏សំខាន់ សម្រាប់ការអនុវត្តន៍ដំណើរការទាំងឡាយចំពោះបញ្ហាសុំកូនអន្តរប្រទេស ជាពិសេសមានចំនាត់ការត្រឹមត្រូវចំពោះការកេងប្រវ័ញ្ចយកចំនេញមិនត្រឹមត្រូវផ្នែកហិរញ្ញវត្ថុដែលទាក់ទងនឹងសុំកូន ហើយដែលផ្ទុយនឹងគោលបំនងនៃអនុសញ្ញានៃទីក្រុងឡាអេស្តីពីការការពារកុមារ និង សហប្រតិបត្តិការដែលទាក់ទងនឹងសុំកូនអន្តរ

[27] មាត្រា២១ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

ប្រទេស។ ដោយអាជ្ញាធរគ្រប់ជាន់ថ្នាក់ត្រូវរួមសហការគ្នាទៅវិញទៅមក ក្នុងចំនាត់ការនេះអោយមានប្រសិទ្ធភាព។

**ក.ភារកិច្ចរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស**

ដោយអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចដូចជា៖

- រៀបចំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនិតិវិធីទាក់ទងនឹងការសម្រេចលើកិច្ចការសុំកូនអន្តរប្រទេស។
- ធ្វើសហប្រតិបត្តិការ និងសម្របសម្រួលលើការប្រាស្រ័យទាក់ទងគ្នាទៅលើកិច្ចការសុំកូនជាមួយក្រសួង ស្ថាប័ន ឬភ្នាក់ងារដែលពាក់ព័ន្ធ។
- ចាត់វិធានការ និងទប់ស្កាត់ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬផលចំណេញផ្សេងៗទាក់ទងនឹងសុំកូនអន្តរប្រទេស។
- រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការសុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ។
- ពិនិត្យលើសំណើររបស់រដ្ឋបាលសុំកូនអន្តរប្រទេស តាមការចាំបាច់។
- ធ្វើអធិការកិច្ចលើការងារទាំងឡាយដែលពាក់ព័ន្ធជាមួយសុំកូនអន្តរប្រទេស ដោយគ្មានជនណាអាចមករារាំង បង្អាក់ ឬជ្រៀតជ្រែកក្នុងការងារអធិការកិច្ចត្រឹមត្រូវតាមច្បាប់បានឡើយ។
- ចាត់វិធានការដ៍សមស្របក្នុងការប្រមូល រក្សាការពារ និងផ្លាស់ប្តូរពត៌មានអំពីស្ថានភាពកុមារ និងរក្សាទុកពត៌មានទាក់ទងនឹងប្រភពកំណើតរបស់កុមារ អត្តសញ្ញាណកុមារ ឪពុកម្តាយកុមារ និងប្រវត្តិសុខភាពកុមារ។
- រក្សានិងផ្តល់ស្ថិតិទាក់ទងនឹងសុំកូនអន្តរប្រទេសដល់ប្រទេសនានាតាមសំណើរ។
- ទទួលប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាពីអ្នកសុំកូនត្រូវបង់តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេស ឬអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។
- ទទួលខុសត្រូវក្នុងការកត់ត្រា តាមដាន និងធ្វើរបាយការណ៍នូវប្រាក់ចំណាយ សោហ៊ុយ និងវិភាគទានដែលប្រមូលបាន បង់ចូលរតនាគារជាតិ និងចាត់ចែងប្រាក់វិភាគទានមនុស្សធម៌។
- ពិនិត្យ ផ្តល់អនុសាសន៍ និងបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេសនីមួយៗទៅតុលាការ។

- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាយល់ថាចាំបាច់សម្រាប់អនុវត្តកិច្ចការសុំកូនអន្តរប្រទេសដោយអនុលោមទៅតាមច្បាប់ និងបទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា[28]។

**ខ.គណៈកម្មាធិការកណ្តាលសុំកូនអន្តរប្រទេស**

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស[29] ។ ដោយរបៀបរបបនៃការធ្វើការរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសបើកសម័យប្រជុំ ដែលដឹកនាំដោយប្រធានគណៈកម្មាធិការដើម្បីពិនិត្យអោយយោបល់លើករណីសុំកូននីមួយៗ និងពិនិត្យអោយយោបល់ក្នុងការរៀបចំត្រួតពិនិត្យគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីដែលទាក់ទងនឹងសុំកូនអន្តរប្រទេស ហើយការប្រជុំ និង ការសម្រេចរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាលអាចយកជាការបានលុះត្រាតែមានសមាជិកចូលរួមយ៉ាងតិច ៥០%+១ នៃសមាជិកគណៈកម្មាធិការទាំងអស់ ។ការសម្រេចរបស់អង្គប្រជុំទាំងអស់ត្រូវអនុម័តដោយសំឡេងភាគច្រើននៃសមាជិកអង្គប្រជុំ ក្នុងករណីមានសំឡេងស្មើគ្នានោះសំឡេងមានឧត្តមានុភាព ប្រសិនបើផ្អែកលើសារៈសំខាន់នៃបញ្ហានីមួយៗ ប្រធានគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គការ និងជនពាក់ព័ន្ធដទៃទៀតអោយចូលរួមយោបល់បាន។ ការប្រជុំនេះត្រូវប្រជុំមួយខែម្តង ឬញឹកញាប់ជាងនេះទៅតាមការចាំបាច់[30]។

**៣.២ . រដ្ឋបាលសុំកូនអន្តរប្រទេស**

រដ្ឋបាលសុំកូនអន្តរប្រទេស ក៏ជាផ្នែកមួយនៃការអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសផងដែរ ជារួមរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវមានទំនួលខុសត្រូវខ្ពស់ មានចំនេះដឹងនិងជំនាញលើការងារសុំកូននេះ ដើម្បីជួយសម្រួលដល់ដំណើរការនៃសុំកូនអន្តរប្រទេសនេះផងដែរ។

**ក. សមាសភាព និងរចនាសម្ព័ន្ធនៃរដ្ឋបាលសុំកូនអន្តរប្រទេស**

រដ្ឋបាលសុំកូនអន្តរប្រទេស ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ ហើយរដ្ឋបាលសុំកូនអន្តរប្រទេសអាចប្រើប្រាស់ទីប្រឹក្សាតាមការចាំបាច់ផងដែរ[31]។

រដ្ឋបាលសុំកូនអន្តរប្រទេសមានរចនាសម្ព័ន្ធដូចជា៖

[28] មាត្រា៣ នៃប្រកាសរបស់ក្រសួង ស.អ.យ លេខ១៩៤ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣

[29] មាត្រា៤ នៃប្រកាសរបស់ក្រសួង ស.អ.យ លេខ១៩៤ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣

[30] មាត្រា៨ នៃប្រកាសរបស់ក្រសួង ស.អ.យ លេខ១៩៤ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣

[31] ប្រការ៣ ប្រកាសរបស់ក្រសួង ស.អ.យ លេខ១២៣០ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- ការិយាល័យគ្រប់គ្រងទិន្នន័យ និងតម្កល់ឯកសារ
- ការិយាល័យអនុវត្តនីតិវិធីសុំកូនអន្តរប្រទេស
- ការិយាល័យអភិវឌ្ឍគ្រប់គ្រងទីភ្នាក់ងារ និងអធិការកិច្ច
- ការិយាល័យសហប្រតិបត្តិការអន្តរជាតិ[32]។

**ខ.តួនាទី និងភារកិច្ចរបស់រដ្ឋបាលសុំកូនអន្តរប្រទេស**

រដ្ឋបាលសុំកូនអន្តរប្រទេសមានភារកិច្ចដូចជា៖

- រៀបចំ ថែរក្សា និងធ្វើបច្ចុប្បន្នភាពបញ្ជីសម្ងាត់ និងសំណុំឯកសាររបស់កុមារដែលមានលក្ខណៈសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស។
- ធ្វើការប៉ាន់ប្រមាណស្ថានភាពកុមារទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីសម្ងាត់ ដើម្បីកំណត់ទម្រង់នៃការចិញ្ចឹមថែទាំសមស្របបំផុត និងធានាថាកុមារទាំងនោះទទួលបានការចិញ្ចឹមតាមតម្រូវការ។
- ធ្វើការផ្ទៀងផ្ទាត់អំពីការខិតខំប្រឹងប្រែងអោយអស់លទ្ធភាពក្នុងដំណោះស្រាយនៅក្នុងប្រទេសតាមរយៈការថែទាំជាអចិន្ត្រៃយ៍នៅតាមគ្រួសារ ឬជាមួយអ្នកអាណាព្យាបាលមុនដាក់ដំណើរការសុំកូនអន្តរប្រទេស។
- ទទួលពិនិត្យ និងចាត់ការពាក្យសុំ និងឯកសារពាក់ព័ន្ធរបស់អ្នកសុំ។
- ផ្គូរផ្គងកុមារ ដែលមានលក្ខណៈសម្បត្តិសមស្របជាមួយអ្នកសុំ ដែលអាចបំពេញតម្រូវការដ៏ល្អបំផុតសម្រាប់កុមារ ស្របតាមគោលការណ៍នៃឧត្តមប្រយោជន៍របស់កុមារ ។
- ជូនដំណឹងអំពីនីតិវិធីសុំកូន និងការអភិវឌ្ឍនៃករណីសុំកូនទៅអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួល ឬទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីប្រទេសទទួល។
- រៀបចំពិធីប្រគល់កុមារទៅអ្នកសុំនិងរៀបចំឯកសារដើម្បីអោយកុមារធ្វើដំណើរចូលទៅប្រទេសរបស់អ្នកសុំ។
- ផ្តល់ ឬសម្របសម្រួលការផ្តល់សេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារអ្នកសុំនិងគ្រួសារបង្កើតតាមការចាំបាច់។

[32] ប្រការ៤ នៃប្រកាសរបស់ក្រសួង ស.អ.យ លេខ១១២៣០ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤

- ផ្តល់យោបល់ជូនគណៈធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ទាក់ទងនឹងការអនុញ្ញាត ឬដកហូតការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។
- អនុវត្តគោលការណ៍ណែនាំរបស់គណៈធិការអាជ្ញាធរកណ្តាល ដើម្បីធ្វើអធិការកិច្ចលើកិច្ចការសុំកូនអន្តរប្រទេស។
- លើកសំណើសុំការសម្រេចពីគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ដើម្បីចាត់វិធានការព្រមាន ដាក់កំហិត ឬផាកពិន័យចំពោះបុគ្គល ឬអង្គភាពដែលប្រព្រឹត្តល្មើសនឹងច្បាប់សុំកូនអន្តរប្រទេស ព្រមទាំងច្បាប់ដែលទាក់ទងផ្សេងៗ។
- ពិនិត្យឯកសារទាក់ទងនឹងសុំកូនអន្តរប្រទេស និងផ្តល់យោបល់សមស្របជូនប្រធានគណៈកម្មាធិការកណ្តាលសុំកូនអន្តរប្រទេស ដើម្បីពិនិត្យសម្រេច។
- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុរាល់ការប្រជុំរបស់គណៈកម្មាធិការកណ្តាលសុំកូនអន្តរប្រទេស។
- គ្រប់គ្រងថវិកាចំណូលរបស់ រដ្ឋបាលសុំកូនអន្តរប្រទេស រៀបចំធ្វើផែនការចំណាយ និងធ្វើរបាយការណ៍ហិរញ្ញវត្ថុពីការប្រើប្រាស់ថវិកាជារៀងរាល់ខែ ត្រីមាស និងប្រចាំឆ្នាំជូនអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។
- រៀបចំផែនការ កម្មវិធី និងសកម្មភាពបណ្តុះបណ្តាលជំនាញដល់មន្ត្រីធ្វើការងារសុំកូនអន្តរប្រទេស និងអ្នកពាក់ព័ន្ធផ្សេងទៀត។
- ចាត់វិធានការសមស្របក្នុងការប្រមូល ថែរក្សា និងផ្លាស់ប្តូរពត៌មានស្តីពីស្ថានភាពកុមារ ពត៌មានដើមកំណើតកុមារ អត្តសញ្ញាណឪពុកម្តាយ និងប្រវត្តិសុខភាពកុមារ។
- បំពេញភារកិច្ចចាំបាច់ផ្សេងៗទៀតដែលទាក់ទងនឹងសុំកូនអន្តរប្រទេសដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់ គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស[33]។

### ៣.៣. ភ្នាក់ងារសុំកូនអន្តរប្រទេស

រាល់ទីភ្នាក់ងារ ដែលមានបំណងចង់ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និងពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារស្របតាមច្បាប់ស្តីពីសុំកូនអន្តរប្រទេសតែប៉ុណ្ណោះ ទើប

[33] ប្រការ២ ប្រកាសរបស់ក្រសួងស.អ.យ លេខ១២៣០ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤

មានសិទ្ធិធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា[34]។អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់ទីភ្នាក់ងារ ត្រូវចុះកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីកំណត់ចំនួនទីភ្នាក់ងារ ដោយមានចំនួនត្រឹមមួយ ឬ ពីរលើកលែងតែក្នុងករណីចាំបាច់ដើម្បីឧត្តមប្រយោជន៍កុមារអាចអនុញ្ញាតអោយមានលើសពីនេះ[35]។

**ក.លក្ខណៈសម្បត្តិរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស**

ទីភ្នាក់ងារសុំកូនអន្តរប្រទេសត្រូវមានលក្ខណៈមួយចំនួន ដើម្បីសុំការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅកម្ពុជាបានមានដូចជា ត្រូវមានការបញ្ជាក់ទទួលស្គាល់គុណវឌ្ឍន៍ពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់ទីភ្នាក់ងារ ហើយអនុញ្ញាតអោយធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានទិសដៅមិនស្វែងរកផលចំណេញ និងបានបំពេញលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ ជាពិសេសគឺត្រូវមានអ្នកដឹកនាំនិងមានបុគ្គលិកដែលមានសមត្ថភាពប្រកបដោយគុណធម៌ និងសីលធម៌ ក៏ដូចជាបទពិសោធន៍ដែលបានទទួលការបណ្តុះបណ្តាលអំពីច្បាប់ស្តីពីសុំកូនអន្តរប្រទេសរបស់ព្រះរាជាណាចក្រកម្ពុជានិងច្បាប់ពាក់ព័ន្ធផ្សេងទៀតដែលរៀបចំដោយអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស[36]។

**៣.៤. អាជ្ញាធរផ្តល់ការអនុញ្ញាតអោយទីភ្នាក់ងារសុំកូនអន្តរប្រទេស**

គ្រប់ទីភ្នាក់ងារទាំងអស់ដែលមានបំណងចង់មកធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅព្រះរាជាណាចក្រកម្ពុជា ត្រូវតែកំណត់ដោយកិច្ចព្រមព្រៀងរួមគ្នារវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាជាមួយ នឹងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលនោះ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល គឺជាសមត្ថកិច្ចក្នុងការអនុញ្ញាតអោយទីភ្នាក់ងារសុំកូនអន្តរប្រទេសមានសិទ្ធិធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងប្រទេសកម្ពុជា។

---

[34] ប្រការ២ នៃប្រកាសរបស់ក្រសួងស.អ.យ លេខ១៩៨០ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤

[35] ប្រការ៣ នៃប្រកាសរបស់ក្រសួងស.អ.យ លេខ១៩៨០ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤

[36] ប្រការ៤ នៃប្រកាសរបស់ក្រសួងស.អ.យ លេខ១៩៨០ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤

## ផ្នែកទី៤៖ នីតិវិធីសុំកូនអន្តរប្រទេស

ដោយនៅ ក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩ បានបែងចែកនីតិវិធីសុំកូនអន្តរប្រទេស បានបែងចែកនីតិវិធីសុំកូនជា២ផ្នែកធំៗ គឺផ្នែកទី១ស្តីពីនីតិវិធីរដ្ឋបាល និងផ្នែកទី២ស្តីពីនីតិវិធីតុលាការ។

### ៤.១. នីតិវិធីរដ្ឋបាលនៃការសុំកូនអន្តរប្រទេស

#### ក. ការគ្រប់គ្រងសុំនំឯកសាររបស់រដ្ឋបាលសុំកូនអន្តរប្រទេស

នីតិវិធីរដ្ឋបាលសុំកូនអន្តរប្រទេស គឺ ត្រូវរៀបចំសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗដែលមានលក្ខណៈសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសរួមមានពត៌មានចាំបាច់ អំពីអត្តសញ្ញាណរបស់កុមារ ភាពអាចសុំជាកូនចិញ្ចឹម សាវតារជាតិរបស់កុមារ បរិយាកាសសង្គមរបស់កុមារ ប្រវត្តិគ្រួសាររបស់កុមារ ប្រវត្តិសុខភាពកុមារ និងប្រវត្តិសុខភាពគ្រួសាររបស់កុមារ និងសេចក្តីត្រូវការជាពិសេសណាមួយរបស់កុមារជាដើម។

បើក្នុងករណីកុមារត្រូវបានបោះបង់ចោល រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា ការខិតខំប្រឹងប្រែងដើម្បីស្វែងរកឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានធ្វើរួចហើយ។

រដ្ឋបាលសុំកូនអន្តរប្រទេសក៏ត្រូវធានាផងដែរថា រាល់ការយល់ព្រមចាំបាច់ទាំងឡាយ ត្រូវបានធ្វើឡើងស្របទៅតាមច្បាប់ស្តីពីសុំកូនអន្តរប្រទេសនេះ។

សំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារ រាប់បញ្ចូលទាំងភស្តុតាងបង្ហាញពីការយល់ព្រម និងការខិតខំប្រឹងប្រែង ដើម្បីស្វែងរកឪពុកម្តាយ ឬសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារផងដែរ[37]។

#### ខ. ការពិនិត្យពាក្យសុំ

ការពិនិត្យពាក្យសុំរបស់អ្នកសុំកូន គឺពិនិត្យលើឯកសារមួយចំនួនដែលមានដូចជា ភស្តុតាងដែលបញ្ជាក់ថា ប្រទេសដើមរបស់ខ្លួន ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ចាត់ទុកថា អ្នកសុំមានលក្ខណសម្បត្តិ និង មានភាពសមស្របសម្រាប់សុំកូនដោយផ្អែកលើការវាយតម្លៃលើជីវប្រវត្តិផ្ទាល់ខ្លួន ប្រវត្តិគ្រួសារ ប្រវត្តិសុខភាព បរិយាកាសគ្រួសារនិងសង្គម មូលហេតុសុំកូន និងលទ្ធភាពនៃការទទួលបន្ទុករ៉ាប់រងចំពោះសុំកូនអន្តរប្រទេស។

[37] មាត្រា២២ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

មួយវិញទៀតពត៌មានចាំបាច់ទាក់ទងនឹងការឆ្លើយតបនឹងលក្ខខណ្ឌនានាដែលមានចែងនៅក្នុងច្បាប់សុំកូនអន្តរប្រទេសដែលមានទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកសុំដែលក្នុងនោះ រួមមានឯកសារទាក់ទងនឹងអគ្រានុកូលដ្ឋានដែលពត៌មានទាក់ទងនឹងលក្ខណៈផ្សេងៗរបស់កុមារដែលអ្នកសុំអាចនឹងមានលក្ខណសម្បត្តិថែទាំបាន និងមានភស្តុតាងទទួលបានពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលដែលបញ្ជាក់ថា នៅពេលពាក្យសុំរបស់ខ្លួនត្រូវបានយល់ព្រមហើយកូនសុំនោះត្រូវបានអនុញ្ញាតអោយចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសទទួល។

ឯកសារទាំងអស់ត្រូវបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ។ ឯកសារទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ឬភាសាបារាំងដែលមានបញ្ជាក់ត្រឹមត្រូវ[38]។

រាល់ឯកសារទាំងអស់ដែលបានរៀបចំខាងលើត្រូវបញ្ជូនទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិតាមរយៈអាជ្ញាធរកណ្តាល ស្ថានទូត ឬស្ថានតំណាងនៃប្រទេសទទួលប្រចាំនៅកម្ពុជាដែលបានបញ្ជាក់ភាពត្រឹមត្រូវនៃឯកសារនោះ ។ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យផ្តល់យោបល់ និងត្រូវបញ្ជូនឯកសារសុំកូនអន្តរប្រទេសអន្តរប្រទេសទៅក្រសួងទទួលបន្ទុកវិស័យវិស័យសង្គមកិច្ចក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីទទួលពាក្យសុំពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកសុំតាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់អ្នកសុំ ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬតាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ដោយបញ្ជាក់ថា ខ្លួនបានទទួលពាក្យសុំកូន[39]។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចទទួលសំណុំលិខិតសុំកូនដូចបានរៀបរាប់ខាងលើនេះ ។ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ហើយ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវបញ្ជាក់ថាអ្នកសុំបានបំពេញលក្ខខណ្ឌត្រឹមត្រូវតាមច្បាប់នេះហើយ។

ក្នុងករណីដែលសំណុំលិខិតដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេសមិនទាន់គ្រប់គ្រាន់ ឬ មិនទាន់ត្រឹមត្រូវរដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងទៅអ្នកសុំជាលាយលក្ខណ៍អក្សរពីឯកសារដែលនៅខ្វះ ឬមិនទាន់ត្រឹមត្រូវតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវ

[38] មាត្រា ២៣ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

[39] មាត្រា២៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

ពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលឯកសារដែលនៅខ្វះ ឬកែតម្រូវរួច។

ក្នុងករណីបដិសេធពាក្យសុំ ក្រសួងទទួលបន្ទុកសង្គមកិច្ច ត្រូវមានបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ[40]។

**គ. ការផ្គូរផ្គងលក្ខណៈសម្បត្តិរវាងកុមារនិងអ្នកសុំ**

ប្រសិនបើសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ហើយអ្នកសុំបានបំពេញទៅតាមលក្ខខណ្ឌនៃច្បាប់នេះ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យពិចារណាទៅលើសំណុំឯកសាររបស់កុមារទាំងឡាយដែលមានលក្ខណៈសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសបាន និងត្រូវផ្គូរផ្គងពីលក្ខណៈសម្បត្តិរបស់អ្នកសុំណាដែលត្រូវគ្នាល្អបំផុតនឹងលក្ខណៈសម្បត្តិរបស់កុមារ។ ក្នុងការផ្គូរផ្គងដោយគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិចារណាអោយបានសមស្របលើអត្ថប្រយោជន៍នៃការបន្តអោយមានការបីបាច់ ថែរក្សាកុមារដូចពេលមានកន្លងមកព្រមទាំងពិចារណាលើសាវតាសង្គម ជាតិ សាសនា និងវប្បធម៌របស់កុមារ[41]។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវផ្ញើសំណុំឯកសាររបស់កុមារដែលត្រូវបានផ្គូរផ្គងរួមទាំងភស្តុតាងដែលបង្ហាញថា រាល់ការចាំបាច់នានា ត្រូវបានទទួលរួចហើយ និងមូលហេតុដែលខ្លួនកំណត់ទុកដាក់កុមារជាមួយអ្នកសុំនោះទៅអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីពិនិត្យ និងបញ្ជូនទៅអ្នកសុំដោយមិនចាំបាច់ជូនដំណឹងអំពីអត្តសញ្ញាណឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារឡើយ លើកលែងតែករណីសុំកូនដោយសាច់ញាតិ[42]។

- **ការឆ្លើយតបរបស់អ្នកសុំ**

អ្នកសុំត្រូវឆ្លើយតបទៅរដ្ឋបាលសុំកូនអន្តរប្រទេសជាលាយលក្ខណ៍អក្សរ ពីការយល់ព្រមទទួលយកកុមារដែលបានផ្គូរផ្គងអោយតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល។

- ក្នុងករណី អ្នកសុំមិនបានឆ្លើយតបមករដ្ឋបាលសុំកូនអន្តរប្រទេស ក្នុងរយៈពេល ៦០ថ្ងៃ នៃថ្ងៃធ្វើការទេអាចចាត់ទុកបានថាអ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ហើយរដ្ឋបាលសុំកូនអន្តរប្រទេស អាចផ្គូរផ្គងកុមារនោះអោយទៅអ្នកសុំផ្សេងទៀតបាន។ ចំណែកឯប្រាក់

[40] មាត្រា២៦ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

[41] មាត្រា២៧ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

[42] មាត្រា២៨ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

ចំណាយលើសោហ៊ុយ និងវិភាគទានទាក់ទងនឹងការដាក់ពាក្យសុំមិនត្រូវបានបង្វិលអោយវិញឡើយ។

- ក្នុងករណីអ្នកសុំបានឆ្លើយតបថា មិនទទួលយកកុមារដែលផ្តូរផ្តងអោយខ្លួននៅលើកទីមួយទេ អ្នកសុំអាចស្នើសុំរដ្ឋបាលសុំកូនអន្តរប្រទេសផ្តូរផ្តងកុមារលើកទីពីរបាន ប៉ុន្តែមិនអនុញ្ញាតអោយមានលើកទីបីទេ។
- ចំពោះអ្នកសុំដែលមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ ៦០ថ្ងៃ ខាងលើនោះទេអ្នកសុំនោះអាចដាក់ពាក្យសុំកូនសារជាថ្មីបាន ស្របតាមនីតិវិធីនៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសនេះ។ ប៉ុន្តែក្នុងការសម្រេចអំពីការសុំអោយមានការផ្តូរផ្តងសាជាថ្មី ឬការទទួលពាក្យសុំកូនសាជាថ្មីនេះ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិចារណាអំពីមូលហេតុដែលអ្នកសុំខកខានមិនបានឆ្លើយតប ឬឆ្លើយតបថាមិនមានបំណងសុំកុមារដែលបានផ្តូរផ្តងបីលើកមុននាពេលកន្លងមក[43]។

### ➢ ការរៀបចំអោយមានការជួបគ្នារវាងកុមារ និងអ្នកសុំ

បន្ទាប់ពីអ្នកសុំបានបញ្ជាក់ពីការយល់ព្រមរបស់ខ្លួន ហើយអាជ្ញាធរកណ្តាលនៃប្រទេសទទួលបានយល់ព្រមលើការសម្រេចនេះ រដ្ឋបាលសុំកូនអន្តរប្រទេសតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ត្រូវរៀបចំអោយមានការជួបគ្នារវាងអ្នកសុំ និងកុមារដែលត្រូវបានផ្តូរផ្តងរួចហើយ។

ការជួបគ្នានេះ ត្រូវប្រព្រឹត្តទៅតាមកាលបរិច្ឆេទសមស្របសម្រាប់អ្នកសុំ និង រដ្ឋបាលសុំកូនអន្តរប្រទេស និង ត្រូវមានវត្តមានមន្ត្រីសង្គមកិច្ចមានសមត្ថកិច្ចមួយរូបផង។ ការជួបគ្នានេះ ត្រូវធ្វើក្នុងរយៈពេល៦០ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលការយល់ព្រមពីអ្នកសុំ។ ក្នុងករណីអ្នកសុំមិនមកក្នុងរយៈពេលដូចបានកំនត់នេះដោយគ្មានមូលហេតុត្រឹមត្រូវរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន។

មុនពេលជួបគ្នារវាងអ្នកសុំ និង កុមាររដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធ្វើសម្ភាសន៍អ្នកសុំ និងធានាថាអ្នកសុំ និងកុមារត្រូវបានរៀបចំខ្លួនជាស្រេចតាមរយៈការពិគ្រោះយោបល់ផ្លាស់ប្តូរពត៌មាន ការផ្លាស់ប្តូររូបថត និង វិធានការចាំបាច់ផ្សេងទៀតដើម្បីការជួបគ្នានេះ។

ករណីមានសហព័ន្ធបើសហព័ន្ធណាម្ខាងមិនអាចមកបានសហព័ន្ធនោះត្រូវធ្វើលិខិតប្រគល់សិទ្ធិអោយទៅសហព័ន្ធម្ខាងទៀតធ្វើ ជាអ្នកតំណាងរបស់ខ្លួនដើម្បី ធ្វើសកម្មភាពក្នុងការសុំ

[43] មាត្រា២៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

កូននោះ។ លិខិតប្រគល់សិទ្ធិត្រូវមានការបញ្ជាក់ពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទទួល[44]។

➢ **សាកសួរយោបល់កុមារ**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវសាកសួរយោបល់របស់កុមារដែលអាចដឹងខុសត្រូវបាន ព្រមទាំងប្រាប់កុមារអោយដឹងពីអានុភាពដែលអាចកើតចេញពីសុំកូននេះ ហើយត្រូវស្តាប់កុមារបញ្ចេញមតិយោបល់របស់ខ្លួន ដោយគ្មានវត្តមានរបស់ភាគីផ្សេងទៀតឡើយ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវយល់ដឹងអោយច្បាស់អំពីទស្សនៈកុមារលើរាល់បញ្ហាដែលពាក់ព័ន្ធដល់សុំកូន ក្នុងនោះមានជាអាទិ៍ការជ្រើសរើសអ្នកសុំ ហើយមតិយោបល់របស់កុមារត្រូវយកទៅគិតគូរពិចារណាដោយផ្អែកទៅតាមវ័យ និងកម្រិតយល់ដឹងរបស់កុមារ។ សំអាងស្តីពីការយល់ព្រមរបស់កុមារ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីការសម្ភាសន៍ និងការជួបគ្នាខាងលើនេះ។

➢ **ការសម្រេចលើការសុំកូន**

ក្នុងករណី រដ្ឋបាលសុំកូនអន្តរប្រទេសពិនិត្យឃើញថា អ្នកសុំនិងកុមារបំពេញបាននូវលក្ខណវិនិច្ឆ័យ និងលក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស ហើយសុំកូននេះពិតជាបានឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របសើកុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវផ្តល់មតិយោបល់ជាវិជ្ជមានក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីការជួបគ្នារវាងអ្នកសុំ និងកុមារ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវដាក់សំណុំលិខិតទាំងនេះជូន រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំការពិនិត្យ និងផ្តល់អានុសាសន៍លើដំណើរការសុំកូន។

ក្រោយពីទទួលអានុសាសន៍លើដំណើរការសុំកូនពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អ្នកសុំត្រូវសហការជាមួយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដាក់ពាក្យសុំកូនដែលបានផ្ទៀងផ្ទាត់រួចតាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេសទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីសុំដីកាសម្រេចសុំកូន។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវបញ្ជូនពាក្យសុំកូន ទៅសាលាដំបូងរាជធានីភ្នំពេញដោយភ្ជាប់មកជាមួយនូវសំណុំឯកសាររបស់កុមារ និងអ្នកសុំព្រមទាំងអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ក្នុងរយៈពេល ៧ (ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការគិតពីកាលបរិច្ឆេទទទួលពាក្យសុំ។ ឯកសារចាំបាច់ទាំងអស់ត្រូវបកប្រែជាភាសាខ្មែរ និងមានការបញ្ជាក់ពីរដ្ឋបាលសុំកូនអន្តរប្រទេស។

[44] មាត្រា៣០ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

ក្នុងករណីអ្នកសុំមិនបានដាក់ពាក្យសុំក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវចាត់ទុកថាអ្នកសុំនោះបានបញ្ឈប់ពាក្យសុំរបស់ខ្លួន។

### ៤.២. សោហ៊ុយលើការសុំកូន

អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានា សម្រាប់ជួយឧបត្ថម្ភដល់ជំរើសនានានៃការថែទាំជំនួស និងការជួយឧបត្ថម្ភទៅដល់មណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និងកម្រៃសេវាចាំបាច់ផ្សេងៗទៀតទាក់ទង ទៅនឹងសុំកូនអន្តរប្រទេសដែលនឹងកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។ ក្រៅពីនេះមិនត្រូវយកសោហ៊ុយសុំកូនពីអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូន។ មិនអនុញ្ញាតអោយអ្នកសុំកូន ឬទីភ្នាក់ងាររបស់អ្នកសុំកូនបង់ថ្លៃសោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗ ឬទៅតាមសោហ៊ុយសុំកូនមួយៗដែលនឹងត្រូវបញ្ជូនទៅអោយមណ្ឌលកំព្រាណាមួយ ឬមិនអនុញ្ញាតអោយអ្នកសុំកូន ឬទីភ្នាក់ងាររបស់អ្នកសុំកូនធ្វើការផ្តល់សោហ៊ុយ អំណោយ ឬការទូទាត់ ទោះក្នុងរូបភាពណាក៏ដោយទៅអោយមណ្ឌលកុមារកំព្រាដែលកុមារទៅទីនោះត្រូវបានសុំយកទៅចិញ្ចឹម ឬ ទៅអោយបុគ្គលិក នាយក ឬសមាជិកនៃគណៈគ្រប់គ្រងទោះជាដោយផ្ទាល់ ឬដោយប្រយោលក្តី[45]។

ចំណែកឯនៅក្នុងនីតិវិធីតុលាការ អ្នកសុំត្រូវបង់ប្រាក់សរុបចំនួន ១.០០០.០០០ (មួយលាន) រៀល ដើម្បីទ្រទ្រង់សោហ៊ុយដាក់ពាក្យសុំ ការពិនិត្យភស្តុតាង ការចេញដីកាសម្រេច ការបញ្ជូនឯកសារ ការផ្សព្វផ្សាយសេចក្តីជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និងសកម្មភាពខាងនីតិវិធីផ្សេងៗទៀតដែលទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស ។ តុលាការ ត្រូវបង្គាប់អោយអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន។ ក្នុងករណីដែលសោហ៊ុយដែលចាំបាច់ដែលបានកំណត់ខាងលើនេះ លើសពី ១.០០០.០០០ (មួយលាន) រៀល តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម និងបង្គាប់អោយអ្នកសុំបង់សោហ៊ុយបន្ថែមនោះជាមុន ។ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញបានទេ[46]។

### ៤.៣. នីតិវិធីតុលាការ

ដោយដូចចែងនៅក្នុងមាត្រា៣៤ នៃច្បាប់ស្តីពីអន្តរប្រទេសឆ្នាំ២០០៩ បាននិយាយថាមានតែសាលាដំបូងរាជធានីភ្នំពេញ មានយុត្តាធិការទៅលើរឿងក្តីសុំកូនអន្តរប្រទេស ហើយតុលាការត្រូវយកបទប្បញ្ញត្តិស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមកអនុវត្តចំពោះនីតិវិធីតុលាការទាក់ទងនឹងសុំកូនអន្តរប្រទេស លើកលែងតែមានបទប្បញ្ញតិពិសេសដូចមានចែងនៅក្នុង

[45] មាត្រា២៥ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

[46] មាត្រា៣៥ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេសនេះ។ ដោយនីតិវិធីតុលាការមានដូចជា ការពិនិត្យសំណុំឯកសារ ការសម្រេចសេចក្តី របស់តុលាការ និងនីតិវិធីនៃការប្តឹងជំទាស់។

**ក. ការពិនិត្យសំណុំឯកសារ**

ជាគោលការណ៍សំណុំឯកសារ និង របាយការណ៍ដាក់ជូនតុលាការដោយក្រសួងទទួលបន្ទុក វិស័យសង្គមកិច្ច ត្រូវសន្មតជាភស្តុតាងនៃអង្គហេតុពិតទាក់ទងនឹងលក្ខណសម្បត្តិស្មុំកូនអន្តរប្រទេសនិងភាពសមស្របសម្រាប់ស្មុំកូនរបស់អ្នកសុំលើកលែងតែមានភស្តុតាងផ្ទុយមកបញ្ជាក់[47]។

តុលាការត្រូវត្រួតពិនិត្យ ចំពោះឯកសារពាក់ព័ន្ធនឹងស្មុំកូនអន្តរប្រទេសដូចជា ត្រូវមានលក្ខណវិនិច្ឆ័យ ឬ លក្ខខណ្ឌទាំងអស់នៃស្មុំកូនអន្តរប្រទេសត្រូវបានបំពេញ មានការពិគ្រោះយោបល់ជាចាំបាច់មុននឹងផ្តល់ការយល់ព្រមដោយការយល់ព្រមត្រូវបានផ្តល់ដោយគោរពតាមខ្លឹមសារផ្នែកទី២ ជំពូកទី៤ នៃច្បាប់នេះ។ អាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ច ឬទីភ្នាក់ងារស្មុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល មានការពិចារណាត្រឹមត្រូវលើគ្រប់លទ្ធភាពក្នុងការទុកដាក់កុមារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ហើយកុមារនឹងត្រូវបានអនុញ្ញាតអោយចូលទៅរស់នៅជា អចិន្ត្រៃយ៍នៅក្នុងប្រទេសទទួល ជាពិសេសការស្មុំកូនអន្តរប្រទេសនេះពិតជាផ្តល់ឧត្តមប្រយោជន៍ដល់កុមារ[48]។

**ខ.ការសម្រេចសេចក្តីរបស់តុលាការ**

តុលាការសម្រេចរឿងក្តីដែលទាក់ទងនឹងស្មុំកូនអន្តរប្រទេស ដោយពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ។

ករណីមានភាពចាំបាច់ដាច់ខាតត្រូវបំភ្លឺអង្គហេតុពាក់ព័ន្ធ តុលាការអាចអញ្ជើញអ្នកសុំ ឬអ្នកតំណាង ឬអ្នកមានអំណាចមេបាម្ខាង ឬទាំងពីរ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អ្នកតំណាងទីភ្នាក់ងារស្មុំកូនអន្តរប្រទេសពាក់ព័ន្ធ និងសាក្សីផ្សេងទៀតដើម្បីផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ទាក់ទងនឹងអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុ[49]។

តុលាការត្រូវលើកយកសំណុំមកវិនិច្ឆ័យ និងដីកាសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំកូន។តុលាការត្រូវបញ្ជូនដីកាសម្រេចនេះទៅអ្នកសុំ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំ និងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

---

47 មាត្រា៣៦ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេសឆ្នាំ២០០៩

48 មាត្រា៣៧ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេសឆ្នាំ២០០៩

49 មាត្រា៣៨ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេសឆ្នាំ២០០៩

ដីកាសម្រេចនេះ មិនត្រូវចូលជាស្ថាពរនៅមុនផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ដែលបានកំណត់ក្នុងមាត្រា៤០ នៃច្បាប់សុំកូនអន្តរប្រទេស។

ករណីមានការប្តឹងជំទាស់ចំពោះដីកាសម្រេចនេះ ដីកាសម្រេចនេះ មិនត្រូវចូលជាស្ថាពររហូតដល់មានដីកាសម្រេចអំពីបណ្តឹងជំទាស់នេះ[50]។

**គ.នីតិវិធីនៃការប្តឹងជំទាស់**

បុគ្គលដែលមានសិទ្ធិ ឬផលប្រយោជន៍របស់ខ្លួនត្រូវបានបំពានដោយដីកាសម្រេចលើពាក្យសុំកូនអន្តរប្រទេស អាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ចំពោះដីកាសម្រេចនោះបាន។

- ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់ជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលខ្លួនទទួលបានការជូនដំណឹងអំពីដីកាសម្រេចនេះ។
- ក្នុងករណីដែលបុគ្គលប្តឹងជំទាស់ មិនមែនជាជនដែលត្រូវទទួលបានការជូនដំណឹងដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលអ្នកសុំបានទទួលការជូនដំណឹងអំពីដីកាសម្រេច។

ដោយអំឡុងពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ដែលបានកំណត់ខាងលើមិនអាចពន្យារបានឡើយ។សាលាឧទ្ធរណ៍ត្រូវលើកយកពាក្យបណ្តឹងជំទាស់នោះមកវិនិច្ឆ័យ និង ចេញដីកាសម្រេចក្នុងរយៈពេល ៣០ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹងជំទាស់។ ដោយឡែក ដីកាសម្រេចរបស់សាលាឧទ្ធរណ៍លើបណ្តឹងជំទាស់មិនអាចប្តឹងជំទាស់បានឡើយ[51]។

**៤.៤ ចំណាត់ការក្រោយពីបញ្ចប់នីតិវិធីសុំកូនអន្តរប្រទេស**

ក្រោយពីដីកាសម្រេចរបស់តុលាការចូលជាស្ថាពរ នោះក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវជូនដំណឹងទៅក្រសួងការបរទេស និងសហប្រត្តិបត្តិការអន្តរជាតិ អំពីដីកាសម្រេចនេះ។

នៅពេលដែលនីតិវិធីសុំកូនអន្តរប្រទេសត្រូវបានបញ្ចប់ ដោយអនុលោមទៅតាមអនុសញ្ញាទីក្រុងឡាអេស្តីពីការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ។ក្រសួងទទួលបន្ទុក វិស័យសង្គមកិច្ចត្រូវចេញលិខិតបញ្ជាក់ដោយអនុលោមតាមមាត្រា២៣ នៃអនុសញ្ញា[52]

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំពិធីប្រគល់កុមារ និងលិខិតបញ្ជាក់ស្តីពីការប្រគល់កូនជាផ្លូវការទៅអ្នកសុំ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវជួយសម្របសម្រួលជាមួយអាជ្ញាធរមាន

---

[50] មាត្រា៣៩ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

[51] មាត្រា៤០ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

[52] អនុសញ្ញាទីក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការសុំកូនអន្តរប្រទេស ១៩៩៣

សមត្ថកិច្ច ក្នុងការរៀបចំ និងផ្តល់នូវលិខិតឆ្លងដែន ទិដ្ឋការ និងឯកសារចាំបាច់នានា ដើម្បីអោយកុមារធ្វើដំណើរចូលទៅប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ។ការធ្វើដំណើររបស់កុមារ ត្រូវអមដំណើរដោយអ្នកសុំ ដោយរដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធានាថាការផ្ទេរកុមារទៅកាន់ប្រទេសទទួលប្រព្រឹត្តទៅក្នុងកាលៈទេសៈមានសុវត្ថិភាព ដោយមានការគិតគូរ ដល់សេចក្តីត្រូវការនានារបស់កុមារ[53]។

ក្រោយពីកុមារត្រូវបានទទួលការអនុញ្ញាតអោយធ្វើជាកូន ឪពុកម្តាយចិញ្ចឹមត្រូវផ្តល់របាយការណ៍អំពីស្ថានភាពវិវឌ្ឍន៍របស់កុមារមករដ្ឋបាលសុំកូនអន្តរប្រទេសជារៀងរាល់ ៦ខែម្តង ក្នុងរយៈពេល ៣ឆ្នាំ បន្ទាប់មកត្រូវផ្តល់របាយការណ៍ ១ឆ្នាំម្តង រហូតដល់កុមារអាយុ ១៨ឆ្នាំ។ ឪពុកម្តាយចិញ្ចឹមត្រូវផ្ញើរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលសុំកូនដោយផ្ទាល់ ឬ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ឬប្រទេសជាលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួនទៅតាមស្ថានភាពសមស្រប[54]។

**៤.៥ ការទុកដាក់សំណុំឯកសារសុំកូន**

រដ្ឋបាលសុំកូនអន្តរប្រទេស និងសាលាដំបូងរាជធានីភ្នំពេញ ត្រូវរក្សាទុកសំណុំឯកសារសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ (ហុកសិប) ឆ្នាំ គិតពីកាលបរិច្ឆេទដែលដីកាសម្រេចសុំកូនអន្តរប្រទេសនោះចូលជាស្ថាពរ។ សំណុំឯកសារ និងកំណត់ហេតុទាំងអស់ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ទោះជារក្សាទុកនៅតុលាការ រដ្ឋបាលសុំកូនអន្តរប្រទេស ទីភ្នាក់ងារសុំកូនអន្តរប្រទេស មណ្ឌលកុមារកំព្រា និងអ្នកជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេសត្រូវរក្សាទុកជាសម្ងាត់។ ក៏ប៉ុន្តែសំណុំឯកសារ និងកំណត់ហេតុទាំងនោះអាចនឹងត្រូវបញ្ចេញទៅតាមការស្នើសុំ ឬការបង្គាប់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរមានសមត្ថកិច្ច នៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីមានតម្រូវការទាក់ទងនឹងករណី ឬនីតិវិធីតុលាការដែលកំពុងតែប្រព្រឹត្តទៅ ឬ កាលទេសៈពិសេសដទៃទៀត[55]។

[53] មាត្រា៩៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

[54] មាត្រា៩៥ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

[55] មាត្រា៩៦ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

### ៤.៦. ការអនុញ្ញាតអោយកូនសុំមើលលិខិតស្មុំកូន

ឪពុកម្តាយចិញ្ចឹម អាចដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំច្បាប់ចម្លងនៃសំណុំលិខិត ដែលរួមមានអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតរបស់កូនសុំ ក្រោយពីដីកាសម្រេចស្មុំកូនរបស់តុលាការចូលជាស្ថាពរ។ កូនសុំដែលដល់អាយុដឹងខុសត្រូវគ្រប់គ្រាន់អំពីផលវិបាកនៃការដឹងអត្តសញ្ញាណរបស់ខ្លួន អាចត្រូវបានអនុញ្ញាតអោយមើលលិខិតរបស់ខ្លួនរួមទាំងអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតបាន ដោយធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីការមើលនេះជាឧត្តមប្រយោជន៍របស់កូនសុំ។ កូនសុំដែលឈានចូលអាយុនីតិភាពមានសិទ្ធិមើលសំណុំឯកសារ និង កំណត់ហេតុទាក់ទងនឹងអត្តសញ្ញាណខ្លួន។ រដ្ឋបាលស្មុំកូនអន្តរប្រទេសត្រូវធានាថា កូនសុំទទួលបានការពិគ្រោះយោបល់សមស្របមុននឹងមើលពត៌មាននៅក្នុងសំណុំលិខិតរបស់ខ្លួន។

### ៤.៧. ទណ្ឌកម្ម

ដោយច្បាប់ស្មុំកូនអន្តរប្រទេសនេះ ត្រូវបានបង្កើតឡើងមិនត្រឹមតែកំណត់ពីគោលការណ៍លក្ខខណ្ឌ នីតិវិធីទម្រង់បែបបទ និងអានុភាពស្មុំកូនអន្តរប្រទេសតែប៉ុណ្ណោះទេ ប៉ុន្តែច្បាប់នេះព្រមទាំងបានកំណត់ អំពីការផ្តន្ទាទោសដល់អ្នកដែលពាក់ព័ន្ធទៅនឹងច្បាប់ស្មុំកូនអន្តរប្រទេសនេះដែលមានកំហុសណាមួយកើតឡើង ដែលត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ និងច្បាប់បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា គឺដើម្បីថែរក្សានូវសន្តិសុខ សណ្តាប់ធ្នាប់នៅក្នុងសង្គម ជាពិសេសគឺចង់ការពារដល់ឧត្តមប្រយោជន៍នៃកុមារដែលត្រូវបានស្មុំអោយខានតែបាន។ ដោយនៅគ្រប់ករណីនៃបទល្មើសទាំងឡាយនឹងទទួលរងនូវទោសព្រហ្មទណ្ឌ(ទោសដាក់ពន្ធនាគារ) ឬទោសរដ្ឋប្បវេណី(ទោសពិន័យជាប្រាក់) ឬ អាចទាំងទោសព្រហ្មទណ្ឌនិងទោសរដ្ឋប្បវេណី ក៏ដូចជាសំណងរដ្ឋប្បវេណីផងដែរ និងការប្រកាសនូវទោសផ្សេងៗទៀត គឺស្ថិតទៅតាមស្ថានទម្ងន់ទោសរបស់ជនល្មើស។

ដោយមិនទាន់គិតដល់ទោសប្បញ្ញត្តិ ដែលមានចែងនៅក្នុងច្បាប់ជាធរមាន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចព្យួរ ឬដកហូតការទទួលស្គាល់ ឬបដិសេធការទទួលស្គាល់ ទីភ្នាក់ងារស្មុំកូនអន្តរប្រទេសសាជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញអោយឃើញថា ទីភ្នាក់ងារស្មុំកូនអន្តរប្រទេសជាប់ពាក់ព័ន្ធនឹងអំពើណាមួយដូចតទៅ៖

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ឬ ញុះញង់ដោយផ្ទាល់អោយឪពុកម្តាយ ឬឪពុក ឬម្តាយបោះបង់ទារកដែលកើតមកហើយ ឬដែលនឹងកើត ដើម្បីអោយប្រគល់កូនតាមរយៈស្មុំកូនអន្តរប្រទេស។

- អំពើប្រព្រឹត្តស្ថិតនៅក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ឪពុកម្តាយ ឬឪពុក ឬម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬដែលទើបនឹងកើត។
- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅអោយអ្នកសុំ។
- អំពើក្លែងបន្លំ ឬសមគំនិតក្លែងបន្លំស្ថានភាពលំបាកបំផុត ដើម្បីទទួលបានការយល់ព្រមពីឪពុកម្តាយបង្កើត ឬឪពុកបង្កើត ឬម្តាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។
- អំពើរៀបចំអោយមានការយល់ព្រមរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារដោយការបង្ខិតបង្ខំ ការគំរាមកំហែង ការឆបោក ឬការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬសន្យាផ្តល់ប្រាក់រង្វាន់សំណង ឬផលប្រយោជន៍ណាមួយ។
- ការបញ្ចេញសំណុំឯកសារ និងកំណត់ហេតុទាំងអស់ ឬ មួយផ្នែកទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ដោយគ្មានការអនុញ្ញាតពី ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ឬតុលាការមានសមត្ថកិច្ច។
- ការបង្គាប់ ឬ ការទទួលដោយផ្ទាល់ ឬដោយប្រយោលនូវថ្នូរប្រាក់កាសទំនិញ ឬសេវាដោះដូរនឹងការបម្រុងទុកកុមារណាមួយសម្រាប់សុំកូន។
- ការផ្តល់ប្រាក់កាស ទំនិញ ឬសេវាទៅអោយមន្ត្រី ឬអ្នកតំណាងណាមួយនៃរដ្ឋបាលសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាជ្ញាធរកណ្តាលទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ឬមន្ត្រីពាក់ព័ន្ធផ្សេងទៀត ដើម្បីអោយផ្តល់នូវសិទ្ធិជាអាទិ៍ភាពនៅក្នុងនីតិវិធីសុំកូនអន្តរប្រទេសដល់អ្នកសុំ។
- ការផ្សាយពាណិជ្ជកម្ម ឬការបោះពុម្ពផ្សាយនូវអត្តសញ្ញាណ ឬរូបថតរបស់កុមារណាមួយដែលកម្មវត្ថុសុំកូន ក្នុងគោលបំនងបញ្ចុះបញ្ចូលបុគ្គលណាមួយអោយដាក់ពាក្យសុំកូន។
- ការតែងតាំង ឬចាត់តាំងអ្នកតំណាងណាមួយដោយមិនមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

- ការចូលរួមក្នុងការរៀបចំការផ្គូរផ្គងឬការទាក់ទងគ្នារវាងអ្នកសុំនិងឪពុកម្ដាយបង្កើត ឬឪពុកបង្កើត ឬម្ដាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារក្នុងគោលបំនងកំណត់ទុកជាមុននូវកុមារណាមួយដែលនឹងត្រូវសុំ។
- ការរំលោភបំពានដល់បទប្បញ្ញត្តិនៃច្បាប់នេះ បទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារ និងបទប្បញ្ញត្តិផ្សេងទៀតជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា[56]។

ដូចបានកំណត់នៅក្នុងមាត្រា៤៧ នៃច្បាប់ស្ដីពីសុំកូនអន្តរប្រទេស ដោយទីភ្នាក់ងារដែលបានធ្វើប្រតិបត្តិការដំណើរការសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែទទួលបានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និង ស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួលថែមទាំងមិនមានបំនងនៅក្នុងការស្វែងរកប្រាក់ចំណេញនៅក្នុងគោលដៅអវិជ្ជមានទាំងឡាយ ជាពិសេសមានគោលដៅរួមមួយគឺដើម្បីឧត្តមប្រយោជន៍នៃកុមារដែលត្រូវបានសុំនោះ ប៉ុន្តែប្រសិនបើមិនអនុវត្តតាមដូចដែលមានចែងនៅក្នុងច្បាប់នេះនឹងត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១.០០០.០០០ (មួយលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។ ការដាក់ពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។ ប្រាក់ពិន័យអន្តរការណ៍ត្រូវបង់ចូលទៅក្នុងមូលនិធីសម្រាប់ទ្រទ្រង់វិស័យសុខុមាលភាពកុមារ។ ប្រសិនក្នុងករណី ទីភ្នាក់ងារមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍នេះទេក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចបញ្ជូនសំណុំរឿងនេះទៅតុលាការ[57]។

ម៉្យាងវិញទៀត ដូចនៅក្នុងច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងនូវមាត្រាមួយចំនួនអំពីការនាំចេញដោយមិនស្របច្បាប់ គឺការនាំយកអនីតិជន ឬជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬនៅក្រោមហិតូបត្ថម្ភ ឬនៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ដោយគ្មានអំណាចតាមផ្លូវច្បាប់ ឬយុត្តិកម្មតាមផ្លូវច្បាប់ ចេញពីការគ្រប់គ្រងស្របច្បាប់នៃឪពុកម្ដាយ អ្នកថែរក្សា ឬអ្នកអាណាព្យាបាលរបស់គេ នឹងត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំ ដល់ ៥ (ប្រាំ)ឆ្នាំ[58]។

ក្នុងករណីជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅស្វែងរកប្រយោជន៍ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្សេងទៀត ត្រូវផ្ដន្ទាទោសដាក់

[56] មាត្រា៥៤ នៃច្បាប់ស្ដីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

[57] មាត្រា៥៥ នៃច្បាប់ស្ដីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩

[58] មាត្រា៨ និងមាត្រា៩ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

ពន្ធនាគារពី ៧ (ប្រាំពីរ)ឆ្នាំ ដល់ ១៥ (ដប់ប្រាំ)ឆ្នាំ។ ប៉ុន្តែក្នុងករណីដែលជនរងគ្រោះជាអនីតិជន ហើយប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ និងអំពើល្មើសប្រព្រឹត្តឡើងដោយក្រុមមានការចាត់តាំង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ)ឆ្នាំ ដល់ ២០ (ម្ភៃ)ឆ្នាំ[59]។

**ផ្នែកទី៥ ៖ គុណប្រយោជន៍នៃការសុំកូនអន្តរប្រទេស**

សុំកូនអន្តរប្រទេសបានផ្តល់សារៈសំខាន់ច្រើនលើសលប់ដល់ទារកក៏ដូចជាកុមារកំព្រា ដើម្បីបាននូវគ្រួសារមានសុភមង្គល មានសេចក្តីស្រលាញ់ ការផ្គត់ផ្គង់យ៉ាងពេញលេញ ការយកចិត្តទុកដាក់ថែរក្សា ទទួលបានការអប់រំនឹងមានអនាគតល្អមួយ ចាកចេញពីភាពលំបាកដែលកុមារជាច្រើនមិនត្រូវការ ជាពិសេសកូនសុំនឹងទទួលបានសិទ្ធិ និងករណីកិច្ចដូចកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមដែរ រីឯអំណាចមេបាក៏ត្រូវប្រគល់អោយឪពុកម្តាយចិញ្ចឹមផងដែរ ទើបធ្វើអោយគ្រួសារមួយមានបន្ថែមនូវសមាជិកថ្មីដែលអាចផ្តល់នូវលក្ខខណ្ឌជីវភាពគ្រួសារថ្មី ឬទទួលបានកូនដែលគេប្រាថ្នាចង់បានប៉ុន្តែមិនអាចធ្វើបានព្រោះតែបញ្ហាមួយចំនួន ដូច្នេះការសុំកូននេះហើយដែលអាចជួយអោយពួកគេទទួលបាននូវគ្រួសារដែលពេញលក្ខណៈមួយ គឺមានឪពុកម្តាយ និងកូនពោរពេញទៅដោយសុភមង្គល និងការស្រលាញ់ពេញចិត្តទៅវិញទៅមក។

[59] មាត្រា១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើនេះរួចមក សង្កេតឃើញថា ការសុំកូនពិតជាមានសារៈសំខាន់នៅក្នុងសង្គមនីមួយៗ ដោយយើងអាចនិយាយបានថា ការបង្កើតអោយមានដំណើរការសុំកូនគឺដើម្បីមនុស្សធម៌ ដើម្បីការពារនូវផលប្រយោជន៍របស់ទារកនិងកុមារដែលត្រូវការការមើលថែទាំពីមនុស្សនៅជុំវិញខ្លួនរបស់ពួកគេនៅក្នុងជីវភាពប្រចាំថ្ងៃ ដូច្នេះហើយទើបរាជរដ្ឋាភិបាលបង្កើតអោយមាន ច្បាប់គតិយុត្តិផ្សេងៗ ដោយសហការជាមួយក្រសួង ឫទីភ្នាក់ងារដែលពាក់ព័ន្ធនៅក្នុងដំណើរការនេះ អោយមានគុណភាព និងលទ្ធផលល្អជាទីគាប់ប្រសើរ។

ដោយយើងសង្កេតឃើញថា សុំកូនក្នុងព្រះរាជាណាចក្រកម្ពុជាដែលយោងទៅតាមក្រមរដ្ឋប្បវេណីពុំសូវមានភាពស្មុគស្មាញប៉ុន្មាន ពោលគឺទាំងសុំកូនធម្មតា និងពេញលេញកូនដែលត្រូវគេសុំសុទ្ធតែបានរស់នៅប្រទេសកំណើតរបស់ខ្លួនដដែល គ្រាន់តែស្ថិតនៅក្រោមអំណាចមេបានៃឪពុកម្តាយចិញ្ចឹម ទទួលបាននូវការយកចិត្តទុកដាក់នៅក្នុងមជ្ឈដ្ឋាននៃគ្រួសារថ្មីដែលអាចផ្តល់នូវសុភមង្គលពេញបរិបូរណ៍។ ប៉ុន្តែបើយើងងាកមកមើល សុំកូនអន្តរប្រទេសវិញ គឺមានភាពតឹងរឹងបន្តិចទាំងនីតិវិធីរាល់ដំណើរការតាំងពីចាប់ផ្តើមរហូតដល់ចូលជាស្ថាពរ បទដ្ឋានគតិយុត្តិ របាយការណ៍ និងមន្ត្រីដែលពាក់ព័ន្ធនានសុទ្ធតែមានបញ្ហាចោទ ពីព្រោះកូនសុំត្រូវបានចាកចេញពីប្រទេសកំនើតរបស់ខ្លួនទៅប្រទេសរបស់អ្នកសុំ ដែលត្រូវចាំបាច់មានការទទួលស្គាល់ពីប្រទេសអ្នកទទួលផងដែរ ដើម្បីជៀសវាងនូវបញ្ហាផ្សេងៗដែលអាចប៉ះពាល់ដល់សុវត្ថិភាព និងអនាគតរបស់កុមារ ជាពិសេសការជួញដូរកុមារ ល។ ប្រទេសកំណើតរបស់កូនសុំ និង ប្រទេសរបស់អ្នកសុំចាំបាច់ត្រូវមានការទុកចិត្តគ្នាទៅវិញទៅមកថា មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការបំពេញតាមកាតព្វកិច្ចរៀងៗខ្លួន។ ប្រទេសកំណើតរបស់កូនសុំត្រូវតែមានច្បាប់នីតិវិធី និងស្ថាប័នគ្រប់គ្រាន់ដើម្បីត្រួតពិនិត្យមើលលក្ខខណ្ឌ ដែលទាក់ទងនឹងកូនសុំ ដើម្បីឲ្យដឹងប្រាកដច្បាស់ថា កុមារពិតជាក្មេងកំព្រា ឬជាក្មេងដែលស្ថិតក្នុងស្ថានភាពលំបាក ដែលគួរដាក់ជាកូនសុំ។ ចំណែកប្រទេសកំណើតរបស់អ្នកសុំវិញត្រូវតែមានច្បាប់ នីតិវិធី និងស្ថាប័នគ្រប់គ្រាន់ ដើម្បីត្រួតពិនិត្យមើលលក្ខខណ្ឌ ដែលទាក់ទងនឹងអ្នកសុំ ដើម្បីឲ្យប្រាកដថា គ្រួសារថ្មីនេះអាចផ្តល់ការថែទាំសមស្របដល់កូនសុំ។

កាលពីដំបូង គឺមានអនុក្រឹត្យឆ្នាំ២០០១ "ស្តីពីការសុំទារកកំព្រា ឬកុមារកំព្រាទៅចិញ្ចឹមនៅបរទេស"។ ក្រោយមកនៅឆ្នាំ២០០៧ កម្ពុជាបានផ្តល់សច្ចាប័ន លើ "អនុសញ្ញាស្តីពីការការពារកុមារនិងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស" (អនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៩៣) ហើយនៅឆ្នាំ២០០៩ រដ្ឋសភាកម្ពុជាក៏បានអនុម័តច្បាប់មួយទៀត គឺ "ច្បាប់ស្តីពីសុំកូនអន្តរប្រទេស" ដើម្បី

រៀបចំបទដ្ឋានឲ្យត្រូវទៅតាមអនុសញ្ញាក្រុងឡាអេនេះ ។ ក៏ប៉ុន្តែ តាំងពីត្រូវអនុម័តមក ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩នេះ មិនទាន់ត្រូវបានរដ្ឋាភិបាលកម្ពុជាចាប់ផ្តើមអនុវត្តនៅឡើយទេ ដោយសារតែត្រូវចាំរៀបចំនីតិវិធី បែបបទលម្អិតក្នុងការអនុវត្ត ហើយជាពិសេស គឺក្រសួងសង្គមកិច្ច ដែលជា "អាជ្ញាធរកណ្តាលសុំកូនអន្តរជាតិ" ត្រូវរៀបចំបង្កើតជារដ្ឋបាលសុំកូនអន្តរជាតិ ដែលត្រូវជាសេនាធិការទទួល និងពិនិត្យពាក្យសុំកូនអន្តរប្រទេស រហូតដល់ដើមឆ្នាំ២០១៣ រាជរដ្ឋាភិបាលបានប្រកាសនឹងចាប់ផ្តើមបើកអោយមានការសុំកូនយកទៅចិញ្ចឹមនៅបរទេសឡើងវិញ។

ទោះបីនៅក្នុងនីតិវិធីនៃដំណើរការសុំកូនបានបញ្ចប់ក៏ពិតមែន ក៏ប៉ុន្តែកូនសុំត្រូវតែធានានូវសុវត្ថិភាព ទទួលបានសិទ្ធិ និងករណីកិច្ចដូចគ្នានឹងកូនបង្កើតនៃគ្រួសារផងដែរ គឺត្រូវទទួលបាននូវការមើលថែ ទាំងកាយនិងចិត្ត ការស្រលាញ់ ភាពទទួលខុសត្រូវក្នុងនាមជាឪពុកម្តាយដែលច្បាប់ទទួលស្គាល់ ទទួលបានការអប់រំសិក្សារៀនសូត្រដើម្បីអនាគតរបស់ពួកគេដូចកុមារដទៃផងដែរ។ ជាពិសេស គឺមិនមែនការរើសអើងពីមជ្ឈដ្ឋានខាងក្រៅថាជាកូនចិញ្ចឹម។

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវសារណាដែលនិយាយពីប្រធានបទ« ស្មុំកូន » នេះរួច នាងខ្ញុំសង្កេតឃើញថា ការស្មុំកូននៅក្នុងប្រទេសមិនសូវមានបញ្ហាដែលគួរអោយបារម្ភនោះទេ ក៏ប៉ុន្តែចំពោះបញ្ហាស្មុំកូនអន្តរប្រទេសនៅមានភាពស្មុគស្មាញនៅឡើយ គឺត្រង់ថាការអនុវត្តនៃដំណើរការគឺត្រូវការមានការចូលរួមពីភាគីប្រទេសនៃអ្នកសុំ ហើយការរៀបចំ និងគ្រប់គ្រងនៃនីតិវិធីនៅមិនទាន់មានលក្ខណៈជាអន្តរជាតិ។ ម៉្យាងវិញទៀត ស្ថាប័នដែលពាក់ព័ន្ធគួរតែផ្សព្វផ្សាយផ្តល់ចែករំលែកនូវការយល់ដឹងអោយកាន់តែទូលំទូលាយដល់ប្រជាជនអំពីនីតិវិធីនៃស្មុំកូន ក៏ដូចជាសារៈសំខាន់នៃការស្មុំកូនដែលទទួលស្គាល់ដោយច្បាប់ត្រឹមត្រូវ ចៀសវាងនៃការជួញដូរកុមារ និងការរំលោភបំពានដល់សិទ្ធិ និង ឧត្តមប្រយោជន៍នៃកុមារដែលកំពុងមានភាពលំបាកអោយកាន់តែលំបាកជាងមុនទៅទៀត។

បន្ថែមពីនេះទៅទៀត ទាំងទារក និង កុមារសុទ្ធតែត្រូវការនូវការមើលថែទាំយ៉ាងយកចិត្តទុកដាក់ពីក្រុមគ្រួសារ និងរស់នៅក្នុងមជ្ឈដ្ឋានដែលមានសេចក្តីស្រលាញ់ដោយពេញចិត្ត មិនមានការបង្ខិតបង្ខំពីបុគ្គលណាម្នាក់ រស់នៅដោយមានសុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្ត ដូច្នេះហើយទើបបង្កើតអោយមានដំណើរការនៃស្មុំកូនទាំងក្នុងប្រទេស និង នីតិវិធីស្មុំកូនអន្តរជាតិដែលមានច្បាប់ស្មុំកូនអន្តរប្រទេសជាគោល។

ទន្ទឹមនឹងនេះ ការស្មុំកូននៅក្នុងប្រទេស និងអន្តរប្រទេស គឺសុទ្ធសឹងតែមានតួនាទីលើកស្ទួយដល់ឧត្តមប្រយោជន៍របស់កុមារ ជាពិសេសកុមារដែលត្រូវការការមើលថែជាពិសេស ការបង្កើតអោយមានដំណើរការនេះឡើយគឺ មានផលប្រយោជន៍ទាំងកុមារដែលត្រូវគេសុំ និង អ្នកសុំក៏ដូចជាភាគីរដ្ឋផងដែរទាំងនេះហើយដែលជាចំនែកនៃការអភិវឌ្ឍន៍ធនធានមនុស្សសំរាប់បំរើប្រទេសជាតិនៅថ្ងៃខាងអនាគត។

# ឯកសារយោង


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ១៩៩៣។
- ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩។
- ក្រមរដ្ឋប្បវេណី, លេខ នស /រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ, លេខ នស/រកម/ ០២០៨/ ០០៥, ១៨ មករា ២០០៨។
- ច្បាប់ស្តីពីការអនុម័តយល់ព្រមអោយព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារនិងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស, លេខ នស/រកម/០១០៧/០០៣, ២៥ ធ្នូ ២០០៧។
- ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, លេខ នស/រកម/១២០៩/០២៤, ០៣ ធ្នូ ២០០៩។
- អនុសញ្ញាទីក្រុងឡាអេស្តីពីការការពារកុមារនិងសហប្រត្តិការសុំកូនអន្តរប្រទេស,ឆ្នាំ ១៩៩៣។
- អនុក្រឹត្យ ស្តីពីការសុំទារកកំព្រា រឺកុមារកំព្រាយកទៅចិញ្ចឹមជាកូននៅបរទេស, លេខ២៩ អនក្រ.បក ឆ្នាំ២០០១ ។
- ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស, លេខ១២៣០ របស់ក្រសួង ស.អ.យ, ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤។
- ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា, លេខ ១៩៤ របស់ក្រសួង ស.អ.យ, ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ២០១៣។
- ប្រកាសស្តីពីនីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស, លេខ ១៩៨០, ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៤។
- ខន សុខេង. ២០១៨. *ការសុំកូន*។
- សារណាបញ្ចប់ការសិក្សាឆ្នាំ២០១៥. (សុំកូន)
- រ៉ៃ ភីរក្ស និង ស៊ិន ផល្លុន. (២០១៧). *វគ្គបណ្តុះបណ្តាលពិសេស ប្រធានបទ សុំកូន*. ដកស្រង់ពីwww.youtube.com ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៩។

**មាត្រា ១០០៦.-** អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

ការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយឡើយ ។

## ផ្នែកទី ២

## សុំកូន

### កថាភាគទី ១

### សុំកូនពេញលេញ

**មាត្រា ១០០៧.-** ទម្រង់នៃការបង្កើតសុំកូនពេញលេញ

បើយល់ឃើញថា មានល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្ដីប្រពន្ធ) ដល់មាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ) ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្ដាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមបាន ។

**មាត្រា ១០០៨.-** សុំកូនដោយសហការរវាងប្ដីប្រពន្ធ

១-បុគ្គលដែលក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ។

២-ប្ដី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនក្លាយជាម្ដាយ ឬ ឪពុកចិញ្ចឹម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្ដីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹម របស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

**មាត្រា ១០០៩.-** អាយុរបស់ឪពុកម្ដាយចិញ្ចឹម

ឪពុកម្ដាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ ហើយត្រូវមាន...

អនុវត្តឡើយ ចំពោះញាតិភាពជាមួយនឹងឪពុកម្តាយម្ខាងទៀត និង ញាតិលោហិតរបស់ឪពុកម្តាយម្ខាងទៀតនោះ ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) នៃក្រមនេះ ។

**មាត្រា ១០១៥.-** អានុភាពនៃសុំកូនពេញលេញ

១-ដោយបង្កើតសុំកូនពេញលេញ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម និង ត្រូវទទួលបាននូវសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹម ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-កូនសុំ ត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម របស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ ម្តាយបង្កើត និង ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម ។

**មាត្រា ១០១៦.-** ការកាត់កាល់នៃសុំកូនពេញលេញ

១-បើយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនសុំ តុលាការអាចកាត់កាល់ភាគីនៃសុំកូនបាន តាមពាក្យសុំរបស់កូនសុំ ឪពុកម្តាយបង្កើត ឬ តំណាងអយ្យការ លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចទាំងអស់ ដែលកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-បើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ។

ខ-បើឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ ។

២-ការកាត់កាល់ ពុំអាចធ្វើបានឡើយ ក្រៅពីយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

មេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ ។

**មាត្រា ១០២១.-** ករណីដែលបុគ្គលដែលនឹងក្លាយជាឪពុកឬម្ដាយចិញ្ចឹម មានសហព័ទ្ធ

បើបុគ្គលដែលមានសហព័ទ្ធ សុំកូនដែលជាអនីតិជន បុគ្គលនោះត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលយកកូនរបស់សហព័ទ្ធ មកធ្វើជាកូនសុំ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

**មាត្រា ១០២២.-** ការយល់ព្រមរបស់សហព័ទ្ធ

ចំពោះបុគ្គលដែលមានសហព័ទ្ធ ដើម្បីដាក់ពាក្យសុំនៃសុំកូនធម្មតា ត្រូវទទួលការយល់ព្រមពីសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

**មាត្រា ១០២៣.-** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនធម្មតា

១-តុលាការ អាចឱ្យបង្កើតសុំកូនបាន លុះត្រាតែករណីដែលអាចបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន ។

២-តុលាការមិនត្រូវឱ្យបង្កើតសុំកូនឡើយ បើយល់ឃើញថា សុំកូនត្រូវបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍ រវាងភេទផ្សេងគ្នា ឬ ភេទដូចគ្នា ឬ ក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត ។

**មាត្រា ១០២៤.-** ករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន

១-បើបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន តុលាការអាចឱ្យបង្កើតសុំកូនបាន លុះត្រាតែយល់ឃើញថា មានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់អនីតិជន

អាហារកាតព្វកិច្ច ។

✓មាត្រា ១០២៧.– អានុភាពនៃសុំកូន ក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹម ជាអាទិ៍

១-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១០១៥ (អានុភាពនៃសុំកូនពេញលេញ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសុំកូនធម្មតា ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-ក្នុងករណីដែលកូនសុំជាអនីតិជន កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលយកកូនបង្កើតរបស់សហព័ទ្ធ មកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្ដាយចិញ្ចឹម និង សហព័ទ្ធនោះ ។

មាត្រា ១០២៨.– ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា

១-ភាគីនៃសុំកូន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យកាត់កាល់សុំកូនបាន ក្នុងករណីដែលភាគីសងខាងព្រមព្រៀងអំពីការកាត់កាល់នោះ ។

២-ក្នុងករណីដែលកូនសុំជាអនីតិជន ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើង ដោយឪពុកម្ដាយចិញ្ចឹម និង បុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ ក្រោយពេលកាត់កាល់ ។ ប៉ុន្តែ បើកូនសុំដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ហើយ ត្រូវទទួលការយល់ព្រមពីកូនសុំនោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើឪពុកម្ដាយបង្កើតរបស់កូនសុំ បានលែងលះគ្នាហើយ ឪពុកម្ដាយបង្កើតរបស់កូនសុំនោះ ត្រូវពិភាក្សា និង កំណត់ថា ឪពុក ឬ ម្ដាយបង្កើត ជាបុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបានៅក្រោយពេលកាត់កាល់ ។

២-ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្ដាយចិញ្ចឹម មិនអាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះកូនសុំបានឡើយ ។

៣-បើកូនសុំជាអនីតិជន បញ្ញត្តិចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនសុំដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះឪពុកម្ដាយចិញ្ចឹម ។

**មាត្រា ១០៣២.-** អានុភាពនៃការកាត់កាល់សុំកូនធម្មតា

១-អានុភាពទាំងឡាយនៃសុំកូនធម្មតា ត្រូវបញ្ចប់ឆ្ពោះទៅអនាគត ដោយការកាត់កាល់ ។

២-ក្រោយការកាត់កាល់ កូនសុំអាចទទួលវិញ នូវនាមត្រកូលមុនសុំកូនក៏បាន ឬអាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមក៏បាន ។

**មាត្រា ១០៣៣.-** ការចុះបញ្ជីនៃសុំកូនធម្មតា និង បញ្ជីកំណើត

ប្រសិនបើបានបង្កើតសុំកូនធម្មតា ត្រូវសរសេរការបង្កើតសុំកូនធម្មតា នៅលើរឹមទំព័រនៃបញ្ជីកំណើតដើមរបស់កូនសុំនោះ ។

## ជំពូកទី ៥

## អំណាចមេបា

### ផ្នែកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១០៣៤.-** អត្ថន័យនៃអំណាចមេបា

អ្នកដែលមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ច ត្រូវបីបាច់រក្សារូបកាយ

# ព្រះរាជក្រម

នស/រកម/១២០៩/០២៨

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីសុំកូនអន្តរប្រទេស ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

# ច្បាប់

# ស្តីពី

# សុំកូនអន្តរប្រទេស



## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ពីគោលការណ៍ លក្ខខណ្ឌ នីតិវិធី ទម្រង់បែបបទ និង អានុភាពនៃសុំកូនអន្តរប្រទេស ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងធានានូវឧត្តមប្រយោជន៍ និង ការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ ដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពលើការសុំកុមារសញ្ជាតិខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្តីប្រពន្ធ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសណាមួយផ្សេងទៀត ដើម្បីយកទៅចិញ្ចឹមជាកូន ដែលទទួលស្គាល់ដោយច្បាប់នៅប្រទេសនោះ ។

**មាត្រា ៤.-**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់ក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

- **ការថែទាំជំនួស** សំដៅដល់ការថែទាំ ដែលផ្តល់ទៅឱ្យកុមារកំព្រា និង កុមារងាយរងគ្រោះ ដែលមិនស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើតនៃកុមារទាំងនោះ ។
- **កុមារដែលត្រូវការនូវការថែទាំពិសេស** សំដៅដល់កុមារពិការផ្នែកកាយសម្បទាធ្ងន់ធ្ងរ ឬ ពិការផ្នែកស្មារតី ឬ កុមារដែលមានជំងឺរ៉ាំរ៉ៃ ។
- **កុមារដែលត្រូវបោះបង់ចោល** សំដៅដល់កុមារដែលអាជ្ញាធរមានសមត្ថកិច្ចរកឃើញ ឬ ត្រូវបានសាធារណជនរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច និង ជាកុមារដែលមិនស្គាល់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ជាកុមារដែលឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបោះបង់ចោល និង រកមិនឃើញអ្នកទាំងនោះ យ៉ាងតិច ៥ (ប្រាំ) ខែជាប់គ្នា ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

4/35

- **ជនម្នាក់** សំដៅដល់ជនដែលគ្មានសហព័ទ្ធស្របច្បាប់ ។

- **ទីភ្នាក់ងារសុំកូនអន្តរប្រទេស** សំដៅដល់ទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និង ពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួលកូនសុំ ដើម្បីធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស ។

- **ឫត្តភាព** សំដៅដល់ក្រសែញាតិ ដែលទាក់ទងពីឪពុកម្តាយទៅកូនបង្កើតរបស់ខ្លួន ។

- **ប្រទេសលំនៅឋានអចិន្ត្រៃយ៍** សំដៅដល់ប្រទេសដែលជនណាមួយកំពុងរស់នៅដោយមានបំណងយកប្រទេសនោះធ្វើជាលំនៅឋានអចិន្ត្រៃយ៍ ។ ជននោះត្រូវបានទទួលស្គាល់ដោយច្បាប់នៃប្រទេសដែលខ្លួនរស់នៅ ថាមានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសនោះ ។

- **មណ្ឌលកុមារកំព្រា** សំដៅដល់មណ្ឌលរបស់រដ្ឋ ឬ របស់អង្គការមិនមែនរដ្ឋាភិបាល ដែលទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ចិញ្ចឹមថែទាំ និង ផ្តល់នូវតម្រូវការជាមូលដ្ឋានគ្រប់យ៉ាងក្នុងការអភិវឌ្ឍរបស់កុមារដែលគ្មានឪពុកម្តាយ ឬ គ្មានឪពុក ឬ គ្មានម្តាយ ឬ កុមារ ដែលត្រូវបោះបង់ចោល ឬ កុមារដែលឪពុកម្តាយ ឬ អ្នកអាណាព្យាបាលពុំមានលទ្ធភាពផ្តល់ការថែទាំគ្រប់គ្រាន់ ។

- **ប្តីប្រពន្ធ** សំដៅដល់បុរសម្នាក់ និង ស្ត្រីម្នាក់ដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ។

- **សុំកូនដោយសាច់ញាតិ** សំដៅដល់ការសុំកូនដោយអ្នកសុំនូវកុមារដែលត្រូវជាចៅរបស់ខ្លួន ចៅទួតរបស់ខ្លួន ក្មួយរបស់ខ្លួន ឬ កុមារដែលត្រូវជាកូន ចៅ ចៅទួត ឬ ក្មួយរបស់សហព័ទ្ធរបស់ខ្លួន ។

- **សុំកូនពេញលេញ** សំដៅដល់សុំកូនដែលមានអានុភាពបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ ជាឪពុកម្តាយ និង កូនរវាងឪពុកម្តាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម និង កូនសុំ និង បញ្ចប់សិទ្ធិ និង កាតព្វកិច្ចរវាងកូននិងឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលស្របច្បាប់ផ្សេងទៀតរបស់ខ្លួន ។

- **អ្នកសុំ** សំដៅដល់ប្តីប្រពន្ធដែលកំពុងស្វះស្វែងសុំកុមារយកទៅចិញ្ចឹម ។

- **ឪពុកម្តាយចិញ្ចឹម** សំដៅដល់ប្តីប្រពន្ធដែលបានទទួលសិទ្ធិជាផ្លូវការពី

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ksl

5/35

តុលាការមានសមត្ថកិច្ច ឱ្យធ្វើជាឪពុកម្តាយថ្មីនៃកូនសុំស្របតាមបទប្បញ្ញត្តិដូចមានចែង ក្នុងច្បាប់នេះ ។

## ជំពូកទី ២
## គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស

**មាត្រា ៥.-**

សុំកូនអន្តរប្រទេសត្រូវអនុវត្តតាមគោលការណ៍ដូចតទៅ :

១- កុមារត្រូវចម្រើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ បរិយាកាសសុភមង្គល សេចក្តីស្រឡាញ់ និង ការយោគយល់ ដើម្បីឱ្យមានការអភិវឌ្ឍពេញលេញ និង យ៉ាងសុខដុម នូវបុគ្គលិកលក្ខណៈរបស់ខ្លួន ។ សុំកូនអន្តរប្រទេស អាចអនុញ្ញាតបានក្រោយពីអស់លទ្ធភាពផ្តល់ការឧបត្ថម្ភគាំទ្រ ដើម្បីឱ្យកុមាររស់នៅក្នុងគ្រួសារកំណើត និង ក្រោយពីបានធ្វើការពិចារណា អំពីសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- សុំកូនអន្តរប្រទេស អាចប្រព្រឹត្តទៅបានលុះត្រាតែជាសុំកូនពេញលេញ ដែលបង្កើតនូវទំនាក់ទំនងរវាងអ្នកសុំ និង កូនសុំជាអចិន្ត្រៃយ៍ និង ដែលផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និង កាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះ ។

៣- កុមារទាំងឡាយណាដែលបំពេញបាននូវលក្ខខណ្ឌដូចមានចែងក្នុង មាត្រា ១០ អាចធ្វើជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបានដោយមិនមានការរើសអើងអំពី ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិកំណើត ឋានៈក្នុងសង្គម ធនធាន ពិការភាព ឬ ស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬ របស់ឪពុកម្តាយ ឬ របស់ឪពុក ឬ របស់ម្តាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

៤- រាល់ការសម្រេច និង សកម្មភាពទាក់ទងនឹងដំណើរការសុំកូនអន្តរប្រទេស ត្រូវគិតគូរឱ្យបានច្រើនលើសលប់ដល់ឧត្តមប្រយោជន៍របស់កុមារ ។

៥- តុលាការ និង អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងដំណើរការសុំកូន អន្តរប្រទេស ត្រូវធានាថា នៅពេលកំពុងដំណើរការនីតិវិធីសុំកូន កុមារដែលមានសមត្ថភាព អាចយល់ដឹងបាន ត្រូវបានពិគ្រោះយោបល់ និង ពន្យល់ណែនាំឱ្យបានត្រឹមត្រូវអំពីអានុភាព

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

Kol

នានា ដែលកើតចេញពីសុំកូននេះដោយគិតគូរដល់សេចក្តីប្រាថ្នា និង មតិរបស់កុមារ ដើម្បីឧត្តមប្រយោជន៍របស់កុមារ ។

៦- ហាមការធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេស ។ អាជីវកម្ម ឬ សកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេសមាន :

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឱ្យបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើតដើម្បីឱ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ឪពុក ឬ ម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត និង

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឱ្យអ្នកសុំ ។

៧- អាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធក្នុងនីតិវិធីសុំកូនអន្តរប្រទេស ត្រូវធានាថាដំណើរការសុំកូនអន្តរប្រទេស មិនបណ្តាលឱ្យមានការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនស្របច្បាប់ និង ត្រូវបង្ការមិនឱ្យមានការចាប់ពង្រត់ ការលក់ និង ការជួញដូរកុមារក្នុងពេលកំពុងដំណើរការសុំកូនអន្តរប្រទេស ។ មានតែប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាន ដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះដែលត្រូវបង់ ។

## ជំពូកទី ៣
## អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស

**មាត្រា ៦.–**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច បំពេញតួនាទីជាអាជ្ញាធរកណ្តាលសុំកូនអន្តរ

**មាត្រា ៧.-**

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសមានតួនាទី និង ភារកិច្ចដូចតទៅ :

១- រៀបចំ និង ត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និង នីតិវិធីទាក់ទងនឹងការសម្រេចលើកិច្ចការសុំកូនអន្តរប្រទេស ។

២-ធ្វើសហប្រតិបត្តិការ និង ធ្វើការសម្របសម្រួលលើការប្រាស្រ័យទាក់ទងគ្នា ទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេសជាមួយក្រសួង ស្ថាប័ន និង ទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង ជាមួយអាជ្ញាធរកណ្តាល និង អាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស នៃប្រទេសទទួល ។

៣- ចាត់វិធានការសមស្របដើម្បីបង្ការ និង ទប់ស្កាត់ ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬ ផលចំណេញផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស ។

៤- រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការសុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ។

៥- ពិនិត្យលើសំណើរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសនីមួយៗតាមការចាំបាច់ ។

៦- ធ្វើអធិការកិច្ចលើកិច្ចការពាក់ព័ន្ធសុំកូនអន្តរប្រទេស ។ គ្មានជនណាអាចរារាំង បង្អាក់ ឬ ជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ ។

៧- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច យល់ថាចាំបាច់សម្រាប់អនុវត្តកិច្ចការសុំកូនអន្តរប្រទេស ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨.-**

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស មានរដ្ឋបាលសុំកូនអន្តរប្រទេសជាសេនាធិការ ។ មន្ត្រីបម្រើការក្នុងរដ្ឋបាលសុំកូនអន្តរប្រទេសរួមមាន អ្នកធ្វើការងារផ្នែកសង្គមកិច្ច អ្នកចិត្តសាស្ត្រ និង អ្នកជំនាញខាងច្បាប់បានទទួលការបណ្តុះបណ្តាលពិសេស ស្តីពីសុំកូន

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

**មាត្រា៩.-**

រដ្ឋបាលសុំកូនអន្តរប្រទេស មានតួនាទី និង ភារកិច្ចដូចតទៅ:

១-រៀបចំ ថែរក្សាបញ្ជីសម្ងាត់ និង សំណុំឯកសាររបស់កុមារដែលមានលក្ខណៈសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស ។

២-វាយតម្លៃស្ថានភាពកុមារទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីសម្ងាត់ដើម្បីកំណត់ទម្រង់នៃការចិញ្ចឹមថែទាំសមស្របបំផុតសម្រាប់កុមារ និង ធានាថាកុមារទាំងនោះទទួលបានការចិញ្ចឹមថែទាំតាមតម្រូវការ ។

៣-ប្រឹងប្រែងរកដំណោះស្រាយឱ្យអស់លទ្ធភាពក្នុងប្រទេស ក្នុងការថែទាំជាអចិន្ត្រៃយ៍នៅតាមគ្រួសារ ឬ នៅជាមួយអ្នកអាណាព្យាបាល មុននឹងដំណើរការសុំកូនអន្តរប្រទេស ។

៤-ទទួលពិនិត្យ និង ចាត់ការពាក្យសុំកូនអន្តរប្រទេស និង ឯកសារពាក់ព័ន្ធផ្សេងៗទៀតរបស់អ្នកសុំ ។

៥-ផ្គូផ្គងអ្នកសុំជាមួយកុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស និង ផ្តល់មតិយោបល់លើករណីសុំកូនអន្តរប្រទេស ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

៦-ផ្តល់ដំណឹងទៅអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតពីប្រទេសទទួល អំពីនីតិវិធីសុំកូន និង ការវិវឌ្ឍនៃករណីសុំកូន ។

៧-សម្របសម្រួលការប្រគល់កុមារទៅឱ្យអ្នកសុំ និង រៀបចំឯកសារ ដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសរបស់អ្នកសុំ ។

៨-ផ្តល់ ឬ សម្របសម្រួលការផ្តល់សេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារអ្នកសុំ និង គ្រួសារបង្កើតតាមការចាំបាច់ ។

៩-ផ្តល់មតិយោបល់ទាក់ទងនឹងការផ្តល់ការអនុញ្ញាតឱ្យទីភ្នាក់ងារសុំកូនអន្តរ-

ប្រទេស ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ឬ ការដកហូតការអនុញ្ញាត ជូនអាជ្ញាធរកណ្តាលទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ។

១០- បំពេញភារកិច្ចផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសតាមការចាំបាច់ ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញា របស់ព្រះរាជាណាចក្រកម្ពុជា និង តាមការប្រគល់អំណាចរបស់អាជ្ញាធរកណ្តាល ។

## ជំពូកទី ៤

## លក្ខខណ្ឌសម្រាប់សុំកូន

### ផ្នែកទី ១

### កូនសុំ

**មាត្រា១០.-**

កុមារដែលអាចជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌទាំងអស់ ដូចខាងក្រោម៖

១- កុមារសញ្ជាតិខ្មែរដែលមានលំនៅឋានជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-កុមារមានអាយុក្រោម ៨ (ប្រាំបី) ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែករណីកុមារត្រូវការទូវការថែទាំពិសេស ដែលអាចអនុញ្ញាតបានដល់អាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។ ក្នុងករណី កុមារមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម ៨ (ប្រាំបី) ឆ្នាំ អាចអនុញ្ញាតឱ្យសុំកុមារនោះរួមជាមួយនឹងបងប្អូនបង្កើតដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

៣- កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬ រស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀត ដែលត្រួតពិនិត្យដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

៤- កុមារទាំងនោះស្ថិតក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬ កុមារដែលស្ថិតនៅក្រោមអំណាចមេបាដែលមានស្ថានភាពលំបាកបំផុត ។

៥- កុមារនោះត្រូវបានប្រកាសថាអាចសុំជាកូនចិញ្ចឹមបាន ដោយអនុលោមតាមមាត្រា ១[illegible] នៃច្បាប់នេះ ។

ក្នុងករណីសុំកូនដោយសាច់ញាតិ សុំកូនអាចអនុញ្ញាតបានចំពោះកុមារមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលរស់នៅក្នុង ឬ ក្រៅមណ្ឌលកុមារកំព្រា ។

**មាត្រា ១១.-**

ករណីមានកុមារត្រូវបានរកឃើញ និង បញ្ជូនមកមណ្ឌលកុមារកំព្រា ហើយរកមិនឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ប្រធានមណ្ឌលកុមារកំព្រា ត្រូវជូនដំណឹងទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត អំពីវត្តមានរបស់កុមារ ដែលបានចូលមកស្នាក់នៅក្នុងមណ្ឌល យ៉ាងយូរបំផុតរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីពេលដែលកុមារមកដល់មណ្ឌល ។ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីបញ្ចូលឈ្មោះកុមារទៅក្នុងបញ្ជី ស្តីពីកុមារដែលត្រូវបានរាយការណ៍ថាត្រូវបានគេបោះបង់ចោល ។

មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីស្វែងរកឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ និង អ្នកអាណាព្យាបាលសម្រាប់អនីតិជនមុន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសាធារណៈទៅតាមលទ្ធភាពដូចជា ទូរទស្សន៍ វិទ្យុ ឬ សារព័ត៌មាន និង រូបភាពរបស់កុមារនោះ ។ ជនណាដែលអះអាងថាខ្លួនជាឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ជននោះត្រូវបង្ហាញភស្តុតាងផ្សេងៗ ដែលបញ្ជាក់ថាខ្លួនមានជាប់ទាក់ទងជាសាច់ញាតិ ឬ អ្នកអាណាព្យាបាល សម្រាប់អនីតិជនជាមួយកុមារស្របទៅតាមបទប្បញ្ញត្តិជាធរមាន ។

បន្ទាប់ពីការផ្សព្វផ្សាយដំណឹងរយៈពេល ៥ (ប្រាំ) ខែ នៅតែរកមិនឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ និង អ្នកអាណាព្យាបាល សម្រាប់អនីតិជនមុននោះ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការខិតខំស្រាវជ្រាវនេះ ហើយត្រូវផ្ញើមួយច្បាប់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីចុះឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារដែលត្រូវបោះបង់ចោល ។

ចាប់ពីពេលដែលកុមារត្រូវបានរកឃើញ រហូតដល់តុលាការបានជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ប្រធានមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត គឺជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន ។ បញ្ញត្តិស្តីពីអាណាព្យាបាលសម្រាប់អនីតិជនដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ត្រូវយកអនុវត្តផងដែរ ចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន ។ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន គ្មានសិទ្ធិផ្តល់ការយល់ព្រមលើសុំកូនទេ ។

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវរៀបចំបញ្ជី និង បញ្ចូលព័ត៌មានថ្មីៗឱ្យបានទៀងទាត់ស្តីពីកុមារដែលត្រូវបោះបង់ចោល ។

ករណីកុមារដែលត្រូវបោះបង់ចោលពុំអាចរកឃើញឪពុកម្តាយ ឬឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ហើយពុំមានសំបុត្រអត្រានុកូលដ្ឋានកំណើត ប្រធានមណ្ឌលកុមារកំព្រា ត្រូវសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតកុមារនោះទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។

**មាត្រា១២.-**

ប្រសិនបើ អ្នកអនុវត្តអំណាចមេបាដែលស្ថិតនៅក្នុងស្ថានភាពលំបាកបំផុត បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនោះ ត្រូវបញ្ចូលឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារ ដែលត្រូវបានធ្វើការទុកដាក់ឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវរៀបចំបញ្ជី និង បញ្ចូលព័ត៌មានថ្មីៗឱ្យបានទៀងទាត់ស្តីពីកុមារដែលអ្នកអនុវត្តអំណាចមេបារបស់ខ្លួន បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

**មាត្រា១៣.-**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបញ្ជូនកុមារទៅគ្រួសារកំណើត ហើយបើមិនអាចធ្វើទៅបានទេ ត្រូវទុកដាក់កុមារតាមរយៈសុំកូនក្នុងស្រុកនៅក្នុងព្រះរាជាណាចក្រកម្ពុជា មុននឹងពិនិត្យរកលក្ខណសម្បត្តិសុំកូនអន្តរប្រទេស ឬស្រុកក្រៅ ។

735

Ksl

នៅពេលវិធានការនានា ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវបានបញ្ចប់ កុមារអាចនឹងត្រូវបានបញ្ចូលឈ្មោះទៅក្នុងបញ្ជីស្តីពីកុមារដែលកំណត់ថាមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស ។

## ផ្នែកទី ២
## ការយល់ព្រមលើសុំកូន

**មាត្រា១៤.-**

ដំណើរការសុំកូនអាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារតាមករណីដូចខាងក្រោមនេះ :

ក- ក្នុងករណីកុមារមានចំណងបុត្តភាពជាមួយឪពុក និង ម្តាយ ការយល់ព្រមត្រូវផ្តល់ដោយឪពុក និង ម្តាយរបស់កុមារនោះ ។

ខ- ក្នុងករណីដែលឪពុក ឬ ម្តាយណាមួយរបស់កុមារបានស្លាប់ ឬ ស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬ ត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយឪពុក ឬ ម្តាយតែម្ខាងដែលមានអំណាចមេបាជាការគ្រប់គ្រាន់ ។

គ- ក្នុងករណីដែលឪពុកម្តាយរបស់កុមារបានស្លាប់ ឬ ស្ថិតនៅក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬ ត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនោះ ។

**មាត្រា១៥.-**

ការយល់ព្រមខាងលើត្រូវផ្តល់ឱ្យដោយសេរី និង ច្បាស់លាស់ដោយមិនត្រូវមានវិការៈណាមួយដូចជា ការបង្ខិតបង្ខំ ការឆបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬ ការសន្យាផ្តល់ប្រាក់ រង្វាន់ សំណង ឬ ផលប្រយោជន៍ណាមួយឡើយ និង ដោយបានដឹងច្បាស់អំពីផលវិបាកនៃការយល់ព្រមរបស់ខ្លួនចំពោះសុំកូនអន្តរប្រទេស ។

មាត្រា១៦.-

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវទទួលនូវការពិគ្រោះយោបល់ពីភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ដែលបានទទួលការអនុញ្ញាតជាមុនសិន មុននឹងផ្តល់ការយល់ព្រម ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវប្រាប់យ៉ាងច្បាស់លាស់ ដល់អ្នកដែលត្រូវផ្តល់ការយល់ព្រមអំពីអានុភាពនៃការយល់ព្រម ការបញ្ចប់នូវបុត្តភាព ព្រមទាំងការបញ្ចប់សិទ្ធិនិងកាតព្វកិច្ចជាអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង ត្រូវប្រាប់អំពីបែបបទ និង រយៈពេលបញ្ឈប់ការយល់ព្រមដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍របស់ខ្លួនជាមួយឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

ទោះក្នុងករណីណាក៏ដោយ ការយល់ព្រមត្រូវផ្តល់សក្តីកម្មជាលាយលក្ខណ៍អក្សរ នៅចំពោះមុខមេឃុំ ឬ ចៅសង្កាត់ខាងទីលំនៅរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

មេឃុំ ឬ ចៅសង្កាត់ និងភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវធានាថា រាល់ការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាការយល់ព្រមដែលគោរពទៅតាមខ្លឹមសារនៃមាត្រា ១៥ នៃច្បាប់នេះ ។

មេឃុំ ឬ ចៅសង្កាត់ ត្រូវចាត់ចែងធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមនេះ ក្រោយពីបានពិនិត្យថា ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចបានពិគ្រោះយោបល់ជាមុនជាមួយឪពុកម្តាយ ឬឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និង បានប្រាប់យ៉ាងត្រឹមត្រូវអំពីអានុភាពនៃការយល់ព្រមនេះ ។

មាត្រា១៧.-

ឪពុកម្តាយ ឬឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អាចបញ្ឈប់ការយល់ព្រមរបស់ខ្លួនវិញបាន រហូតដល់មុនពេលសេចក្តីសម្រេចរបស់តុលាការស្តីពីសុំកូនធម៌ជាស្ថាពរ ។ ការបញ្ឈប់ការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននេះ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ នៅចំពោះមុខមេឃុំ ឬ ចៅសង្កាត់ខាងលំនៅឋានរបស់ខ្លួន ។ មេឃុំ ឬ ចៅសង្កាត់ខាង

លំនៅឋានរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវធ្វើកំណត់ហេតុអំពីកិច្ចការនេះ ហើយត្រូវបញ្ជូនកំណត់ហេតុនេះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ប្រធានមណ្ឌលកុមារកំព្រាដែលពាក់ព័ន្ធ និង ត្រូវប្រគល់កំណត់ហេតុចម្លងដែលមានសេចក្ដីបញ្ជាក់នៅលើកំណត់ហេតុនោះ ទៅឱ្យឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។

**មាត្រា ១៨.-**

ដំណើរការសុំកូនអាចប្រព្រឹត្តទៅបាន លុះត្រាតែផុតកំណត់ពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយការយល់ព្រមរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

**មាត្រា ១៩.-**

ករណីឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារបដិសេធការយល់ព្រម ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចប្ដឹងសុំឱ្យតុលាការប្រកាសដកហូតអំណាចមេបាពីឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ បញ្ឈប់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និងជ្រើសតាំងអ្នកអាណាព្យាបាលថ្មីសម្រាប់អនីតិជនរបស់កុមារ ក្នុងករណីពិនិត្យឃើញថា ការបដិសេធ ឬ ការបញ្ឈប់ការយល់ព្រមនេះ ធ្វើឱ្យ បាត់បង់ផលប្រយោជន៍របស់កុមារ ឬ បណ្ដាលឱ្យ ប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬ សីលធម៌របស់កុមារ ។ ពាក្យបណ្ដឹងទៅតុលាការត្រូវធ្វើក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ បដិសេធ ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន ។

**មាត្រា ២០.-**

ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ដែលយល់ថា ការយល់ព្រមរបស់ខ្លួនបានមកពីការបង្ហាញឆន្ទៈដែលមានវិការៈ ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អាចបញ្ឈប់ ឬ លុបចោលនូវការយល់ព្រមរបស់ខ្លួនបាន រហូតដល់មុនដីកាសម្រេចរបស់តុលាការលើសុំកូនចូល

## ផ្នែកទី ៣

## អ្នកសុំ

**មាត្រា ២១.-**

អ្នកសុំដែលអាចអនុញ្ញាតឱ្យសុំកុមារយកទៅចិញ្ចឹមជាកូនបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌ ដូចតទៅ :

១-អ្នកសុំជាប្តីប្រពន្ធត្រូវមានអាយុចាប់ពី ៣០(សាមសិប)ឆ្នាំ និង មានអាយុលើសកូនសុំយ៉ាងតិច ២២(ម្ភៃពីរ)ឆ្នាំ និង យ៉ាងច្រើនបំផុត ៤៥(សែសិបប្រាំ)ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំកូន ។

២-ក្នុងករណីដែលអ្នកសុំមិនបានបំពេញតាមចំណុច ១ ខាងលើ ហើយក្នុងករណីសុំកូនឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារ សុំកូនអាចអនុញ្ញាតឱ្យបាន ក្នុងស្ថានភាពដូចតទៅ :

ក-អ្នកសុំមានដើមកំណើតសញ្ជាតិខ្មែរ សុំកុមារដែលជាសាច់ញាតិរបស់ខ្លួន ឬ

ខ-អ្នកសុំជាសហព័ទ្ធដែលសុំកូននៃសហព័ទ្ធម្ខាងទៀត ឬ

គ-អ្នកសុំ សុំកុមារដែលត្រូវការការថែទាំពិសេស ឬ ស្ថានភាពផ្សេងទៀត ដែលបម្រើឧត្តមប្រយោជន៍របស់កុមារ ។

៣-ក្នុងករណីអ្នកសុំមានប្តី ឬ ប្រពន្ធ ការសុំកូនត្រូវធ្វើដោយសហព័ទ្ធទាំងពីររួមគ្នា លើកលែងតែករណីដែលសហព័ទ្ធណាម្ខាង សុំកូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

៤-ច្បាប់ជាតិរបស់អ្នកសុំនីមួយៗ និង ច្បាប់ប្រទេសនៃលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំបានទទួលស្គាល់ និង អនុញ្ញាតនូវបុត្តភាពនៃសុំកូនពេញលេញ ។

៥-ប្រទេសនៃសញ្ជាតិ ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍នៃអ្នកសុំ ត្រូវតែជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា ។

៦-អ្នកសុំត្រូវមានលក្ខណសម្បត្តិ និង លក្ខខណ្ឌជាសារវន្តនានាសម្រាប់សុំកូនស្របទៅតាមច្បាប់ប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ក្រសួងព្រះបរមរាជវាំង

៧-អ្នកសុំត្រូវតែជាជនពុំធ្លាប់ត្រូវបានផ្តន្ទាទោស ឬ កំពុងត្រូវបានប្តឹងអំពីកំហុសទាក់ទងទៅនឹងកិរិយាមារយាទ ឬ ការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយនៅក្នុងប្រទេសនៃសញ្ជាតិរបស់ខ្លួន ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍ ឬ ក្នុងប្រទេសណាមួយដែលខ្លួនបានស្នាក់នៅចុងក្រោយ ។

៨-អ្នកសុំត្រូវតែជាអ្នកមានសមត្ថភាពផ្តល់ការថែទាំសមស្រប និង ការគាំទ្រចាំបាច់ដល់កូនសុំ ។

៩-អ្នកសុំត្រូវបានអនុញ្ញាតឱ្យសុំកូនបាន លុះត្រាតែអ្នកសុំកូនគ្មានកូន ឬ មានកូនតែម្នាក់នៅក្នុងបន្ទុក ។ អ្នកសុំអាចសុំកូនបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតអាចអនុញ្ញាតឱ្យសុំច្រើននាក់បាន ។

## ជំពូកទី ៥
## នីតិវិធីសុំកូន
## ផ្នែកទី ១
## នីតិវិធីរដ្ឋបាល

**មាត្រា ២២.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសរួមមាន ព័ត៌មានចាំបាច់អំពីអត្តសញ្ញាណរបស់កុមារ ភាពអាចសុំជាកូនចិញ្ចឹម សាវតារជាតិរបស់កុមារ បរិយាកាសសង្គមរបស់កុមារ ប្រវត្តិគ្រួសាររបស់កុមារ ប្រវត្តិសុខភាពរបស់កុមារ និង ប្រវត្តិសុខភាពគ្រួសាររបស់កុមារ និង សេចក្តីត្រូវការជាពិសេសណាមួយរបស់កុមារ ។

ក្នុងករណីកុមារត្រូវបានបោះបង់ចោល រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារត្រូវបានធ្វើរួចហើយ ។

រដ្ឋបាលសុំកូនអន្តរប្រទេសក៏ត្រូវធានាផងដែរថា រាល់ការយល់ព្រមចាំបាច់ទាំងឡាយត្រូវបានធ្វើឡើងស្របទៅតាមបទប្បញ្ញត្តិនានានៃច្បាប់នេះ ។

សំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារ រាប់បញ្ចូលទាំងភស្តុតាងបង្ហាញពីការយល់ព្រម និង/ឬ ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្តាយ ឬឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារផងដែរ ។

**មាត្រា ២៣.-**

អ្នកសុំត្រូវដាក់ពាក្យសុំកូនទៅអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាដោយភ្ជាប់មកជាមួយនូវឯកសាររួមមាន :

១-ភស្តុតាងដែលបញ្ជាក់ថា អាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់ខ្លួន ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ចាត់ទុកថា អ្នកសុំមានលក្ខណសម្បត្តិ និង មានភាពសមស្របសម្រាប់សុំកូនដោយផ្អែកលើការវាយតំលៃលើជីវប្រវត្តិផ្ទាល់ខ្លួន ប្រវត្តិគ្រួសារ ប្រវត្តិសុខភាព បរិយាកាសគ្រួសារ បរិយាកាសសង្គម មូលហេតុសុំកូន និងលទ្ធភាពនៃការទទួលបន្ទុករ៉ាប់រងចំពោះសុំកូនអន្តរប្រទេស ។

២-ព័ត៌មានចាំបាច់ទាក់ទងនឹងការឆ្លើយតបទៅនឹងលក្ខខណ្ឌនានាដែលមានចែងក្នុងមាត្រា ២១ នៃច្បាប់នេះ ។

៣-ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកសុំ ដែលក្នុងនោះរួមមានឯកសារទាក់ទងនឹងអត្រានុកូលដ្ឋាន ។

៤-ព័ត៌មានទាក់ទងនឹងលក្ខណសម្បត្តិផ្សេងៗរបស់កុមារ ដែលអ្នកសុំអាចនឹងមានលក្ខណសម្បត្តិថែទាំបាន ។

៥-ភស្តុតាងទទួលបានពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលដែលបញ្ជាក់ថា នៅពេលពាក្យសុំកូនរបស់ខ្លួនត្រូវបានយល់ព្រមហើយ កូនសុំនោះត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសទទួល ។

ឯកសារទាំងអស់ ត្រូវបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

ឯកសារច្បាប់ដើមទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ឬ ភាសាបារាំង ដែលមានការបញ្ជាក់ត្រឹមត្រូវ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មាត្រា ២៤.-

ពាក្យសុំដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ត្រូវបញ្ជូនមកក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ តាមរយៈអាជ្ញាធរកណ្តាល ស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួលប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារទាំងនោះ ។ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យផ្តល់យោបល់ និង ត្រូវបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេស ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំ ។ ក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកសុំ តាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់អ្នកសុំ ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ ដោយបញ្ជាក់ថា ខ្លួនបានទទួលពាក្យសុំកូន ។

មាត្រា ២៥.-

អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានា សម្រាប់ជួយឧបត្ថម្ភដល់ជីវភាពនានានៃការថែទាំជំនួស និង ការជួយឧបត្ថម្ភទូទៅដល់មណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និង កម្រៃសេវាចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសដែលនឹងកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ក្រៅពីនេះ មិនត្រូវយកថ្លៃសោហ៊ុយសុំកូនពីអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូន ។ មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូនបង់ថ្លៃសោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗ ឬ ទៅតាមសោហ៊ុយសុំកូនមួយៗដែលនឹងត្រូវបញ្ជូនទៅឱ្យមណ្ឌលកុមារកំព្រាណាមួយ ឬ មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូនធ្វើការផ្តល់សោហ៊ុយ អំណោយ ឬ ការទូទាត់ ទោះក្នុងរូបភាពណាក៏ដោយឱ្យទៅមណ្ឌលកុមារកំព្រា ដែលកុមារនៅទីនោះត្រូវបានសុំយកទៅចិញ្ចឹម ឬ ទៅឱ្យបុគ្គលិក នាយក ឬ សមាជិកនៃគណៈគ្រប់គ្រងទោះជាដោយផ្ទាល់ ឬ ដោយប្រយោលក្តី ។

9/35

Kol

**មាត្រា ២៦.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចទទួលសំណុំលិខិតសុំកូន ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។ ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ហើយ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវបញ្ជាក់ថា អ្នកសុំបានបំពេញលក្ខខណ្ឌត្រឹមត្រូវតាមច្បាប់នេះហើយ ។

ក្នុងករណីដែលសំណុំលិខិតដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេស មិនទាន់គ្រប់គ្រាន់ ឬ មិនទាន់ត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងទៅអ្នកសុំជាលាយលក្ខណ៍អក្សរអំពីឯកសារដែលនៅខ្វះ ឬ មិនទាន់ត្រឹមត្រូវ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលឯកសារដែលនៅខ្វះ ឬ កែតម្រូវរួច។

ក្នុងករណីអ្នកសុំខកខានមិនបានផ្តល់ឯកសារដែលនៅខ្វះ ឬ មិនទាន់ត្រឹមត្រូវក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃរដ្ឋបាលសុំកូនអន្តរប្រទេសបានជូនដំណឹងអំពីឯកសារដែលមិនទាន់គ្រប់គ្រាន់ ឬ មិនទាន់ត្រឹមត្រូវ នោះពាក្យសុំកូនអន្តរប្រទេសត្រូវទុកជាមោឃៈ ។

ក្នុងករណីបដិសេធពាក្យសុំ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវមានបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ ។

**មាត្រា ២៧.-**

ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ និង ត្រឹមត្រូវ ហើយអ្នកសុំបានបំពេញទៅតាមលក្ខខណ្ឌនៃច្បាប់នេះ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យពិចារណាទៅលើសំណុំឯកសាររបស់កុមារទាំងឡាយដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសបាន និង ត្រូវផ្តល់អំពីលក្ខណសម្បត្តិរបស់អ្នកសុំណាដែលត្រូវគ្នាល្អបំផុតនឹងលក្ខណសម្បត្តិរបស់កុមារ ។

ក្នុងការផ្តល់ដោយគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិចារណាឱ្យបានសមស្របទៅលើអត្ថប្រយោជន៍នៃការបន្តឱ្យមានការបីបាច់ថែរក្សាកុមារ ដូចពេលកន្លងមក ព្រមទាំងពិចារណាទៅលើសាវតារសង្គម ជាតិពន្ធុ សាសនា និងវប្បធម៌របស់កុមារ ។

**មាត្រា ២៨.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវផ្ញើសំណុំឯកសាររបស់កុមារដែលត្រូវបានផ្តល់ រួមទាំងភស្តុតាងដែលបង្ហាញថា រាល់ការយល់ព្រមចាំបាច់នានា ត្រូវបានទទួលរួចហើយ និងមូលហេតុដែលខ្លួនកំណត់ទុកដាក់កុមារជាមួយអ្នកសុំនោះទៅអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីពិនិត្យនិងបញ្ជូនទៅអ្នកសុំដោយមិនចាំបាច់ជូនដំណឹងអំពីអត្តសញ្ញាណឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារឡើយ លើកលែងតែករណីសុំកូនដោយសាច់ញាតិ ។

**មាត្រា ២៩.-**

អ្នកសុំត្រូវឆ្លើយតបទៅរដ្ឋបាលសុំកូនអន្តរប្រទេសជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមសុំកុមារ ដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្តល់ឱ្យតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ។

ក្នុងករណីអ្នកសុំមិនបានឆ្លើយតបមករដ្ឋបាលសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្ញើសំណុំឯកសាររបស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសអាចចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ហើយរដ្ឋបាលសុំកូនអន្តរប្រទេសអាចផ្តល់កុមារនោះឱ្យទៅអ្នកសុំផ្សេងទៀតបាន ។ ប្រាក់ចំណាយ សោហ៊ុយ និង វិភាគទានទាក់ទងនឹងការដាក់ពាក្យសុំមិនត្រូវបានប្រគល់ជូនវិញឡើយ ។

LE MINISTÈRE DU PALAIS ROYAL

ក្នុងករណីអ្នកសុំបានឆ្លើយតបថាមិនទទួលយកកុមារដែលបានផ្តល់ឱ្យខ្លួននៅលើកទីមួយទេ អ្នកសុំនោះអាចស្នើសុំឱ្យរដ្ឋបាលសុំកូនអន្តរប្រទេសផ្តល់កុមារជាលើកទីពីរបាន ។ ការផ្តល់នេះមិនត្រូវអនុញ្ញាតឱ្យធ្វើជាលើកទីបីឡើយ ។

ចំពោះអ្នកសុំដែលមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ អ្នកសុំនោះអាចដាក់ពាក្យសុំកូនសាជាថ្មីស្របតាមនីតិវិធីនៃច្បាប់នេះ ។ ក្នុងការសម្រេចអំពីការសុំឱ្យមានការផ្តល់សាជាថ្មី ឬ ការទទួលពាក្យសុំកូនសាជាថ្មី រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិចារណាអំពីមូលហេតុដែលអ្នកសុំខកខានមិនបានឆ្លើយតប ឬ ឆ្លើយតបថា មិនមានបំណងសុំកុមារដែលបានផ្តល់ពីលើកមុនទាពេលកន្លងមក ។

**មាត្រា ៣០.-**

បន្ទាប់ពីអ្នកសុំ បានបញ្ជាក់ការយល់ព្រមរបស់ខ្លួនស្របតាមបទប្បញ្ញត្តិក្នុងមាត្រា ២៩ នៃច្បាប់នេះ ហើយអាជ្ញាធរកណ្តាលនៃប្រទេសទទួល បានយល់ព្រមលើការសម្រេចនេះ រដ្ឋបាលសុំកូនអន្តរប្រទេសតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ត្រូវរៀបចំឱ្យមានការជួបគ្នារវាងអ្នកសុំ និង កុមារដែលត្រូវបានផ្តល់រួចហើយ ។

ការជួបគ្នានេះត្រូវប្រព្រឹត្តទៅតាមកាលបរិច្ឆេទមួយសមស្របសម្រាប់អ្នកសុំ និង រដ្ឋបាលសុំកូនអន្តរប្រទេស និង ត្រូវមានវត្តមានមន្ត្រីសង្គមកិច្ចមានសមត្ថកិច្ចមួយរូបផង ។ ការជួបគ្នានេះ ត្រូវធ្វើក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលការយល់ព្រមពីអ្នកសុំ ។

មុនការជួបគ្នារវាងអ្នកសុំ និង កុមារ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើសម្ភាសន៍អ្នកសុំ និង ធានាថា អ្នកសុំ និង កុមារត្រូវបានរៀបចំខ្លួនជាស្រេចតាមរយៈការពិគ្រោះយោបល់ ការផ្លាស់ប្តូរព័ត៌មាន ការផ្លាស់ប្តូររូបថត និង វិធានការចាំបាច់ផ្សេងៗទៀត ដើម្បីការជួបគ្នានេះ ។

ករណីមានសហព័ទ្ធ បើសហព័ទ្ធណាម្ខាងមិនអាចមកបាន សហព័ទ្ធនោះត្រូវធ្វើលិខិតប្រគល់សិទ្ធិឱ្យទៅសហព័ទ្ធម្ខាងទៀត ធ្វើជាអ្នកតំណាងរបស់ខ្លួន ដើម្បីធ្វើសកម្មភាពក្នុងការសុំកូននោះ ។ លិខិតប្រគល់សិទ្ធិត្រូវមានការបញ្ជាក់ពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទទួល ។

ក្នុងករណីអ្នកសុំមិនមកក្នុងរយៈពេលដូចបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើ ដោយគ្មានមូលហេតុត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវសាកសួរយោបល់របស់កុមារដែលអាចដឹងខុសត្រូវបាន ព្រមទាំងប្រាប់កុមារឱ្យបានដឹងអំពីអានុភាពដែលកើតចេញពីសុំកូននេះ ហើយត្រូវស្តាប់កុមារបញ្ចេញមតិយោបល់របស់ខ្លួន ដោយគ្មានវត្តមានរបស់ភាគីផ្សេងទៀតឡើយ ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវយល់ដឹងឱ្យបានច្បាស់ អំពីទស្សនៈកុមារលើរាល់បញ្ហាដែលពាក់ព័ន្ធដល់សុំកូន ក្នុងនោះមានជាអាទិ៍ ការជ្រើសរើសអ្នកសុំ ហើយមតិយោបល់របស់កុមារត្រូវយកទៅគិតគូរពិចារណាដោយផ្អែកទៅតាមវ័យ និង កម្រិតយល់ដឹងរបស់កុមារ ។ សំអាងស្តីពីការយល់ព្រមរបស់កុមារត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍ និង ការជួបគ្នាខាងលើនេះ ។

**មាត្រា ៣១.-**

បទប្បញ្ញត្តិ ដែលមានចែងក្នុងជំពូកនេះត្រូវយកមកអនុវត្តផងដែរចំពោះសុំកូនដោយសាច់ញាតិ ។

**មាត្រា ៣២.-**

ក្នុងករណីរដ្ឋបាលសុំកូនអន្តរប្រទេសពិនិត្យឃើញថា អ្នកសុំ និង កុមារបំពេញបាននូវលក្ខណវិនិច្ឆ័យ និង លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស ហើយសុំកូននេះពិតជាបានឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវផ្តល់មតិយោបល់ជាវិជ្ជមានក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីការជួបគ្នារវាងអ្នកសុំ និង កុមារ ។

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវដាក់សំណុំលិខិតទាំងនេះ ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកស៊ីវិលសង្គមកិច្ច ដើម្បីសុំការពិនិត្យ និង ផ្តល់អនុសាសន៍លើដំណើរការសុំកូន ។

**មាត្រា ៣៣.-**

ក្រោយពីទទួលអនុសាសន៍លើដំណើរការសុំកូនពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អ្នកសុំត្រូវសហការជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដាក់ពាក្យសុំកូនដែលបានផ្គូផ្គងរួច តាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេសទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីសុំដីកាសម្រេចសុំកូន ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវបញ្ជូនពាក្យសុំកូនទៅសាលាដំបូងរាជធានីភ្នំពេញដោយភ្ជាប់មកជាមួយនូវសំណុំឯកសាររបស់កុមារ និង អ្នកសុំ ព្រមទាំងអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ គិតពីកាលបរិច្ឆេទទទួលពាក្យសុំ ។ ឯកសារចាំបាច់ទាំងអស់ត្រូវបកប្រែជាភាសាខ្មែរ និង មានការបញ្ជាក់ពីរដ្ឋបាលសុំកូនអន្តរប្រទេស ។

ក្នុងករណីអ្នកសុំមិនបានដាក់ពាក្យសុំក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចាត់ទុកថាអ្នកសុំនោះបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ។

## ផ្នែកទី ២
## នីតិវិធីតុលាការ

**មាត្រា ៣៤.-**

សាលាដំបូងរាជធានីភ្នំពេញ មានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ។

តុលាការដែលមានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ត្រូវយកបទប្បញ្ញត្តិស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងមកអនុវត្តចំពោះនីតិវិធីតុលាការទាក់ទងនឹងសុំកូនអន្តរប្រទេស លើកលែងតែមានបទប្បញ្ញត្តិពិសេសដូចមានចែងនៅក្នុងច្បាប់នេះ ។

**មាត្រា ៣៥.-**

អ្នកសុំត្រូវបង់ប្រាក់សរុបចំនួន ១.០០០.០០០ (មួយលាន) រៀល ដើម្បីទ្រទ្រង់សោហ៊ុយដាក់ពាក្យសុំ ការពិនិត្យភស្តុតាង ការចេញដីកាសម្រេច ការបញ្ជូនឯកសារ ការផ្សព្វផ្សាយសេចក្ដីជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និង សកម្មភាពខាងនីតិវិធីផ្សេងៗទៀត

ដែលទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស ។ តុលាការត្រូវបង្គាប់ឱ្យអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន ។ ក្នុងករណីដែលសោហ៊ុយចាំបាច់ដែលបានកំណត់ខាងលើនេះ លើសពី ១.០០០.០០០ (មួយលាន) រៀល តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម និង បង្គាប់ឱ្យអ្នកសុំបង់សោហ៊ុយបន្ថែមនោះជាមុន ។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញទេ ។

**មាត្រា ៣៦.-**

ជាគោលការណ៍ សំណុំឯកសារ និង របាយការណ៍ដែលដាក់ជូនតុលាការដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវសន្មតជាភស្តុតាងនៃអង្គហេតុពិតទាក់ទងនឹងលក្ខណសម្បត្តិ សុំកូនរបស់កុមារ និង ភាពសមស្របសម្រាប់សុំកូនរបស់អ្នកសុំលើកលែងតែមានភស្តុតាងផ្ទុយមកបញ្ជាក់ ។

ក្នុងករណីចាំបាច់ តុលាការអាចបង្គាប់ឱ្យអ្នកតំណាងរដ្ឋបាលសុំកូនអន្តរប្រទេសមកបំភ្លឺបន្ថែមអំពីលទ្ធផលនៃការស្រាវជ្រាវ និង អនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសរួមទាំងឯកសារ របាយការណ៍ និង ភស្តុតាងជាឯកសារពាក់ព័ន្ធដែលគាំទ្រលទ្ធផលនៃការស្រាវជ្រាវខាងលើ ។

**មាត្រា ៣៧.-**

តុលាការត្រូវពិនិត្យផ្ទៀងផ្ទាត់ថា :

ក- លក្ខណវិនិច្ឆ័យ ឬ លក្ខខណ្ឌទាំងអស់នៃសុំកូនអន្តរប្រទេសត្រូវបានបំពេញ ។

ខ- ការពិគ្រោះយោបល់ជាចាំបាច់នានាត្រូវបានធ្វើមុននឹងផ្តល់ការយល់ព្រម ។

គ- ការយល់ព្រមចាំបាច់នានាត្រូវបានផ្តល់ ដោយគោរពតាមខ្លឹមសារផ្នែកទី ២ ជំពូកទី ៤ នៃច្បាប់នេះ ។

ឃ- មានការពិចារណាត្រឹមត្រូវលើគ្រប់លទ្ធភាពក្នុងការទុកដាក់កុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល យល់ព្រមលើការទុកដាក់កុមារ ។

ច- កុមារនឹងត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេស

ឆ- សុំកូនអន្តរប្រទេសនេះពិតជាឧត្តមប្រយោជន៍របស់កុមារ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

25/35

**មាត្រា ៣៨.-**

តុលាការសម្រេចសេចក្តីអំពីរឿងក្តីដែលទាក់ទងនឹងសុំកូនអន្តរប្រទេស ដោយពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ។

ក្នុងករណីមានភាពចាំបាច់ដាច់ខាតត្រូវបំភ្លឺអង្គហេតុពាក់ព័ន្ធ តុលាការអាចអញ្ជើញអ្នកសុំ ឬ អ្នកតំណាង ឬ អ្នកមានអំណាចមេបាម្ខាង ឬ ទាំងពីរ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អ្នកតំណាងទីភ្នាក់ងារសុំកូនអន្តរប្រទេសពាក់ព័ន្ធ និងសាក្សីផ្សេងទៀត ដើម្បីផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ទាក់ទងនឹងអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុ ។

**មាត្រា ៣៩.-**

តុលាការត្រូវលើកយកសំណុំរឿងសុំកូនអន្តរប្រទេសមកវិនិច្ឆ័យ និងចេញដីកាសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំកូន ។ តុលាការត្រូវបញ្ជូនដីកាសម្រេចនេះទៅអ្នកសុំ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំ និងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ ដែលបានកំណត់នៅក្នុងមាត្រា ៤០ នៃច្បាប់នេះ ។ ក្នុងករណីមានការប្តឹងជំទាស់ចំពោះដីកាសម្រេចនេះ ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពររហូតដល់ពេលមានដីកាសម្រេចអំពីបណ្តឹងជំទាស់នោះ ។

**មាត្រា ៤០.-**

បុគ្គលដែលមានសិទ្ធិ ឬ ផលប្រយោជន៍របស់ខ្លួនត្រូវបានបំពានដោយដីកាសម្រេចលើពាក្យសុំកូនអន្តរប្រទេស អាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ចំពោះដីកាសម្រេចនោះបាន ។

ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់ជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលខ្លួនទទួលបានការជូនដំណឹងអំពីដីកាសម្រេច ។

ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់ មិនមែនជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ)

ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលអ្នកសុំបានទទួលការជូនដំណឹងអំពីដីកាសម្រេច ។

អំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ដែលកំណត់ក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើមិនអាចពន្យារបានឡើយ ។

សាលាឧទ្ធរណ៍ត្រូវលើកយកពាក្យបណ្តឹងជំទាស់នោះមកវិនិច្ឆ័យ និង ចេញដីកាសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹងជំទាស់ ។

ដីកាសម្រេចរបស់សាលាឧទ្ធរណ៍លើបណ្តឹងជំទាស់មិនអាចប្តឹងជំទាស់ទៀតបានឡើយ ។

## ជំពូកទី ៦

## អានុភាពនៃសុំកូន

**មាត្រា ៤១.-**

សុំកូនអន្តរប្រទេសត្រូវតែជាសុំកូនពេញលេញ ។ សុំកូនអន្តរប្រទេសមានអានុភាពបង្កើតនូវទំនាក់ទំនងញាតិភាពរវាងឪពុកម្តាយ និង កូនជាអចិន្ត្រៃយ៍ ដោយផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និង ភាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម ហើយវាបញ្ចប់ញាតិភាពរវាងកុមារ និង ឪពុកម្តាយបង្កើតរបស់ខ្លួន ។

**មាត្រា ៤២.-**

អានុភាពផ្សេងទៀតនៃសុំកូនអន្តរប្រទេស ត្រូវគ្រប់គ្រងដោយច្បាប់ជាតិរបស់អ្នកសុំ ឬ ប្រសិនបើគ្មានច្បាប់រួមមួយទេ ត្រូវគ្រប់គ្រងដោយច្បាប់នៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

## ជំពូកទី ៧

## ការជូនដំណឹងពីចំណាត់ការ និង នីតិវិធី បន្ទាប់ពីបញ្ចប់ដំណើរការសុំកូនអន្តរប្រទេស

**មាត្រា ៤៣.-**

រដ្ឋជាអ្នកសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងអំពីការប្រព្រឹត្តទៅនៃនីតិវិធីសុំកូន វិធានការដែលអាជ្ញាធរមានសមត្ថកិច្ចបានចាត់ការ និង ការវិវត្តនៃការសុំកូននៅគ្រប់

ដំណាក់កាលរបស់នីតិវិធីសុំកូនឱ្យបានទៀងទាត់ ទៅអ្នកសុំតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាត ។

**មាត្រា ៤៤.-**

ក្រោយពីដីកាសម្រេចរបស់តុលាការចូលជាស្ថាពរ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវជូនដំណឹងទៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ អំពីដីកាសម្រេចនេះ ។

នៅពេលដែលនីតិវិធីសុំកូនអន្តរប្រទេសត្រូវបានបញ្ចប់ ដោយអនុលោមទៅតាមអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និង សហប្រតិបត្តិការ ទាក់ទងនឹងសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចេញលិខិតបញ្ជាក់អនុលោមតាមមាត្រា ២៣ នៃអនុសញ្ញានេះ ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំពិធីប្រគល់កុមារ និង លិខិតបញ្ជាក់ស្តីពីការប្រគល់កូនជាផ្លូវការទៅអ្នកសុំ ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវជួយសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការរៀបចំ និង ផ្តល់នូវលិខិតឆ្លងដែន ទិដ្ឋាការ និង ឯកសារចាំបាច់នានា ដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

ការធ្វើដំណើររបស់កុមារទៅកាន់ប្រទេសទទួល ត្រូវអមដំណើរដោយអ្នកសុំ ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធានាថាការផ្ទេរកុមារទៅកាន់ប្រទេសទទួល ប្រព្រឹត្តទៅក្នុងកាលៈទេសៈមានសុវត្ថិភាព ដោយមានការគិតគូរដល់សេចក្តីត្រូវការនានារបស់កុមារ ។

**មាត្រា ៤៥.-**

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវសម្របសម្រួលជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីផ្តល់ ឬ សម្របសម្រួលសេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារចិញ្ចឹម និង គ្រួសារបង្កើតតាមការចាំបាច់ ។

ក្រោយពីកុមារត្រូវបានទទួលការអនុញ្ញាតឱ្យធ្វើជាកូន ឪពុកម្តាយចិញ្ចឹមត្រូវផ្តល់របាយការណ៍អំពីស្ថានភាពវិវឌ្ឍន៍របស់កុមារមករដ្ឋបាលសុំកូនអន្តរប្រទេសជារៀងរាល់ ៦ (ប្រាំមួយ) ខែម្តង ក្នុងរយៈពេល ៣ (បី) ឆ្នាំ បន្ទាប់មកត្រូវផ្តល់របាយការណ៍ ១ ឆ្នាំម្តង រហូតដល់កុមារមានអាយុ ១៨ ឆ្នាំ ។

28k5

Kd

ឪពុកម្ដាយចិញ្ចឹមត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលសុំកូនអន្តរប្រទេសដោយផ្ទាល់ ឬ តាមរយៈអាជ្ញាធរកណ្ដាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ឬ ប្រទេសជាលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួនទៅតាមស្ថានភាពសមស្រប ។

**មាត្រា ៤៦.-**

រដ្ឋបាលសុំកូនអន្តរប្រទេស និង សាលាដំបូងរាជធានីភ្នំពេញ ត្រូវរក្សាទុកសំណុំឯកសារសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ (ហុកសិប) ឆ្នាំ គិតពីកាលបរិច្ឆេទដែលដីកាសម្រេចសុំកូនអន្តរប្រទេសនោះចូលជាស្ថាពរ ។

សំណុំឯកសារ និង កំណត់ហេតុទាំងអស់ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ទោះជារក្សាទុកនៅតុលាការ រដ្ឋបាលសុំកូនអន្តរប្រទេស ទីភ្នាក់ងារសុំកូនអន្តរប្រទេស មណ្ឌលកុមារកំព្រា និង អ្នកជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេសត្រូវរក្សាទុកជាការសម្ងាត់ ។ ក៏ប៉ុន្តែសំណុំឯកសារនិងកំណត់ហេតុ ឬ ព័ត៌មានទាំងឡាយដែលមាននៅក្នុងសំណុំឯកសារ និង កំណត់ហេតុទាំងនោះអាចនឹងត្រូវបញ្ចេញទៅតាមការស្នើសុំ ឬ ការបង្គាប់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរមានសមត្ថកិច្ច នៅក្នុង ឬ ក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីមានតម្រូវការទាក់ទងនឹងករណី ឬ នីតិវិធីតុលាការដែលកំពុងតែប្រព្រឹត្តទៅ ឬ កាលៈទេសៈពិសេសដទៃទៀត ។

ឪពុកម្ដាយចិញ្ចឹមអាចដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំច្បាប់ចម្លងនៃសំណុំលិខិត ដែលរួមមានអត្តសញ្ញាណរបស់ឪពុកម្ដាយបង្កើតរបស់កូនសុំក្រោយពីដីកាសម្រេចសុំកូនរបស់តុលាការចូលជាស្ថាពរ ។ កូនសុំដែលដល់អាយុដឹងខុសត្រូវគ្រប់គ្រាន់អំពីផលវិបាកនៃការដឹងអត្តសញ្ញាណរបស់ខ្លួន អាចត្រូវបានអនុញ្ញាតឱ្យមើលសំណុំលិខិតរបស់ខ្លួនរួមទាំងអត្តសញ្ញាណរបស់ឪពុកម្ដាយបង្កើតបាន ដោយធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកអាជ្ញាធរកណ្ដាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីការមើលនេះជាឧត្ដមប្រយោជន៍របស់កូនសុំ ។ កូនសុំដែលឈានចូលអាយុនីតិភាពមានសិទ្ធិមើលសំណុំឯកសារ និង កំណត់ហេតុទាក់ទងនឹងអត្តសញ្ញាណខ្លួន ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា កូនសុំទទួលបានការពិគ្រោះយោបល់សមស្របមុននឹងមើលព័ត៌មាននៅក្នុងសំណុំលិខិតរបស់ខ្លួន ។

29/35

## ជំពូកទី ៨

## ការផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារ

**មាត្រា ៤៧.-**

មានតែទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជា និង ពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល ស្របតាមមាត្រាជាបន្តបន្ទាប់ដូចខាងក្រោមប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស ។

ចំនួនទីភ្នាក់ងារមកពីប្រទេសទទួលនីមួយៗ ដែលអនុញ្ញាតឱ្យផ្តល់សេវានៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវកំណត់ដោយកិច្ចព្រមព្រៀងរួមគ្នាមួយរវាងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និង អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួល ។

**មាត្រា ៤៨.-**

ដើម្បីសុំការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារត្រូវមានលក្ខណសម្បត្តិដូចតទៅ ៖

១- មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល ។

២- មានទិសដៅមិនស្វែងរកផលចំណេញ និង បានបំពេញនូវលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ឬ បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារនោះ ។

៣- មានអ្នកដឹកនាំនិងមានបុគ្គលិកដែលមានសមត្ថភាពប្រកបដោយគុណធម៌ និង សីលធម៌ ព្រមទាំងបានទទួលការបណ្តុះបណ្តាល និង មានបទពិសោធន៍ធ្វើការងារក្នុងវិស័យសុំកូនអន្តរប្រទេស ។

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវបានអនុញ្ញាតឱ្យបើក ឬ យកមណ្ឌលកុមារកំព្រា ជាប្រភពដើម្បីផ្គត់ផ្គង់ទារក និង កុមារកំព្រា នៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

**មាត្រា ៤៩.-**

ទីភ្នាក់ងារនីមួយៗត្រូវបានចុះបញ្ជីតាមបទប្បញ្ញត្តិច្បាប់ជាធរមាន របស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ឬ បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត ទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារនោះ មុនពេលដាក់ពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច តាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេស ។ ទីភ្នាក់ងារសុំកូនអន្តរប្រទេសត្រូវចុះកិច្ចសន្យាស្តីពីប្រតិបត្តិការសុំកូនអន្តរប្រទេស និង បំពេញបែបបទផ្សេងៗទៀត តាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

**មាត្រា ៥០.-**

ពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស នៅព្រះរាជាណាចក្រកម្ពុជា ដែលដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម:

១- ពាក្យសុំការអនុញ្ញាតដោយមានការយល់ព្រម និង ទទួលស្គាល់ពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

២- ឯកសារសង្ខេបអំពីប្រវត្តិ និង សកម្មភាពរបស់ទីភ្នាក់ងារ ។

៣- ច្បាប់ចម្លងដែលមានបញ្ជាក់ត្រឹមត្រូវអំពីការអនុញ្ញាតឱ្យបើកទីភ្នាក់ងារពីប្រទេសទទួលរបស់ខ្លួន ចំពោះទីភ្នាក់ងារអន្តរជាតិ ។

៤- ច្បាប់ចម្លងលិខិតចុះបញ្ជីដែលមានបញ្ជាក់ត្រឹមត្រូវដូចមានចែងក្នុងមាត្រា ៤៩ នៃច្បាប់នេះ ។

៥- លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងរបស់ទីភ្នាក់ងារ ។

៦- ជីវប្រវត្តិសង្ខេបនិងរូបថតរបស់សមាជិកក្រុមប្រឹក្សាភិបាល ឬ គណៈគ្រប់គ្រង ។

៧- ជីវប្រវត្តិសង្ខេបរបស់បុគ្គលដែលបានទទួលការអនុញ្ញាតឱ្យធ្វើជាអ្នកតំណាងទីភ្នាក់ងារចំពោះកិច្ចការសុំកូនអន្តរប្រទេស ។ អ្នកតំណាងទាំងនេះមិនត្រូវឱ្យលើសពីពីរនាក់ និងមិនមែនជានាយក នាយករង ឬ បុគ្គលិកនៃមណ្ឌលកុមារកំព្រាណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

31/25

៨- ឯកសារភស្តុតាងនានាដែលបញ្ជាក់ថាអ្នកតំណាងដូចមានចែងក្នុងចំណុចទី ៧ ខាងលើ គ្មានជាប់ឈ្មោះក្នុងបញ្ជីថ្កោលទោសនៅប្រទេសដើមរបស់ខ្លួន និង នៅប្រទេសចុងក្រោយដែលខ្លួនរស់នៅ ក្នុងករណីប្រទេសខុសគ្នា ។

៩- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសុំកូនអន្តរប្រទេស រវាងព្រះរាជាណាចក្រកម្ពុជា និង ប្រទេសរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ក្នុងករណីដែលប្រទេសនោះមិនមែនជារដ្ឋភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសទេ ។

១០- របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មឯករាជ្យ និង កិច្ចព្រមព្រៀងផ្តល់ជំនួយមនុស្សធម៌ ឬ ការជួយឧបត្ថម្ភដល់កុមារកំព្រានានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

១១- តម្រូវការផ្សេងៗទៀតដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចយល់ថាចាំបាច់ ដើម្បីជាឧត្តមប្រយោជន៍របស់កុមារ ដូចមានចែងនៅក្នុងនីតិវិធីទាក់ទងនឹងការផ្តល់ការអនុញ្ញាត ។

ច្បាប់ចម្លងចំនួនមួយច្បាប់នៃពាក្យសុំ និង សំណុំលិខិតសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារ ត្រូវធ្វើជូនស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួល ដែលទីភ្នាក់ងារធ្វើប្រតិបត្តិការនៅទីនោះ ។

**មាត្រា ៥១.-**

ក្នុងកំឡុងពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅទីភ្នាក់ងារវិញអំពីការសម្រេចជាផ្លូវការរបស់ខ្លួន ។ ក្នុងករណីមានការបដិសេធ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវបញ្ជាក់អំពីមូលហេតុឱ្យ បានច្បាស់លាស់ ។

**មាត្រា ៥២.-**

មានតែអ្នកតំណាងដែលមានឈ្មោះក្នុងសំណុំឯកសារពាក្យសុំការអនុញ្ញាតតែប៉ុណ្ណោះដែលមានសិទ្ធិធ្វើជាអ្នកតំណាងទីភ្នាក់ងារនៅក្នុងដំណើរការសុំកូនអន្តរប្រទេស ។ ក្នុងករណីអ្នកតំណាងដែលបានទទួលការអនុញ្ញាត ត្រូវជំនួសដោយអ្នកផ្សេងនោះ ទីភ្នាក់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

32/35

ងារត្រូវដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំការអនុញ្ញាតជាថ្មីឡើងវិញ។

**មាត្រា ៥៣.-**

ការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ត្រូវផ្តល់ឱ្យសម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ ហើយអាចអនុញ្ញាតឱ្យបន្តទៀតបាន ដោយទីភ្នាក់ងារត្រូវដាក់ពាក្យសុំសាជាថ្មី និង ត្រូវបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៤៨ មាត្រា ៤៩ និង មាត្រា ៥០ នៃច្បាប់នេះ ដរាបណាសេវារបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស នៅតែចាំបាច់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៩
## ទោសប្បញ្ញត្តិ

**មាត្រា ៥៤.-**

ដោយមិនទាន់គិតដល់ទោសប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ជាធរមាន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចព្យួរ ឬ ដកហូតការទទួលស្គាល់ ឬ បដិសេធការទទួលស្គាល់ ទីភ្នាក់ងារសុំកូនអន្តរប្រទេសសាជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញឱ្យឃើញថា ទីភ្នាក់ងារសុំកូនអន្តរប្រទេស ជាប់ពាក់ព័ន្ធនឹងអំពើណាមួយដូចតទៅ :

១- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ឱ្យឪពុកម្តាយ ឬ ឪពុក ឬ ម្តាយបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើត ដើម្បីឱ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស ។

២- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ឪពុកម្តាយ ឬឪពុក ឬ ម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត ។

៣- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឱ្យអ្នកសុំ ។

ROYAUME DU CAMBODGE · LE MINISTERE DU PALAIS ROYAL

37/35

៤- អំពើក្លែងបន្លំ ឬ សមគំនិតក្លែងបន្លំស្ថានភាពលំបាកបំផុត ដើម្បីទទួលបានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ ឪពុកបង្កើត ឬ ម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

៥- អំពើរៀបចំឱ្យមានការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារដោយការបង្ខិតបង្ខំ ការគំរាមកំហែង ការឆបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬ សន្យាផ្តល់ប្រាក់ រង្វាន់ សំណង ឬ ផលប្រយោជន៍ណាមួយ ។

៦- ការបញ្ចេញសំណុំឯកសារ និង កំណត់ហេតុទាំងអស់ ឬ មួយផ្នែកទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ដោយគ្មានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ឬ តុលាការមានសមត្ថកិច្ច ។

៧- ការបង្គាប់ ឬ ការទទួលដោយផ្ទាល់ ឬ ដោយប្រយោល នូវថ្នូរប្រាក់កាស ទំនិញ ឬ សេវា ដោះដូរនឹងការបម្រុងទុកកុមារណាមួយសម្រាប់សុំកូន ។

៨- ការផ្តល់ប្រាក់កាស ទំនិញ ឬ សេវាទៅឱ្យមន្ត្រី ឬ អ្នកតំណាងណាមួយនៃរដ្ឋបាលសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាជ្ញាធរកណ្តាលទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ឬ មន្ត្រីពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យផ្តល់នូវសិទ្ធិជាអាទិភាពនៅក្នុងនីតិវិធីសុំកូនអន្តរប្រទេសដល់អ្នកសុំ ។

៩- ការផ្សាយពាណិជ្ជកម្ម ឬ ការបោះពុម្ពផ្សាយនូវអត្តសញ្ញាណ ឬ រូបថតរបស់កុមារណាមួយដែលជាកម្មវត្ថុសុំកូន ក្នុងគោលបំណងបញ្ចុះបញ្ចូលបុគ្គលណាមួយឱ្យដាក់ពាក្យសុំកូន ។

១០- ការតែងតាំង ឬ ចាត់តាំងអ្នកតំណាងណាមួយដោយមិនមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

១១- ការចូលរួមក្នុងការរៀបចំការផ្គូផ្គង ឬ ការទាក់ទងគ្នារវាងអ្នកសុំ និង ឪពុកម្តាយបង្កើត ឬ ឪពុកបង្កើត ឬ ម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារក្នុង គោលបំណងកំណត់ទុកជាមុននូវកុមារណាមួយដែលនឹងត្រូវសុំ ។

១២- ការរំលោភបំពានដល់បទប្បញ្ញត្តិនៃច្បាប់នេះ បទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារ និង បទប្បញ្ញត្តិផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE · PALAIS ROYAL · LE MINISTRE DU PALAIS

34/35

មាត្រា ៥៥.-

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនអនុវត្តតាមកថាខណ្ឌទី ១ មាត្រា ៤៧ ឬ កថាខណ្ឌទី ២ មាត្រា ៤៨ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។ ការដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ប្រាក់ពិន័យអន្តរការណ៍នេះត្រូវបង់ចូលទៅក្នុងមូលនិធិសម្រាប់ទ្រទ្រង់វិស័យសុខុមាលភាពកុមារ ។

ក្នុងករណីទីភ្នាក់ងារមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍នេះទេ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចបញ្ជូនសំណុំរឿងទៅតុលាការ ។

**មាត្រា ៥៦.-**

បទល្មើសពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៥៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥៨.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩

នស/រកម.០៩១២.០១៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ហត្ថលេខា

អ៊ិត សំហេង

លេខ ១០៥៩ ច.ល
ជូនចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០០៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៩ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការសុំទារកកំព្រា ឬ កុមារកំព្រាយកទៅចិញ្ចឹមជាកូននៅបរទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យ លេខ ៥៦ ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីតាមសម័យប្រជុំ ថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០១ ។

## សំ រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ កំណត់សមត្ថកិច្ច ល័ក្ខខណ្ឌ និងនីតិវិធី នៃការសុំទារកកំព្រា ឬកុមារកំព្រា យកទៅចិញ្ចឹមបីបាច់ជាកូន នៅក្រៅប្រទេស ។

## ជំពូកទី ២

## សមត្ថកិច្ច លក្ខខណ្ឌ និងនីតិវិធីនៃការសុំទារកកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមនៅបរទេស

២. –

ជនបរទេសជាសាមីអ្នកស្នើសុំទារកកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមបីបាច់ជាកូននៅបរទេស ត្រូវបំពេញលក្ខខណ្ឌ និងនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យនេះ ។

៣. –

សាមីអ្នកស្នើសុំជាប្ដីប្រពន្ធត្រូវបានរៀបអាពាហ៍ពិពាហ៍ និងមានអាយុពី ២៥ ឆ្នាំ ដល់ ៥៥ ឆ្នាំ ។ ចំពោះអ្នកនៅលីវ អាចអនុញ្ញាតឱ្យសុំបានតែអ្នកនៅលីវដែលមានអាយុចាប់ពី ៤០ ឆ្នាំ ដល់ ៥០ ឆ្នាំ ។ ចំពោះសាមីអ្នកស្នើសុំមិនអាចសុំកូនយកទៅចិញ្ចឹមលើសពី ២ នាក់ បានឡើយ ។ ត្រូវបានអនុញ្ញាតឱ្យសុំកូនបាន លុះត្រាតែអ្នកស្នើសុំគ្មានកូន ឬមានកូនមិនលើសពី ២ នាក់ ។

៤. –

សាមីអ្នកស្នើសុំត្រូវសរសេរពាក្យសុំទៅក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយមានភ្ជាប់ឯកសារ ដូចខាងក្រោម :

- ទំរង់ពាក្យសុំ
- លិខិតអនុញ្ញាតឱ្យសុំកូនចិញ្ចឹមពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសាមីរបស់សាមីអ្នកស្នើសុំ
- របាយការណ៍ស្ដីពីស្ថានភាពគ្រួសារ ដោយមានបញ្ជាក់ពីចំនួនសមាជិកគ្រួសារ ដែលធ្វើដោយភ្នាក់ងារមានជំនាញលើការងារនេះ ហើយមានការទទួលស្គាល់ពីក្រសួងមានសមត្ថកិច្ច នៃប្រទេសសាមី របស់សាមីអ្នកស្នើសុំ
- សេចក្ដីចម្លងសំបុត្រកំណើត ឬវិញ្ញាបនប័ត្រកំណើតរបស់សាមីអ្នកស្នើសុំ
- សេចក្ដីចម្លងលិខិតអាពាហ៍ពិពាហ៍ ឬលិខិតលែងលះគ្នា ឬលិខិតបញ្ជាក់ថានៅលីវ
- លិខិតបញ្ជាក់អំពីសុខភាពរបស់សាមីអ្នកស្នើសុំ
- របាយការណ៍ស្ដីពីចិត្តវិទ្យាធ្វើឡើងដោយគ្រូពេទ្យចិត្តវិទ្យា ដែលទទួលស្គាល់ដោយរដ្ឋាភិបាលនៃប្រទេសសាមី របស់សាមីអ្នកស្នើសុំ
- លិខិតបញ្ជាក់ថាគ្មានទោស ចេញដោយអាជ្ញាធរក្នុងប្រទេសកំណើត ឬកន្លែងដែលសាមីអ្នកស្នើសុំបានរស់នៅ ឬ សំបុត្រថ្កោលទោសចេញដោយក្រសួងមានសមត្ថកិច្ច
- លិខិតបញ្ជាក់អំពីកិរិយាមារយាទ នៅក្នុងកន្លែងប្រកបការងារ និងនៅក្នុងសង្គមរស់នៅ ចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- សេចក្ដីបញ្ជាក់អំពីស្ថានភាពហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាមីអ្នកស្នើសុំ ចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- កិច្ចសន្យាគោរពសិទ្ធិជាកូន និងផ្ដល់ការសិក្សា ព្រមទាំងសិទ្ធិទទួលកេរ្ដិ៍មរតក ដូចកូនបង្កើតរបស់ខ្លួន

- រូបថតរបស់សាមីអ្នកស្នើសុំ យកក្នុងកំឡុងពេលពីរខែចុងក្រោយ
- កិច្ចសន្យារបស់សាមីអ្នកស្នើសុំ ស្តីពីការផ្តល់ពត៌មានលើការចិញ្ចឹមកូន ចាប់ពីពេលដែលយកកូនចិញ្ចឹមចេញពីប្រទេសកម្ពុជាមួយឆ្នាំម្តង១ រហូតដល់អាយុ ១៨ ឆ្នាំ មកក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ហើយរបាយការណ៍នោះត្រូវបានត្រួតពិនិត្យ និងបញ្ជាក់ពីភាពត្រឹមត្រូវ ដោយក្រសួងមានសមត្ថកិច្ចខាងការងារសុំកូនចិញ្ចឹម នៃប្រទេសរបស់សាមីអ្នកស្នើសុំ ហើយចម្លងជូនទៅស្ថានទូតខ្មែរដែលប្រចាំនៅប្រទេសសាមីអ្នកស្នើសុំ
- សេចក្តីចំលងលិខិតឆ្លងដែនរបស់សាមីអ្នកស្នើសុំ
- លិខិតបញ្ជាក់ពីស្ថានទូតនៃប្រទេសរបស់សាមីអ្នកស្នើសុំ ចំពោះឯកសារទាំងអស់ខាងលើពីភាពត្រឹមត្រូវ ។

ប្រការ ៥ . -

ទារកកំព្រា ឬកុមារកំព្រាដែលត្រូវបានអនុញ្ញាតឱ្យសុំយកទៅចិញ្ចឹម ត្រូវមានលក្ខណៈវិនិច្ឆ័យ និងសំណុំលិខិតដូចខាងក្រោមៈ

ក- មានអាយុក្រោម ៨ ឆ្នាំ

ខ- រស់នៅក្រោមការថែទាំរបស់មជ្ឈមណ្ឌលកុមារកំព្រារដ្ឋ ឬមណ្ឌលឯទៀតដែលគ្រប់គ្រងដោយ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

គ- រស់នៅក្នុងមណ្ឌលអស់រយៈពេល ៣ ខែ យ៉ាងតិចមុនពេលត្រូវបានស្នើសុំ

ឃ- ត្រូវមានសំបុត្រកំណើតដែលចេញឱ្យដោយមន្ត្រីអត្រានុកូលដ្ឋាន

ង- ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ពីសុខភាពកាយសម្បទា ដែលចេញដោយវេជ្ជបណ្ឌិតមានសមត្ថកិច្ច ធ្វើការក្នុងមន្ទីរពេទ្យរដ្ឋ ឬគ្លីនិកផ្សេងទៀតដែលរដ្ឋទទួលស្គាល់ ។

ប្រការ ៦. -

ការជ្រើសរើសកូនត្រូវធ្វើឡើងតាមបញ្ជីរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានរៀបចំ និងត្រូវបានការឯកភាពពីអ្នកសុំកូនយកទៅចិញ្ចឹម ។ អ្នកស្នើសុំមានសិទ្ធិទៅមើលទារកកំព្រា ឬកុមារកំព្រាក្នុងមណ្ឌល មុនពេលធ្វើការសំរេចចិត្តថា ទទួលយក ឬមិនទទួលយក ។

ប្រការ ៧. -

ឯកសារស្នើសុំកូនទាំងអស់ត្រូវផ្ញើមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈស្ថានទូតនៃប្រទេសសាមីប្រចាំនៅកម្ពុជា ។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យលើសំណុំឯកសារទាំងអស់ដែលមានចែងក្នុងមាត្រា ៣ និងមាត្រា ៤ នៃអនុក្រឹត្យនេះ ក្នុងរយៈពេល ១៥ ថ្ងៃ ។ ប្រសិនបើសំណុំលិខិតរបស់សាមីអ្នកស្នើសុំមិនគ្រប់គ្រាន់ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចបដិសេធ ឬបញ្ជូនសំណុំឯកសារទៅឱ្យសាមីអ្នកស្នើសុំ ដើម្បីបំពេញសំណុំឯកសារឱ្យបានត្រឹមត្រូវឡើងវិញ ។ ក្រោយពីបានពិនិត្យរួចរាល់ហើយ ត្រូវធ្វើលិខិតបញ្ជាក់យោបល់របស់ក្រសួង អមជាមួយសំណុំឯកសារពាក់ពន្ធ័ទាំងអស់ បញ្ជូនមកក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

ភា ៨.-

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវពិនិត្យលើលក្ខខ័ណ្ឌ និងបែបបទនានា ដែលសាមីអ្នកស្នើសុំបានបំពេញដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ក្នុងរយៈពេល ២ ខែ ។ ក្រោយពីបានពិនិត្យសព្វគ្រប់ហើយ ត្រូវធ្វើលិខិតបញ្ជាក់អំពីយោបល់របស់ក្រសួង បញ្ជូនអមជាមួយសំណុំលិខិតពាក់ពន្ធ័ទាំងអស់ មកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសុំសេចក្តីសំរេចពីរាជរដ្ឋាភិបាល ។

ភា ៩.-

ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវពិនិត្យសំណុំលិខិត និងដាក់ឆ្លងប្រមុខរាជរដ្ឋាភិបាលក្នុងរយៈពេល ១៥ ថ្ងៃ ហើយត្រូវបញ្ជូនលិខិតយល់ព្រម ទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីធ្វើលិខិតបញ្ជាក់ស្តីពីការសុំកូនចិញ្ចឹម និងជូនពត៌មានទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីអញ្ជើញសាមីអ្នកស្នើសុំមកកាន់ប្រទេសកម្ពុជា តាមរយៈស្ថានទូតនៃប្រទេសសាមីប្រចាំនៅកម្ពុជា ។ ការសំរេចជាវិជ្ជមាន ឬអវិជ្ជមាន ជាឆន្ទានុសិទ្ធិរបស់រាជរដ្ឋាភិបាល ។

ភា ១០.-

ក្រោយពីបានទទួលសេចក្តីជូនដំណឹងស្តីពីការសំរេចយល់ព្រម ពីរាជរដ្ឋាភិបាល ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវចេញលិខិតបញ្ជាក់ស្តីពីការសុំកូនចិញ្ចឹម ជូនសាមីអ្នកស្នើសុំកូនចិញ្ចឹម ។

ការប្រគល់ទារកកំព្រា ឬកុមារកំព្រាជូនឪពុក និងឬ ម្តាយចិញ្ចឹម ត្រូវធ្វើជាផ្លូវការនៅចំពោះមុខមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ជាអ្នកសំរបសំរួល ។ ឪពុក និងឬ ម្តាយចិញ្ចឹម ត្រូវមានវត្តមាន ទទួលកូនដោយផ្ទាល់ក្នុងពេលនោះ ។ មិនអនុញ្ញាតឱ្យប្រគល់ទារកកំព្រា ឬកុមារកំព្រា តាមរយៈភ្នាក់ងារកណ្តាលណាមួយឡើយ ។

ភា ១១.-

ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវបន្តតាមដានពត៌មានជួយគាំពារកូនចិញ្ចឹមសញ្ជាតិដើមកម្ពុជា រហូតដល់កុមារកំព្រារូបនោះ មានអាយុ ១៨ ឆ្នាំ ។

## ជំពូកទី ៣

## អំពីបន្ទុករបស់សាមីអ្នកស្នើសុំកូន

ភា ១២.-

សាមីអ្នកស្នើសុំកូនចិញ្ចឹមទាំងអស់ ត្រូវមានបន្ទុកចំណាយដូចតទៅ :

- ធ្វើលិខិតឆ្លងដែនសំរាប់ទារកកំព្រា ឬកុមារកំព្រា ដែលសាមីខ្លួនបានស្នើសុំ
- រ៉ាប់រងការចំណាយទាំងអស់ក្នុងការចាកចេញរបស់ទារកកំព្រា ឬកុមារកំព្រា ។

ភា ១៣.-

សាមីអ្នកស្នើសុំកូនអាចរួមធ្វើវិភាគទានសប្បុរសធម៌ តាមការស្ម័គ្រចិត្ត ជូនក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សំរាប់ជាផលប្រយោជន៍របស់ទារកកំព្រា ឬកុមារកំព្រា ។

មាត្រា ១៤.-

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានភារកិច្ចគ្រប់គ្រង ប្រើប្រាស់ថវិកាវិភាគទានសប្បុរសធម៌នេះ តាមបទប្បញ្ញត្តិជាធរមាន និងដោយតម្លាភាព ។

ជំពូកទី ៤

អវសានប្បញ្ញត្តិ

មាត្រា ១៥.-

បទប្បញ្ញត្តិទាំងឡាយ ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួង ស្ថាប័នពាក់ពន្ធ័ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ... ឆ្នាំ ២០០១

... សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

អ៊ិត សំហេង

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង / កាល័យព្រះមហាក្សត្រ
- លេខាធិការដ្ឋានព្រឹទ្ធសភា
- លេខាធិការដ្ឋានរដ្ឋសភា
- សួងព្រះបរមរាជវាំង
- កាល័យសម្តេចនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ់ក្រសួង-ស្ថាប័ន
- ប់សាលាខេត្ត-ក្រុង
- មាត្រា ១៦
- សារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ១៩៤ ស.អ.យ.

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ [illegible] ឆ្នាំ២០១៣

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាល សុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា

---

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន. និងយុវនីតិសម្បទា
- បានឃើញអនុសញ្ញាស្តីពីសិទ្ធិកុមារដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា បានសុំចូលជាភាគីនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញព្រះរាជក្រម នស / រកម / ០១០៧ / ០០៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១២០៩ / ០២៤ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសុំកូនអន្តរប្រទេស
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

### ប្រការ ១.-

ប្រកាសនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា មានអក្សរកាត់ថា " **អ . ក . ស . ក** " ជាភាសាអង់គ្លេស " Central Authority for Inter-country Adoption ( C . A . I . A )។



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086

## ប្រការ ២.-

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បំពេញតួនាទីជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាស្របតាមមាត្រា ៦ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស។

## ប្រការ ៣.-

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចដូចតទៅ៖

១- រៀបចំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងការសម្រេចលើកិច្ចការសុំកូនអន្តរប្រទេស។

២- ធ្វើសហប្រតិបត្តិការ និងសម្របសម្រួលលើការប្រាស្រ័យទាក់ទងគ្នាទៅនឹងកិច្ចការសុំកូនអន្តរប្រទេសជាមួយក្រសួង ស្ថាប័ន និងទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងជាមួយអាជ្ញាធរកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។

៣- ចាត់វិធានការសមស្របដើម្បីបង្ការ និងទប់ស្កាត់ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬផលចំណេញផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស។

៤- រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការសុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ។

៥- ពិនិត្យលើសំណើរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសនីមួយៗតាមការចាំបាច់។

៦- ធ្វើអធិការកិច្ចលើការងារទាំងឡាយដែលពាក់ព័ន្ធជាមួយសុំកូនអន្តរប្រទេស។ គ្មានជនណាអាចរារាំង បង្អាក់ ឬ ជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ។

៧- ចាត់វិធានការដ៏សមស្របដើម្បីប្រមូល រក្សាការពារ និងផ្លាស់ប្តូរព័ត៌មានអំពីស្ថានភាពរបស់កុមារ និងរក្សាទុកព័ត៌មានទាក់ទងនឹងប្រភពកំណើតរបស់កុមារ អត្តសញ្ញាណរបស់កុមារ ឪពុកម្តាយកុមារ និងប្រវត្តិសុខភាពកុមារ។

៨- រក្សា និងផ្តល់ស្ថិតិទាក់ទងនឹងសុំកូនអន្តរប្រទេសដល់ប្រទេសនានាតាមសំណើ។

៩- ទទួលប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាពីអ្នកសុំកូនត្រូវបង់តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេស ឬអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។

១០-ទទួលខុសត្រូវក្នុងការកត់ត្រា តាមដានប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាដែលប្រមូលបាន និងបង់ប្រាក់ចូលក្នុងគណនីប្រាក់បញ្ញើរបស់គណៈកម្មាធិការគ្រប់គ្រង និងចាត់ចែងប្រាក់វិភាគទានមនុស្សធម៌នៅរតនាគារជាតិ។

១១-ធ្វើរបាយការណ៍ស្តីពីស្ថានភាពប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាដែលប្រមូលបាន និងបង់ប្រាក់ចូលក្នុងគណនីប្រាក់បញ្ញើនៅរតនាគារជាតិជារៀងរាល់ខែ ត្រីមាស និងប្រចាំឆ្នាំជូនគណៈកម្មាធិការគ្រប់គ្រង និងចាត់ចែងប្រាក់វិភាគទានមនុស្សធម៌។

១២-ពិនិត្យ ផ្តល់អនុសាសន៍ និងបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេសនីមួយៗទៅតុលាការ។

១៣- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យល់ ថាចាំបាច់សម្រាប់អនុវត្តកិច្ចការសុំកូនអន្តរប្រទេស ដោយអនុលោមទៅតាមច្បាប់ និងបទ បញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.–**

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយគណៈកម្មាធិការអាជ្ញាធរ កណ្តាលសុំកូនអន្តរប្រទេស។

**ប្រការ ៥.–**

គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស មានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលបន្ទុកវិស័យសុខុមាលភាពកុមារ | អនុប្រធាន |
| ៣- អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៤- អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុ | សមាជិក |
| ៥- នាយកខុទ្ទកាល័យរដ្ឋមន្ត្រី | សមាជិក |
| ៦- តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | សមាជិក |
| ៧- អ្នកជំនាញការជាតិលើវិស័យសុខុមាលភាពកុមារ | សមាជិក |
| ៨- ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ | សមាជិក |
| ៩- ប្រធានរដ្ឋបាលសុំកូនអន្តរប្រទេស | អគ្គលេខាធិការ |

ការតែងតាំងសមាសភាពគណៈកម្មាធិការអាជ្ញាធរកណ្តាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ប្រការ ៦.–**

គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

១- ពិនិត្យ និងសម្រេចចុងក្រោយពាក់ព័ន្ធនិងនីតិវិធីសុំកូនអន្តរប្រទេស។

២- ពិនិត្យ និងផ្តល់អនុសាសន៍តាមការចាំបាច់លើគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធី ទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស។ តាមដាន ត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងសុំកូនអន្តរប្រទេស។

៣- ធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយ កិច្ចការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអាជ្ញាធរកណ្តាល និង អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។

៤- ចាត់វិធានការសមស្របដើម្បីបង្ការ ទប់ស្កាត់ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិន សមស្រប ឬផលចំណេញផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស។

៥- ពិនិត្យ និងផ្តល់អនុសាសន៍លើសកម្មភាពបណ្តុះបណ្តាលជំនាញដល់មន្ត្រីពាក់ព័ន្ធ និងអ្នក ពាក់ព័ន្ធផ្សេងទៀតលើការងារសុំកូនអន្តរប្រទេស។

៦- ពិនិត្យ សម្រេចលើសំណើផ្គូផ្គងកុមារនឹងអ្នកសុំដែលស្នើឡើងដោយរដ្ឋបាលសុំកូនអន្តរប្រទេស និងផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។



2-b

៧-ពិនិត្យ និងអនុម័តគម្រោងថវិកា ប្រាក់ចំណាយ សោហ៊ុយ ស្របតាមច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស និងសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

៨- ទាក់ទង និងធ្វើសហប្រតិបត្តិការជាមួយការិយាល័យអចិន្ត្រៃយ៍នៃសន្និសីទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិឯកជនពាក់ព័ន្ធនឹងការងារស្មុំកូនអន្តរប្រទេស អង្គការអន្តរជាតិពាក់ព័ន្ធ និងប្រទេសដែលមានទំនាក់ទំនងសហប្រតិបត្តិការលើវិស័យស្មុំកូនអន្តរប្រទេស ជាមួយព្រះរាជាណាចក្រកម្ពុជា។

៩- អនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាប្រគល់ជូន។

## ប្រការ ៧.–

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រង ចាត់ចែងវិភាគទានមនុស្សធម៌នៃអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេស ដែលរួមមានសមាសភាពគណៈកម្មាធិការអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេស បន្ថែមតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប។ សមាសភាពតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំណត់ដោយលិខិតរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ប្រការ ៨.–

របៀបរបបធ្វើការរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេស៖

-គណៈកម្មាធិការអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេសបើកសម័យប្រជុំ ដើម្បីពិនិត្យឲ្យយោបល់លើករណីស្មុំកូននីមួយៗ និងពិនិត្យឲ្យយោបល់ក្នុងការរៀបចំត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាំងឡាយទាក់ទងនឹងស្មុំកូនអន្តរប្រទេស និងអនុវត្តភារកិច្ចដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ។

-ការប្រជុំ និងការសម្រេចរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេសអាចយកជាការបានលុះត្រាតែមានសមាជិកចូលរួមយ៉ាងតិច ៥០%+១ នៃសមាជិកគណៈកម្មាធិការទាំងអស់។

-ការប្រជុំត្រូវដឹកនាំដោយប្រធានគណៈកម្មាធិការ ក្នុងករណីប្រធានអវត្តមាន អាចប្រគល់សិទ្ធិឲ្យអនុប្រធានដឹកនាំជំនួស។

-ការសម្រេចរបស់អង្គប្រជុំទាំងអស់ត្រូវអនុម័តដោយសំឡេងភាគច្រើននៃសមាជិកអង្គប្រជុំ ករណីមានសំឡេងស្មើគ្នា សំឡេងប្រធានមានឧត្តមានុភាព។

-ផ្អែកលើសារៈសំខាន់នៃបញ្ហានីមួយៗ ប្រធានគណៈកម្មាធិការអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេសអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គការ និងជនពាក់ព័ន្ធដទៃទៀតឲ្យចូលរួមយោបល់តាមការចាំបាច់។

-គណៈកម្មាធិការអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេស ត្រូវប្រជុំមួយខែម្តង ឬញឹកញាប់ជាងនេះទៅតាមការចាំបាច់។

## ប្រការ ៩.–

ត្រូវបានបង្កើតរដ្ឋបាលស្មុំកូនអន្តរប្រទេស មានអក្សរកាត់ថា " រ.ស. អ. " ជាភាសាអង់គ្លេស " Inter- country Adoption Administration ( I . C . A .A ) " ដើម្បីធ្វើជាសេនាធិការរបស់អាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេស។

៤ៃ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ១៤៣០ ស.អ.យ.

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៤

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស

---

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុសញ្ញាស្តីពីសិទ្ធិកុមារដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា បានចុះហត្ថលេខាថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញព្រះរាជក្រម នស/រកម/០១០៧/០០៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសុំកូនអន្តរប្រទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ១៩៥ សអយ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

### ប្រការ១.-

ប្រកាសនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស មានអក្សរកាត់ជា " រ.ស.អ. " ជាភាសាអង់គ្លេស " Inter- Country Adoption Administration (I.C.A.A) "។



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាគារលេខ ៧៨៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ. ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២ ៦១ ០០.

**ប្រការ២.-**

រដ្ឋបាលសុំកូនអន្តរប្រទេសមានភារកិច្ចដូចខាងក្រោម៖

១-រៀបចំ ថែរក្សា និងធ្វើបច្ចុប្បន្នភាពបញ្ជីសម្ងាត់ និងសំណុំឯកសាររបស់កុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស។

២-ធ្វើការប៉ាន់ប្រមាណស្ថានភាពកុមារទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីសម្ងាត់ ដើម្បីកំណត់ទម្រង់នៃការចិញ្ចឹមថែទាំសមស្របបំផុតសម្រាប់កុមារ និងធានាថាកុមារទាំងនោះទទួលបានការចិញ្ចឹមថែទាំតាមតម្រូវការ។

៣-ធ្វើការផ្ទៀងផ្ទាត់អំពីការខិតខំប្រឹងប្រែង ដោយអស់លទ្ធភាពក្នុងដំណោះស្រាយនៅក្នុងប្រទេស តាមរយៈការថែទាំជាអចិន្ត្រៃយ៍នៅតាមគ្រួសារ ឬជាមួយអ្នកអាណាព្យាបាលមុនដាក់ដំណើរការសុំកូនអន្តរប្រទេស។

៤-ទទួលពិនិត្យ និងចាត់ការពាក្យសុំកូនអន្តរប្រទេស និងឯកសារពាក់ព័ន្ធផ្សេងៗទៀតរបស់អ្នកសុំ។

៥-ផ្គូផ្គងកុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស ជាមួយអ្នកសុំដែលអាចបំពេញតម្រូវការដ៏ល្អបំផុតរបស់កុមារ ស្របតាមគោលការណ៍នៃឧត្តមប្រយោជន៍របស់កុមារ ហើយលើកយោបល់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពិនិត្យសម្រេច។

៦-ជូនដំណឹងអំពីនីតិវិធីសុំកូន និងការវិវឌ្ឍនៃករណីសុំកូនទៅអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួល ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតពីប្រទេសទទួល។

៧-រៀបចំពិធីប្រគល់កុមារឲ្យទៅអ្នកសុំ និងរៀបចំឯកសារដើម្បីឲ្យកុមារធ្វើដំណើរចូលទៅប្រទេសរបស់អ្នកសុំ។

៨-ផ្តល់ ឬសម្របសម្រួលការផ្តល់សេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារអ្នកសុំនិងគ្រួសារបង្កើតតាមការចាំបាច់។

៩-ផ្តល់យោបល់ជូនគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ទាក់ទងនឹងការអនុញ្ញាត ឬដកហូតការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១០-អនុវត្តគោលការណ៍ណែនាំរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាល ដើម្បីធ្វើអធិការកិច្ចលើកិច្ចការសុំកូនអន្តរប្រទេស។ គ្មានជនណាអាចរារាំង បង្អាក់ បំភិតបំភ័យ ឬជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ។

១១-លើកសំណើសុំការសម្រេចពីគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ដើម្បីចាត់វិធានការព្រមាន ដាក់កំហិត ឬដាក់ពិន័យចំពោះបុគ្គល ឬអង្គភាពដែលប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងៗទៀត។

១២-ពិនិត្យឯកសារទាក់ទងនឹងសុំកូនអន្តរប្រទេស និងផ្តល់យោបល់សមស្របជូនប្រធានគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនិងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពិនិត្យសម្រេច ។

១៣-រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុរាល់ការប្រជុំរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

១៤-គ្រប់គ្រងថវិកាចំណូលរបស់រដ្ឋបាលសុំកូនអន្តរប្រទេស រៀបចំធ្វើផែនការចំណាយ និងធ្វើរបាយការណ៍ហិរញ្ញវត្ថុស្តីពីស្ថានភាពប្រើប្រាស់ថវិកាជារៀងរាល់ខែ ត្រីមាស និងប្រចាំឆ្នាំជូនអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

១៥-រៀបចំផែនការ កម្មវិធី និងសកម្មភាពបណ្តុះបណ្តាលជំនាញដល់មន្ត្រីធ្វើការងារសុំកូនអន្តរប្រទេស និងអ្នកពាក់ព័ន្ធផ្សេងទៀត។

១៦-ចាត់វិធានការសមស្របក្នុងការប្រមូល ថែរក្សា និងផ្លាស់ប្តូរព័ត៌មានស្តីពីស្ថានភាពកុមារ ព័ត៌មានដើមកំណើតកុមារ អត្តសញ្ញាណឪពុកម្តាយ និងប្រវត្តិសុខភាពកុមារ ។

១៧-បំពេញភារកិច្ចចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

## ប្រការ៣.-

រដ្ឋបាលសុំកូនអន្តរប្រទេស ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

## ប្រការ៤.-

រដ្ឋបាលសុំកូនអន្តរប្រទេសមានរចនាសម្ព័ន្ធដូចខាងក្រោម៖

១-ការិយាល័យ រដ្ឋបាល និងហិរញ្ញវត្ថុ

២-ការិយាល័យ គ្រប់គ្រងទិន្នន័យ និងតម្កល់ឯកសារ

៣-ការិយាល័យ អនុវត្តនីតិវិធីសុំកូនអន្តរប្រទេស

៤-ការិយាល័យ អភិវឌ្ឍ គ្រប់គ្រងទីភ្នាក់ងារ និងអធិការកិច្ច

៥-ការិយាល័យ សហប្រតិបត្តិការអន្តរជាតិ

ប្រធានការិយាល័យនីមួយៗមានឋានៈស្មើប្រធានការិយាល័យថ្នាក់ក្រសួង។

អង្គការលេខរបស់រដ្ឋបាលសុំកូនអន្តរប្រទេសមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ប្រការ៥.-

សមាសភាពថ្នាក់ដឹកនាំ និងមន្ត្រីបម្រើការងារនៅរដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោមនេះ៖

-មានបទពិសោធន៍លើការងារសង្គមកិច្ច ផ្នែកចិត្តសាស្ត្រ ជាពិសេសការងារសុខុមាលភាពកុមារ

-បានទទួលការបណ្តុះបណ្តាលវគ្គសេវាសង្គមកិច្ច

-មានចំណេះដឹងជាមូលដ្ឋានលើផ្នែកច្បាប់ ជាពិសេសច្បាប់ស្តីពីសុំកូនអន្តរប្រទេស និងអនុសញ្ញាអន្តរជាតិនានាដែលពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេស

-មានសមត្ថភាពខាងផ្នែកព័ត៌មានវិទ្យា និងភាសាបរទេសជាពិសេសភាសាអង់គ្លេស

-ជាមន្ត្រីក្របខណ្ឌរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬជាមន្ត្រីជាប់កិច្ចសន្យា

-រដ្ឋបាលសុំកូនអន្តរប្រទេសអាចប្រើប្រាស់ទីប្រឹក្សាតាមការចាំបាច់។

ប្រការ៦.–

ការិយាល័យនិមួយៗមានភារកិច្ចដូចតទៅ៖

**១-ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ**

ក-ការងាររដ្ឋបាល បុគ្គលិក:

-គ្រប់គ្រងបុគ្គលិក

-ទទួលគ្រប់គ្រង ធ្វើការទាក់ទងជាមួយស្ថាប័ន អង្គភាព អាជ្ញាធរមូលដ្ឋាន ក្នុងការផ្ញើ ទទួល បែងចែក សារាចរ លិខិត ឯកសារ

-គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ សម្ភារៈ និងគ្រឿងបរិក្ខារ

-ផ្សព្វផ្សាយបទបញ្ជា សារាចរ សេចក្ដីសម្រេច សេចក្ដីជូនដំណឹងផ្សេងៗរបស់ថ្នាក់ដឹកនាំ

-រៀបចំកិច្ចប្រជុំ ធ្វើកំណត់ហេតុអង្គប្រជុំ រៀបចំលិខិតស្នាមផ្សេងៗទៀតតាមស្មារតីអង្គប្រជុំ របស់គណៈកម្មាធិការអាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេស

-ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំរបស់រដ្ឋបាលសុំកូនអន្តរប្រទេស

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

ខ-ការងារហិរញ្ញវត្ថុ:

-ជំនួយឲ្យអាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេស ក្នុងការអនុវត្តនីតិវិធីទទួល គ្រប់គ្រងថវិកា ជាប្រាក់ចំណាយសោហ៊ុយ និងវិភាគទានសុំកូនអន្តរប្រទេស ស្របតាមការកំណត់នៃប្រកាស រួមរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ទទួលគ្រប់គ្រងថវិកាចំណូលរបស់រដ្ឋបាលសុំកូនអន្តរប្រទេស រៀបចំធ្វើផែនការចំណាយ និងលើកសំណើប្រើប្រាស់ថវិកាដែលមានតាមភារកិច្ចរបស់រដ្ឋបាលសុំកូនអន្តរប្រទេស

-ធ្វើរបាយការណ៍ពីចំណូល និងចំណាយរបស់អាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេស និងរដ្ឋ បាលសុំកូនអន្តរប្រទេសរៀងរាល់ខែ ត្រីមាស និងប្រចាំឆ្នាំ

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

**២-ការិយាល័យគ្រប់គ្រងទិន្នន័យ និងតម្កល់ឯកសារ**

-រៀបចំ និងគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងកុមារដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស ទិន្នន័យ របស់អ្នកសុំ និងទិន្នន័យផ្សេងទៀតស្របតាមមុខងាររបស់រដ្ឋបាលសុំកូនអន្តរប្រទេស

-ប្រមូល គ្រប់គ្រង រក្សាទិន្នន័យពាក់ព័ន្ធនឹងកុមារដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស ទិន្នន័យ របស់អ្នកសុំ និងទិន្នន័យរបស់ទីភ្នាក់ងារទៅក្នុងប្រព័ន្ធDatabase

-រៀបចំតម្កល់រក្សាទុកសំណុំឯកសាររបស់កុមារឲ្យបានគត់មត់ល្អក្នុងរយៈពេល ៦០ (ហុក សិប) ឆ្នាំ

-រក្សាការសម្ងាត់ចំពោះព័ត៌មានទាំងអស់ដែលមានសរសេរនៅក្នុងសំណុំឯកសារ

-ណែនាំឪពុកម្ដាយចិញ្ចឹម និងកូនសុំដែលដល់អាយុពេញវ័យឲ្យដាក់ពាក្យសុំមក ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រសិនបើចង់មើល ឬចង់ចម្លងសំណុំឯកសារ

-ពិគ្រោះយោបល់ជាមួយកូនសុំឲ្យបានសមស្រប មុនឲ្យមើលព័ត៌មានផ្សេងៗនៅក្នុងសំណុំ ឯកសារ

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

៣-ការិយាល័យអនុវត្តនីតិវិធីសុំកូនអន្តរប្រទេស

ក-ការងារគ្រប់គ្រងអត្តសញ្ញាណកុមារដែលជាកម្មវត្ថុសុំកូនអន្តរប្រទេសៈ

-រៀបចំបញ្ជីត្រួតពិនិត្យឯកសារ ព័ត៌មានផ្សេងៗតាមដំណាក់កាល និងពេលវេលាសម្រាប់សំណុំឯកសារទាំងអស់

-រៀបចំសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗ ដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសរួមមានព័ត៌មានចាំបាច់អំពីអត្តសញ្ញាណរបស់កុមារ ភាពអាចសុំជាកូនចិញ្ចឹមបាន សាវតារជាតិរបស់កុមារ បរិយាកាសសង្គម ប្រវត្តិគ្រួសារ ប្រវត្តិសុខភាពផ្ទាល់ខ្លួន ប្រវត្តិសុខភាពគ្រួសារកុមារ និងសេចក្តីត្រូវការពិសេសរបស់កុមារ

-ពិនិត្យមើលឲ្យបានត្រឹមត្រូវ គ្រប់គ្រាន់អំពីឯកសារទាំងឡាយស្តីពីការស្វះស្វែងទុកដាក់កុមារតាមរយៈការថែទាំជំនួសនៅក្នុងស្រុកដោយអស់លទ្ធភាព ពិសេសតាមរយៈសុំកូនក្នុងស្រុក

-ករណីកុមារត្រូវបានបោះបង់ចោល ត្រូវមានឯកសារបញ្ជាក់អំពីការស្វះស្វែងរកឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារស្របតាមបទប្បញ្ញត្តិជាធរមាន

-រៀបចំលិខិតបទដ្ឋាន និងពិនិត្យសំណុំឯកសារដើម្បីអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសដោយសាច់ញាតិ និងកុមារដែលមានតម្រូវការពិសេស

-ពិនិត្យលិខិតយល់ព្រមលើសុំកូនដែលត្រូវមានជាចាំបាច់ ហើយធ្វើឡើងស្របទៅតាមបទប្បញ្ញត្តិច្បាប់ស្តីពីសុំកូនអន្តរប្រទេស

-ពិនិត្យផ្ទៀងផ្ទាត់សំណុំឯកសារទាំងអស់របស់កុមារអំពីភាពត្រឹមត្រូវ និងស្របច្បាប់ ក្នុងករណីមានភាពមិនប្រក្រតី ត្រូវបញ្ជូនសំណុំឯកសារទៅផ្នែកអធិការកិច្ចដើម្បីធ្វើការស៊ើបអង្កេតឲ្យបានច្បាស់លាស់ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេត

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

ខ-ការងារពិនិត្យពាក្យសុំរបស់អ្នកសុំកូនៈ

- ទទួលពាក្យសុំកូនដែលបញ្ជូនមកពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិព្រមទាំងសំណុំឯកសារភស្តុតាងរបស់អ្នកសុំកូនដែលបានភ្ជាប់មកជាមួយ និងធ្វើលិខិតឆ្លើយតបទៅអ្នកសុំឲ្យស្របទៅតាមនីតិវិធី និងបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេស

- ណែនាំអ្នកតំណាងទីភ្នាក់ងារសុំកូនអន្តរប្រទេសឲ្យបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាជំនួសឲ្យអ្នកសុំតាមគោលការណ៍កំណត់ ក្រៅពីនេះមិនត្រូវបង់ប្រាក់អ្វីផ្សេងទៀតឡើយ

- ណែនាំទីភ្នាក់ងារសុំកូនអន្តរប្រទេស ឬអ្នកតំណាង ឬរបស់អ្នកសុំកូនមិនឲ្យបង់ប្រាក់ចំណាយ សោហ៊ុយ វិភាគទាន ឬការទូទាត់ដោយផ្ទាល់ ឬដោយប្រយោលក្តី ទោះក្នុងរូបភាពណាក៏ដោយទៅឲ្យមណ្ឌលកុមារកំព្រា ឬនាយក នាយករង សមាជិកគណៈគ្រប់គ្រង និងបុគ្គលិកមណ្ឌលកុមារកំព្រាឡើយ

- ចាត់ចែងឲ្យបកប្រែសំណុំឯកសារដើមរបស់អ្នកសុំទាំងអស់មកជាភាសាខ្មែរ ដោយមានបញ្ជាក់អំពីភាពត្រឹមត្រូវពីស្ថាប័នមានសមត្ថកិច្ច

- ពិនិត្យសំណុំឯកសាររបស់អ្នកសុំឲ្យបានត្រឹមត្រូវគ្រប់គ្រាន់ទៅតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ករណីសំណុំឯកសារមិនទាន់ត្រឹមត្រូវ ឬមិនទាន់គ្រប់គ្រាន់

ត្រូវធ្វើលិខិតជូនដំណឹងទៅទីភ្នាក់ងារសុំកូនអន្តរប្រទេស ដើម្បីឲ្យអ្នកសុំបំពេញឯកសារដែលខ្វះ ឬកែតម្រូវឲ្យបានត្រឹមត្រូវឡើងវិញ

- ធ្វើលិខិតឆ្លើយតបទៅអ្នកសុំដោយបញ្ជាក់ពីមូលហេតុឲ្យបានច្បាស់លាស់ ក្នុងករណីបដិសេធពាក្យសុំកូន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

គ-ការងារផ្គូផ្គងកុមារៈ

- ពិនិត្យ និងពិចារណាលើសំណុំឯកសាររបស់កុមារដែលមានឈ្មោះនៅក្នុងបញ្ជីកុមារជាកម្មវត្ថុសម្រាប់សុំកូនអន្តរប្រទេស រួចហើយត្រូវផ្គូផ្គងជាមួយអ្នកសុំណាដែលមានលក្ខណសម្បត្តិត្រូវសមគ្នាល្អបំផុតស្របតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងច្បាប់ស្ដីពីសុំកូនអន្តរប្រទេស និងក៏គិតគូដល់ឧត្តមប្រយោជន៍របស់កុមារផងដែរ
- រៀបចំធ្វើលិខិតផ្ញើទៅអ្នកសុំ និងភ្ជាប់សំណុំឯកសារចាំបាច់របស់កុមារដែលត្រូវបានផ្គូផ្គងឲ្យលើកលែងតែករណីសុំកូនដោយសាច់ញាតិ
- ពិនិត្យខ្លឹមសារលិខិតឆ្លើយតបរបស់អ្នកសុំដែលយល់ព្រមទទួលយកកុមារ ឬមិនទទួលយក ករណីបដិសេធត្រូវពិនិត្យឈ្មោះកុមារផ្សេងទៀតផ្គូផ្គងឲ្យជាលើកទីពីរ ហើយមិនអនុញ្ញាតឲ្យមានការផ្គូផ្គងជាលើកទីបីឡើយ
- បន្ទាប់ពីអ្នកសុំឆ្លើយតបយល់ព្រម ត្រូវរៀបចំឲ្យមានការជួបគ្នារវាងអ្នកសុំជាមួយកុមារដែលត្រូវបានផ្គូផ្គងរួចហើយតាមកាលបរិច្ឆេទមួយសមស្របត្រឹមត្រូវតាមបែបបទ នីតិវិធី និងបទប្បញ្ញត្តិ ដែលមានកំណត់ក្នុងច្បាប់ស្ដីពីសុំកូនអន្តរប្រទេស
- រៀបចំធ្វើសម្ភាសអ្នកសុំមុនការជួបគ្នាជាមួយកុមារ ហើយកុមារក៏ត្រូវបានពិគ្រោះយោបល់ជាមុនផងដែរ
- ចាត់ចែងធ្វើកំណត់ហេតុអំពីការធ្វើសម្ភាស និងការជួបគ្នារវាងអ្នកសុំជាមួយកុមារ
- ធ្វើកំណត់បង្ហាញ ផ្ដល់យោបល់ ដាក់សំណុំលិខិតទាំងអស់ជូនគណៈកម្មាធិការអាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេសសុំការពិនិត្យ និងផ្ដល់អនុសាសន៍លើដំណើរការសុំកូន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

ឃ-ការងារបន្តនីតិវិធីទៅតុលាការៈ

- សហការជាមួយទីភ្នាក់ងារសុំកូនអន្តរប្រទេស ដើម្បីឲ្យអ្នកសុំរៀបចំដាក់ពាក្យសុំកូនទៅសាលាដំបូងរាជធានីភ្នំពេញតាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេស
- ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញឲ្យបានត្រឹមត្រូវនូវសំណុំលិខិតទាំងអស់របស់កុមារ និងរបស់អ្នកសុំ រួចហើយបញ្ជូនពាក្យសុំកូន និងសំណុំលិខិតទាំងអស់នេះទៅសាលាដំបូងរាជធានីភ្នំពេញដើម្បីសុំដីកាសម្រេច
- សហការជាមួយមន្ត្រីគ្រប់គ្រងសំណុំលិខិតអត្តសញ្ញាណកុមារ និងពិនិត្យឯកសារឡើងវិញឲ្យបានគ្រប់គ្រាន់ ច្បាស់លាស់ ដើម្បីត្រៀមឡើងបំភ្លឺតុលាការក្នុងករណីចាំបាច់ និងអាចរកមេធាវីជួយការពារក្ដីផង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

ង-ការងារទាក់ទងជូនដំណឹងពីចំណាត់ការ និងនីតិវិធីបន្ទាប់ពីបញ្ចប់ដំណើរការសុំកូនៈ

- ជូនដំណឹងឲ្យបានទៀងទាត់ទៅអ្នកសុំអំពីចំណាត់ការ និងការវិវត្តនៃនីតិវិធីសុំកូន តាមមាត្រា ៩៣ ក្នុងច្បាប់ស្ដីពីសុំកូនអន្តរប្រទេស

- ធ្វើលិខិតរបស់ក្រសួងជូនដំណឹងទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិអំពីការសម្រេចរបស់តុលាការ
- ធ្វើលិខិតបញ្ជាក់សុំកូនដាក់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចុះហត្ថលេខា
- រៀបចំពិធីប្រគល់កុមារ ជូនលិខិតបញ្ជាក់សុំកូន និងធ្វើកំណត់ហេតុអំពីពិធីប្រគល់កុមារ
- សហការជួយសម្របសម្រួលជាមួយ ស្ថាប័នមានសមត្ថកិច្ចក្នុងការធ្វើលិខិតឆ្លងដែន និងទិដ្ឋាការឲ្យកុមារបានធ្វើដំណើរទៅកាន់ប្រទេសទទួលដោយសុវត្ថិភាព និងស្របតាមនីតិវិធីច្បាប់ស្តីពីសុំកូនអន្តរប្រទេស
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

**៤-ការិយាល័យអភិវឌ្ឍ គ្រប់គ្រងទីភ្នាក់ងារ និងអធិការកិច្ច**

ក-ការងារអភិវឌ្ឍ:

- រៀបចំតាក់តែងសេចក្តីព្រាងគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីថ្មីៗតាមការចាំបាច់ដើម្បីធ្វើឲ្យប្រសើរឡើងចំពោះការងារសុំកូនអន្តរប្រទេស
- ពិនិត្យ និងផ្តល់យោបល់ជូនគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស អំពីការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងសុំកូនអន្តរប្រទេស ព្រមទាំងអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារនិង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស
- ធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន ដែលមានសមត្ថកិច្ចលើកិច្ចការសុំកូនអន្តរប្រទេស និងទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលធ្វើប្រតិបត្តិការសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ទប់ស្កាត់សកម្មភាពទាំងឡាយដែលបំពានច្បាប់ស្តីពីសុំកូនអន្តរប្រទេស អនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស
- រៀបចំបើកវគ្គផ្សព្វផ្សាយច្បាប់ស្តីពីសុំកូនអន្តរប្រទេស លិខិតបទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេសដល់មន្ត្រីរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋានជា ពិសេសឃុំ សង្កាត់
- រៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីពាក់ពន្ធ័ការងារសុំកូនអន្តរប្រទេស និងអ្នកពាក់ពន្ធ័ផ្សេងទៀត
- តាមដាន វាយតម្លៃលទ្ធផលនៃការបណ្តុះបណ្តាល
- រៀបចំបោះពុម្ពសៀវភៅច្បាប់សុំកូនអន្តរប្រទេស អនុសញ្ញាអន្តរជាតិ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត
- រៀបចំតាក់តែង និងបោះពុម្ពសៀវភៅផ្នត់ ស្តីពីនីតិវិធីសុំកូនអន្តរប្រទេស
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

ខ-ការងារគ្រប់គ្រងទីភ្នាក់ងារ:

- ពិនិត្យ និងផ្តល់យោបល់ ក្នុងការអនុញ្ញាតឲ្យទីភ្នាក់ងារសុំកូនអន្តរប្រទេសធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំកិច្ចសន្យារវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា

- ពិនិត្យ និងផ្តល់យោបល់លើកិច្ចព្រមព្រៀងរវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយទីភ្នាក់ងារសុំកូនអន្តរប្រទេស ស្តីពីការផ្តល់ជំនួយមនុស្សធម៌ ការជួយឧបត្ថម្ភដល់កុមារកំព្រា និងកុមាររងគ្រោះដទៃទៀតដែលមិនពាក់ព័ន្ធជាមួយការងារសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

គ-ការងារអធិការកិច្ចៈ

- ចុះធ្វើការស្រាវជ្រាវលើសំណុំឯកសារ អត្តសញ្ញាណកុមារជាមុខសញ្ញាសុំកូនអន្តរប្រទេសដែលមានឈ្មោះក្នុងបញ្ជីកុមារជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសក្នុងករណីចាំបាច់
- ធ្វើអធិការកិច្ចចំពោះទីភ្នាក់ងារសុំកូនអន្តរប្រទេស និងអ្នកតំណាងទាំងអស់ដែលធ្វើប្រតិបត្តិការ នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការធ្វើអធិការកិច្ច
- រៀបចំដាក់ពិន័យអន្តរការណ៍ចំពោះទីភ្នាក់ងារ តាមការសម្រេចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្របតាមច្បាប់ ស្តីពីសុំកូនអន្តរប្រទេស
- រៀបចំឯកសារបញ្ជូនទៅតុលាការ ករណីទីភ្នាក់ងារមិនព្រមបង់ពិន័យអន្តរការណ៍
- សម្របសម្រួលជាមួយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីផ្តល់ ឬ សម្របសម្រួលសេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារចិញ្ចឹម និងគ្រួសារបង្កើតតាមការចាំបាច់ដូចមានចែងក្នុងមាត្រា ៩៥ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស
- ណែនាំអ្នកសុំកូនឲ្យផ្ញើរបាយការណ៍អំពីស្ថានភាពវិវឌ្ឍរបស់កុមារ មករដ្ឋបាលសុំកូនអន្តរប្រទេសឲ្យបានទៀងទាត់តាមការកំណត់ក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេស
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

**៥-ការិយាល័យ សហប្រតិបត្តិការអន្តរជាតិ**

- ធ្វើបច្ចុប្បន្នភាពលើព័ត៌មានអំពីការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីដែលទទួលបានពីស្ថានទូត ឬស្ថានតំណាង ទីភ្នាក់ងារជូនគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេស
- រៀបចំបើកវគ្គផ្សព្វផ្សាយច្បាប់ស្តីពីសុំកូនអន្តរប្រទេស លិខិតបទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេសដល់ស្ថានទូត ឬស្ថានតំណាង និងទីភ្នាក់ងារ
- រៀបចំកម្មវិធីបណ្តុះបណ្តាល និងទស្សនកិច្ចសម្រាប់មន្ត្រីពាក់ពន្ធ័ការងារសុំកូនអន្តរប្រទេស និងអ្នកពាក់ពន្ធ័ផ្សេងទៀត ទៅប្រទេសដែលមានកិច្ចសហប្រតិបត្តិការសុំកូនអន្តរប្រទេសជាមួយប្រទេសកម្ពុជា
- ធ្វើទំនាក់ទំនង និងសហប្រតិបត្តិការជាមួយអាជ្ញាធរកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល រដ្ឋជាភាគីអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស និងប្រទេសដទៃទៀតដែលមានកិច្ចសហប្រតិបត្តិការសុំកូនអន្តរប្រទេសជាមួយប្រទេសកម្ពុជា
- ជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីទប់ស្កាត់សកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងការជួញដូរកុមារតាមរយៈសុំកូនអន្តរប្រទេស ស្របតាមច្បាប់ស្តីពីសុំកូនអន្តរប្រទស និងអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស

- បំពេញបែបបទ និងផ្តល់ព័ត៌មានទៅការិយាល័យអចិន្ត្រៃយ៍នៃសន្ធិសិទក្រុងឡាអេស្តីពីច្បាប់អន្តរជាតិ ឯកជន តាមតម្រូវការ និងភាតព្វកិច្ចនៃប្រទេសជាភាគីនៃអនុសញ្ញានេះ
- ទំនាក់ទំនង និងសហការជាមួយការិយាល័យអចិន្ត្រៃយ៍នៃសន្ធិសិទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិ ឯកជន រដ្ឋជាភាគីអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារនិងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស អង្គការជាតិ អង្គការអន្តរជាតិពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងប្រទេសជាមិត្តនានាដើម្បីទាក់ទាញការជួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងសម្ភារៈចំពោះការងារសុំកូនអន្តរប្រទេសនៅកម្ពុជា
- រៀបចំកិច្ចព្រមព្រៀងនានារវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលទាំងអស់ដែលពាក់ព័ន្ធលើការងារសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

**ប្រការ៧.-**

រដ្ឋបាលសុំកូនអន្តរប្រទេសមានសិទ្ធិប្រើប្រាស់ត្រាដោយឡែកសម្រាប់ប្រតិបត្តិការមុខងាររបស់ខ្លួន។

**ប្រការ៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ ប្រធានរដ្ឋបាលសុំកូនអន្តរប្រទេស ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីខេត្ត និងអង្គភាពពាក់ព័ន្ធមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

<u>ចម្លងជូន:</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**
-ខុទ្ទកាល័យឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងមុខងារសាធារណៈ
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-ដូចប្រការ ៩
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ១៩៥៤/ស.អ.យ

ភ្នំពេញ ថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០១៤

# ប្រកាស
## ស្តីពី
## នីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសុំកូនអន្តរប្រទេស
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia Fax/Phone (855) 23 726 086

- បានឃើញប្រកាសរួមលេខ ១០០៧ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញប្រកាសរួមលេខ ៨៩៨ សហវ.ប្រក ចុះថ្ងៃទី១០ ខែ មេសា ឆ្នាំ ២០១៣ ស្តីពីការកំណត់ចំនួនប្រាក់ចំណាយ សោហ៊ុយ និងភាគទាននានាសម្រាប់សុំកូនអន្តរប្រទេស
- បានឃើញប្រកាសលេខ ១៩៥ ស.អ.យ. ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញប្រកាសលេខ ១២៣០ ស.អ.យ. ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស
- បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១ .-**

ប្រកាសនេះ កំណត់អំពីនីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ឲ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២ .-**

ទីភ្នាក់ងារ ដែលមានបំណងចង់ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារស្របតាមច្បាប់ ស្តីពីសុំកូនអន្តរប្រទេសតែប៉ុណ្ណោះ ទើបមានសិទ្ធិធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ចំពោះប្រទេសទទួលដែលគ្មានទីភ្នាក់ងារ អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួលនោះ មានសិទ្ធិធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ប៉ុន្តែត្រូវមានការទទួលស្គាល់ពីស្ថានទូត ឬ ស្ថានតំណាងរបស់ប្រទេសទទួល និងមានការយល់ព្រមពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងត្រូវមានការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ដំណើរការសុំកូនអន្តរប្រទេស ត្រូវធ្វើតាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលមានការបញ្ជាក់ទទួលស្គាល់គុណវុឌ្ឍិពីប្រទេសរបស់ទីភ្នាក់ងារ។

**ប្រការ ៣ .-**

អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់ទីភ្នាក់ងារ ត្រូវចុះកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង

ជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីកំណត់ចំនួនទីភ្នាក់ងារ ដែលអនុញ្ញាតឲ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយចំនួននេះ កំណត់ឲ្យមានត្រឹម ០១ (មួយ) ឬ ០២ (ពីរ) លើកលែងតែក្នុងករណីចាំបាច់ដើម្បីឧត្តមប្រយោជន៍ កុមារអាចអនុញ្ញាតឲ្យមានលើសពីនេះ។

**ប្រការ ៤ .-**

ដើម្បីសុំការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារត្រូវមានលក្ខណសម្បត្តិដូចតទៅ៖

១ - មានការបញ្ជាក់ទទួលស្គាល់គុណវុឌ្ឍិពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់ទីភ្នាក់ងារ។

២ - មានការអនុញ្ញាតពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់ទីភ្នាក់ងារ ឲ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៣ -មានទិសដៅមិនស្វែងរកផលចំណេញ និងបានបំពេញនូវលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ឬ បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារ។

៤ - មានអ្នកដឹកនាំ និងមានបុគ្គលិកដែលមានសមត្ថភាពប្រកបដោយគុណធម៌ និងសីលធម៌ បញ្ជាក់ដោយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស របស់ប្រទេសទីភ្នាក់ងារ បានទទួលការបណ្តុះបណ្តាលអំពីច្បាប់ ស្តីពីសុំកូនអន្តរប្រទេស របស់ព្រះរាជាណាចក្រកម្ពុជា លិខិតបទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងការងារសុំកូនអន្តរប្រទេស រៀបចំដោយអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស (រដ្ឋបាលសុំកូនអន្តរប្រទេស) និងមានបទពិសោធធ្វើការងារក្នុងវិស័យសុំកូនអន្តរប្រទេស។

**ប្រការ ៥ .-**

ទីភ្នាក់ងារដែលអនុញ្ញាតឲ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវឆ្លើយតបនឹងលក្ខខណ្ឌដូចតទៅ៖

១ - មិនមានបើកមណ្ឌលកុមារកំព្រា ឬ ប្រើប្រាស់មណ្ឌលកុមារកំព្រា ដើម្បីជាប្រភពផ្តល់ទារក និងកុមារកំព្រាសម្រាប់សុំកូនអន្តរប្រទេស។

២ - ប្រទេសរបស់ទីភ្នាក់ងារជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា។



ε/1

៣ - គោរព និងអនុវត្តតាមច្បាប់ ស្តីពីសុំកូនអន្តរប្រទេស និងបទប្បញ្ញត្តិច្បាប់ជាធរមានផ្សេងទៀតរបស់ព្រះរាជាណាចក្រកម្ពុជា អនុសញ្ញាស្តីពីសិទ្ធិកុមារ [illegible] សញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស និងលិខិតគតិយុត្តអន្តរជាតិផ្សេងទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស ដែលព្រះរាជាណាចក្រកម្ពុជា និងប្រទេសរបស់ទីភ្នាក់ងារបានផ្តល់សច្ចាប័ន ឬ អនុម័តយល់ព្រម។

**ប្រការ ៦ .-**

ការសុំការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារត្រូវមានសំណុំឯកសារដូចតទៅ៖

១ - ពាក្យស្នើសុំត្រូវចុះហត្ថលេខាដោយប្រធានទីភ្នាក់ងារ និងមានបិទតែមប្រិ៍សារពើពន្ធតម្លៃ ៥០០០ (ប្រាំពាន់) រៀល។

២ - ច្បាប់ចម្លងលិខិតបញ្ជាក់ទទួលស្គាល់គុណវុឌ្ឍិរបស់ទីភ្នាក់ងារ (នៅមានសុពលភាព) ចេញដោយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារ។

៣ - ច្បាប់ចម្លងលិខិតអនុញ្ញាតឲ្យបើកទីភ្នាក់ងារដែលមានទិសដៅមិនស្វែងរកផលចំណេញ ដោយមានការបញ្ជាក់ត្រឹមត្រូវពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារ។

៤ - លិខិតរបស់អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារដែលអនុញ្ញាតឲ្យទីភ្នាក់ងារ ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៥ - លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ទីភ្នាក់ងារ។

៦ - ឯកសារសង្ខេបអំពីប្រវត្តិ សកម្មភាព កម្មវិធី និងសេវារបស់ទីភ្នាក់ងារ បញ្ជីរាយនាមបុគ្គលិក និងលក្ខណសម្បត្តិរបស់បុគ្គលិកទាំងនោះ រួមទាំងភ័ស្តុតាងដែលបង្ហាញអំពីបទពិសោធន៍ក្នុងវិស័យសុំកូនអន្តរប្រទេសយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ។

៧ - របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយដែលបានធ្វើសវនកម្មឯករាជ្យ រួមមានប្រភពមូលនិធិ សោហ៊ុយសុំកូន និងថ្លៃចំណាយនានាទាក់ទងនឹងសុំកូនអន្តរប្រទេស។

៨ - ជីវប្រវត្តិសង្ខេបមានបិទរូបថតទំហំ ៤ ស.ម x ៦ ស.ម របស់សមាជិកក្រុមប្រឹក្សាភិបាល ឬ គណៈគ្រប់គ្រងទីភ្នាក់ងារ។

៩ - ជីវប្រវត្តិសង្ខេបមានបិទរូបថតទំហំ ៤ ស.ម x ៦ ស.ម របស់បុគ្គលិកមួយនាក់ ឬ ពីរនាក់ដែលបានទទួលការអនុញ្ញាត ឲ្យធ្វើជាអ្នកតំណាងទីភ្នាក់ងារលើការងារសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១០ -ឯកសារភ័ស្តុតាងនានាដែលបញ្ជាក់ថាអ្នកតំណាងដូចមានចែងក្នុងចំណុច ៩ ខាងលើ គ្មានជាប់ឈ្មោះក្នុងបញ្ជីថ្កោលទោសនៅប្រទេសដើមរបស់ខ្លួន និងនៅប្រទេសចុងក្រោយដែលខ្លួនកំពុងរស់នៅ ប្រសិនបើប្រទេសខុសគ្នា។

១១ - ច្បាប់ចម្លងឯកសារកិច្ចព្រមព្រៀងពីអតីតកាល ឬ បច្ចុប្បន្នកាលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការផ្តល់ជំនួយមនុស្សធម៌ ឬ ការជួយឧបត្ថម្ភដល់កុមារកំព្រានានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១២ - ច្បាប់ចម្លងកិច្ចព្រមព្រៀងទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការសុំកូនអន្តរប្រទេសរវាងព្រះរាជាណាចក្រកម្ពុជា (ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ) និងប្រទេសរបស់ទីភ្នាក់ងារ ប្រសិនបើប្រទេសនេះមិនមែនជាប្រទេសភាគីអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។

១៣ - ឯកសារផ្សេងៗទៀតដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យល់ថាចាំបាច់ដើម្បីឧត្តមប្រយោជន៍កុមារ និងដើម្បីមានមូលដ្ឋានវាយតម្លៃពាក្យសុំឲ្យបានសមស្រប។

ពាក្យសុំ និងសំណុំឯកសារទាំងអស់ត្រូវបញ្ជូនតាមរយៈស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសរបស់ទីភ្នាក់ងារប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពិនិត្យ និងបញ្ជូនបន្តមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

សំណុំឯកសារទាំងអស់នេះ ត្រូវមានជាភាសាអង់គ្លេស ឬ ភាសាបារាំង ហើយត្រូវបកប្រែជាភាសាខ្មែរ។

**ប្រការ ៧ .–**

នៅពេលពាក្យស្នើសុំ និងសំណុំឯកសារទាំងអស់មកដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវទំនាក់ទំនងអញ្ជើញសាមីទីភ្នាក់ងារមកបង់ប្រាក់តម្លៃសេវារដ្ឋបាលពិនិត្យឯកសារចំនួន ២០០០ ០០០ (ពីរលាន) រៀល យោងតាមប្រកាសរួមលេខ ១០០៧ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញទេ។

**ប្រការ ៨ .–**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងផ្តល់ចម្លើយជាលាយលក្ខណ៍អក្សរទៅទីភ្នាក់ងារ វិញអំពីការសម្រេចរបស់ក្រសួង ក្នុងកំឡុងពេល៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ

បន្ទាប់ពីបានទទួលប្រាក់តម្លៃសេវាពិនិត្យឯកសារ។

ក្នុងករណីយល់ព្រមទីភ្នាក់ងារត្រូវចុះកិច្ចសន្យា ស្ដីពីកិច្ចប្រតិបត្តិការស៊ុំកូនអន្តរប្រទេសជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ក្រសួងនឹងចេញប្រកាសអនុញ្ញាត ព្រមទាំងផ្ដល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារ ហើយទីភ្នាក់ងារត្រូវបង់ប្រាក់តម្លៃសេវាផ្ដល់អាជ្ញាប័ណ្ណចំនួន ១២ ០០០ ០០០ (ដប់ពីរលាន) រៀល យោងតាមប្រកាសរួមលេខ ១០០៧ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ប្រកាសផ្ដល់ការអនុញ្ញាតដល់ទីភ្នាក់ងារ ត្រូវបញ្ជាក់អំពីកាតព្វកិច្ច និងសកម្មភាពរបស់ទីភ្នាក់ងារដែលបានទទួលការអនុញ្ញាត និងលក្ខខណ្ឌដទៃទៀតសម្រាប់ការផ្ដល់ការអនុញ្ញាត និងផ្ដល់អាជ្ញាប័ណ្ណ។

ក្នុងករណីមានការបដិសេធ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងឆ្លើយបញ្ជាក់ច្បាស់លាស់ទៅទីភ្នាក់ងារវិញអំពីមូលហេតុនៃការបដិសេធ។

**ប្រការ ៩ .-**

ទីភ្នាក់ងារស៊ុំកូនអន្តរប្រទេសត្រូវចាត់តាំងឲ្យមានអ្នកតំណាងចំនួនមួយនាក់ ឬ ពីរនាក់ជាជនជាតិខ្មែរ។ ក្នុងករណីពីរនាក់អាចមានមួយនាក់ជាជនបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជាសម្រាប់ដំណើរការនីតិវិធីស៊ុំកូនអន្តរប្រទេស។ អ្នកតំណាងទាំងនេះ ត្រូវមានការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងពីអាជ្ញាធរកណ្ដាល ឬ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារ។ លក្ខខណ្ឌរបស់ទីភ្នាក់ងារ ដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ នៃប្រការ ៥ ក្នុងប្រកាសនេះក៏ត្រូវយកមកអនុវត្តចំពោះអ្នកតំណាងទីភ្នាក់ងារផងដែរ។

មានតែអ្នកតំណាងដែលមានឈ្មោះក្នុងសំណុំឯកសារពាក្យស្នើសុំការអនុញ្ញាតតែប៉ុណ្ណោះដែលមានសិទ្ធិធ្វើជាអ្នកតំណាងឲ្យទីភ្នាក់ងារនៅក្នុងដំណើរការនីតិវិធីស៊ុំកូនអន្តរប្រទេស។

ក្នុងករណីអ្នកតំណាងដែលបានទទួលការអនុញ្ញាតរួចហើយ ត្រូវជំនួសដោយអ្នកផ្សេង ប្រធានទីភ្នាក់ងារ ត្រូវដាក់ពាក្យស្នើសុំទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីសុំការអនុញ្ញាតទទួលស្គាល់ សម្រាប់អ្នកតំណាងថ្មីនេះ។ មុនមានការយល់ព្រមពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អ្នកតំណាងថ្មីនេះមិនអាចធ្វើជាអ្នកតំណាងរបស់ទីភ្នាក់ងារបានឡើយ។

**ប្រការ ១០ .-**

ការអនុញ្ញាតឲ្យទីភ្នាក់ងារធ្វើប្រតិបត្តិការស៊ុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវផ្ដល់ឲ្យសម្រាប់រយៈពេល ០២ (ពីរ) ឆ្នាំម្ដង ហើយអាចអនុញ្ញាតឲ្យបន្តដរាបណាក្រសួងសង្គម

កិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពិនិត្យឃើញថា សេវារបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេសនោះនៅតែចាំបាច់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ទីភ្នាក់ងារត្រូវដាក់ពាក្យស្នើសុំសាជាថ្មីទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រយៈពេល៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ មុនអាជ្ញាប័ណ្ណរបស់ទីភ្នាក់ងារអស់សុពលភាព ដើម្បីសុំបន្តការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាតទៅទៀត ហើយត្រូវចម្លងពាក្យស្នើសុំនេះ ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដើម្បីជ្រាប។ ឯកសារនៅក្នុងប្រការ ៦ នៃប្រកាសនេះ ហើយអស់សុពលភាព ទីភ្នាក់ងារត្រូវរៀបចំបំពេញសារជាថ្មី។ ត្រូវបង់ប្រាក់តម្លៃសេវារដ្ឋបាលពិនិត្យឯកសារ និងផ្តល់អាជ្ញាប័ណ្ណ ចំនួន ២ ០០០ ០០០ (ពីរលាន) រៀល យោងតាមប្រកាសរួមលេខ ១០០៧ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទឹកប្រាក់នេះមិនអាចបង្វិលជូនវិញទេ។

មុនផ្តល់ការអនុញ្ញាតសារជាថ្មី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចចាត់តាំងមន្ត្រី អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសឲ្យទៅពិនិត្យវាយតម្លៃសកម្មភាពការងាររបស់ទីភ្នាក់ងារ ហើយក្នុងករណីចាំបាច់អាចទៅធ្វើទស្សនកិច្ចពិនិត្យវាយតម្លៃអំពីស្ថានភាពរស់នៅរបស់កុមារកម្ពុជា ដែលត្រូវបានសុំយកទៅចិញ្ចឹមនៅប្រទេសរបស់ទីភ្នាក់ងារនោះ។ ទីភ្នាក់ងារសុំកូនអន្តរប្រទេសសាមីត្រូវសម្របសម្រួលជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ខ្លួនដើម្បីបង្កលក្ខណៈងាយស្រួលដល់ការពិនិត្យវាយតម្លៃនេះ។

**ប្រការ ១១ .-**

ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលមានបំណងឈប់ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវធ្វើលិខិតជូនដំណឹងជាផ្លូវការជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទឈប់ធ្វើប្រតិបត្តិការ។ លិខិតជូនដំណឹងនេះត្រូវចម្លង ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ក្នុងករណីនេះ អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសាមីរបស់ទីភ្នាក់ងារអាចបញ្ជូនទីភ្នាក់ងារថ្មីមកជំនួសទីភ្នាក់ងារដែលបានបញ្ចប់សកម្មភាព។ ទីភ្នាក់ងារថ្មីត្រូវបំពេញបែបបទស្នើសុំការអនុញ្ញាតតាមបទប្បញ្ញត្តិនៃប្រកាសនេះ។

**ប្រការ ១២ .-**

ទីភ្នាក់ងារសុំកូនអន្តរប្រទេសត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាជំនួសឲ្យអ្នកសុំទៅតាមចំនួនកូនសុំ។ បរិមាណទឹកប្រាក់មានកំណត់ក្នុងប្រកាសរួមលេខ ៩៤៨ សហវ.

ប្រក ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ ស្ដីពីការកំណត់ចំនួនប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាសម្រាប់សុំកូនអន្តរប្រទេស។

**ប្រការ ១៣ .–**

ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលទទួលបានការអនុញ្ញាតអាចផ្ដល់ជំនួយមនុស្សធម៌ ឬ អនុវត្តគម្រោងនានា ដើម្បីលើកស្ទួយវិស័យសុខុមាលភាពកុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈអាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេស។ ទីភ្នាក់ងារត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំជូនអាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាអំពីការអនុវត្តគម្រោង និងជំនួយមនុស្សធម៌ទាំងអស់នោះ ហើយគ្រប់គម្រោងទាំងអស់ត្រូវកាត់ផ្ដាច់ជានិច្ច និងច្បាស់លាស់រវាងសុំកូនអន្តរប្រទេស និងវិភាគទាន ឬ អំណោយ ឬ ជំនួយអភិវឌ្ឍន៍។

**ប្រការ ១៤ .–**

ដោយមិនគិតដល់ទោសប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ ស្ដីពីសុំកូនអន្តរប្រទេស និងច្បាប់ជាធរមានដទៃទៀតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចព្យួរការអនុញ្ញាត ឬ ដកហូតការអនុញ្ញាត ឬ បដិសេធមិនផ្ដល់ការអនុញ្ញាតសារជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញឲ្យឃើញថា ទីភ្នាក់ងារសុំកូនអន្តរប្រទេស ឬ អ្នកតំណាងមានជាប់ពាក់ព័ន្ធនឹងអំពើណាមួយដូចមានចែងតាមការហាមឃាត់ក្នុងប្រការ ១៥ នៃប្រកាសនេះ។

**ប្រការ ១៥ .–**

ទីភ្នាក់ងារសុំកូនអន្តរប្រទេស ឬ អ្នកតំណាងទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានហាមឃាត់មិនឲ្យធ្វើសកម្មភាពដូចខាងក្រោម៖

១ - អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ឲ្យឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយឲ្យបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើត ដើម្បីឲ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស។

២ - អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីរវាងប្ដីប្រពន្ធ ដែលចង់សុំកូនយកទៅចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត។

៣ - អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីរវាងប្ដីប្រពន្ធ ដែលចង់សុំកូនយកទៅចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឲ្យអ្នកសុំ។

៤ - អំពើក្លែងបន្លំ ឬ សមគំនិតក្លែងបន្លំស្ថានភាពលំបាកបំផុត ដើម្បីទទួលបានការយល់ព្រមពីឪពុកម្ដាយបង្កើត ឬ ឪពុកបង្កើត ឬ ម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ។

៥ - អំពើរៀបចំឲ្យមានការយល់ព្រមរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ដោយការបង្ខិតបង្ខំ ការគំរាមកំហែង ការឆបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្ដល់ ឬ សន្យាផ្ដល់ប្រាក់រង្វាន់សំណង ឬ ផលប្រយោជន៍ណាមួយ។

៦ - ការបញ្ចេញសំណុំឯកសារ និងកំណត់ហេតុទាំងអស់ ឬ មួយផ្នែកទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ដោយគ្មានការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬ ពីតុលាការមានសមត្ថកិច្ច។

៧ - ការបង្គាប់ ឬ ការទទួលដោយផ្ទាល់ ឬ ដោយប្រយោលនូវថ្នូរប្រាក់កាស ទំនិញ ឬ សេវាដោះដូរ និងការបម្រុងទុកកុមារណាមួយសម្រាប់សុំកូន។

៨ - ការថ្លែងមិនពិត ឬ លាក់បាំងព័ត៌មានសំខាន់ណាមួយដែលតម្រូវដោយច្បាប់ទាក់ទងនឹងសុំកូនអន្តរប្រទេស ការបង្កើត និងការប្រព្រឹត្តទៅនៃអង្គការមិនស្វែងរកផលចំណេញ ឬ លក្ខខណ្ឌតម្រូវនានានៃប្រកាសនេះ។

៩ - ការផ្ដល់ប្រាក់កាស ទំនិញ ឬ សេវាទៅឲ្យមន្ត្រី ឬ អ្នកតំណាងណាមួយនៃរដ្ឋបាលសុំកូនអន្តរទេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេស ឬ មន្ត្រីពាក់ព័ន្ធផ្សេងទៀត ដើម្បីឲ្យផ្ដល់សិទ្ធិជាអាទិភាពក្នុងនីតិវិធីសុំកូនអន្តរប្រទេសដល់អ្នកសុំ។ ត្រូវហាមឃាត់ផងដែរការទទួលប្រាក់ ទំនិញ ឬ សេវាសម្រាប់គោលបំណងនេះដែរ។

១០-ការផ្សាយពាណិជ្ជកម្ម ឬ ការបោះពុម្ពផ្សាយនូវអត្តសញ្ញាណ ឬ រូបថតរបស់កុមារណាមួយដែលជាកម្មវត្ថុសុំកូនអន្តរប្រទេស ក្នុងគោលបំណងបញ្ចុះបញ្ចូលបុគ្គលណាមួយឲ្យដាក់ពាក្យសុំកូន។

១១-ការធ្វើអំពើណាមួយ ដែលមិនគោរពទៅតាមច្បាប់ ស្ដីពីសុំកូនអន្តរប្រទេស ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គការមិនស្វែងរកផលចំណេញ ឬ លក្ខខណ្ឌតម្រូវនានានៃប្រកាសនេះ។

១២-ការតែងតាំង ឬ ចាត់តាំងអ្នកតំណាងណាមួយដោយមិនមានការអនុញ្ញាតទទួលស្គាល់ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

១៣-ការចូលរួមក្នុងការរៀបចំការផ្គូផ្គង ឬ ការទាក់ទងគ្នារវាងអ្នកសុំ និងឪពុកម្ដាយបង្កើត ឬ ឪពុកបង្កើត ឬ ម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ក្នុងគោលបំណងកំណត់ទុកជាមុននូវកុមារណាមួយដែលនឹងត្រូវសុំ។

១៤-ការមិនបានកាត់ផ្ដាច់ និងច្បាស់លាស់រវាងសុំកូនអន្តរប្រទេស និងវិភាគទាន ឬអំណោយ ឬ ជំនួយអភិវឌ្ឍន៍ក្នុងគ្រប់ករណីទាំងអស់។

១៥-ការរំលោភបំពានដល់បទប្បញ្ញត្តិនៃច្បាប់ បទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារ និងបទប្បញ្ញត្តិផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១៦ .** -

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវត្រួតពិនិត្យតាមដានសេវាកម្មសុំកូនអន្តរប្រទេសរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេសឲ្យបានហ្មត់ចត់ក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែម្ដង។

ក្រោយពីបានស៊ើបអង្កេតដ៏ល្អិតល្អន់រួចហើយ ប្រសិនបើមានភស្តុតាងបង្ហាញឲ្យឃើញថា ទីភ្នាក់ងារសុំកូនអន្តរប្រទេស ឬ អ្នកតំណាងណាមួយបានប្រព្រឹត្តបំពានច្បាប់ ស្ដីពីសុំកូនអន្តរប្រទេស បទប្បញ្ញត្តិទាក់ទងនឹងនីតិបុគ្គលមិនយកផលចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីចាត់វិធានការតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ទីភ្នាក់ងារដែលមានការបញ្ជាក់ទទួលស្គាល់គុណវុឌ្ឍិ ត្រូវផ្ដល់របាយការណ៍ប្រចាំឆ្នាំអំពីសកម្មភាពរបស់ខ្លួនជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ប្រការ ១៧ .** -

ករណីទទួលបានរបាយការណ៍ ពាក្យបណ្ដឹង ឬ ព័ត៌មានណាមួយដែលអាចជឿជាក់បានទាក់ទងនឹងការ បំពានច្បាប់ ឬ ភាពមិនប្រក្រតីក្នុងសកម្មភាពពាក់ព័ន្ធនឹងការងារសុំកូនអន្តរប្រទេសរបស់ទីភ្នាក់ងារណាមួយ ឬ អ្នកតំណាង រដ្ឋបាលសុំកូនអន្តរប្រទេសដោយមានជំនួយពីអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត បើចាំបាច់អាចធ្វើការស៊ើបអង្កេតទីភ្នាក់ងារ ឬ អ្នកតំណាងនោះ ហើយបើយល់ឃើញថារបាយការណ៍ ពាក្យបណ្ដឹង ឬ ព័ត៌មាន ទាំងនោះមានមូលដ្ឋានគតិយុត្ត និងផ្អែកលើអង្គហេតុច្បាស់លាស់ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធ្វើលិខិតជូនដំណឹងទៅទីភ្នាក់ងារសាមីដោយភ្ជាប់នូវច្បាប់ចម្លងនៃពាក្យបណ្ដឹង ឬ សេចក្ដីសង្ខេបរបាយការណ៍ ឬ សំណូមពរជាមួយផង ហើយតម្រូវឲ្យទីភ្នាក់ងារនោះធ្វើការឆ្លើយតប ឬ ឆ្លើយបំភ្លឺមកវិញក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីពេលដែលទីភ្នាក់ងារទទួលបានលិខិតជូនដំណឹង។

រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីកាលបរិច្ឆេទដែលបានទទួលការឆ្លើយបំភ្លឺ ឬ ការខកខានមិនបានឆ្លើយតប ឬ ឆ្លើយបំភ្លឺពីសំណាក់ទីភ្នាក់ងារក្នុងរយៈពេលដែលបានកំណត់ក្នុងកថាខ័ណ្ឌទី ១ នៃប្រការនេះ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីសុំការសម្រេច។

**ប្រការ ១៨ .–**

អាស្រ័យលើស្ថានទម្ងន់នៃការរំលោភបំពានច្បាប់ ឬ ករណីទីភ្នាក់ងារខកខានមិនបានផ្តល់ការឆ្លើយតប ឬ ឆ្លើយបំភ្លឺ ហើយបើចាំបាច់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចព្យួរជាបណ្តោះអាសន្នមិនឲ្យទីភ្នាក់ងារពាក់ព័ន្ធនោះធ្វើសកម្មភាពរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ ជាអតិបរិមា។ ប្រសិនបើមានភស្តុតាងបង្ហាញថា ទីភ្នាក់ងារ ឬ អ្នកតំណាងទីភ្នាក់ងារបានរំលោភបំពានច្បាប់យ៉ាងធ្ងន់ធ្ងរ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចបញ្ឈប់ទីភ្នាក់ងារនោះជាបន្ទាន់មិនអនុញ្ញាត ឲ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសតទៅទៀត ហើយត្រូវមានវិធានការដើម្បីធានាថា ការបញ្ឈប់សកម្មភាពរបស់ទីភ្នាក់ងារនោះពុំមានកុមារណាមួយទទួលរងគ្រោះអំពីការព្យួរ ឬ ការបញ្ឈប់ការអនុញ្ញាតឲ្យធ្វើប្រតិបត្តិការរបស់ទីភ្នាក់ងារនោះឡើយ។

**ប្រការ ១៩ .–**

ក្នុងករណីចាំបាច់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចស្នើសុំតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទៅអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់ទីភ្នាក់ងារ ដើម្បីទៅធ្វើអធិការកិច្ចទីភ្នាក់ងារសុំកូនអន្តរប្រទេសនៅប្រទេសសាមីទីភ្នាក់ងារនោះ។ គ្មានជនណាអាចរារាំង បង្អាក់ ឬ ជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់នោះឡើយ។

ផ្អែកតាមលទ្ធផលនៃការធ្វើអធិការកិច្ច ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចសម្រេចព្យួរ ឬ ដកហូតការអនុញ្ញាត ឬ បដិសេធការបន្តការអនុញ្ញាតសាជាថ្មីទៅតាមស្ថានទម្ងន់ ឬ ភស្តុតាងបង្ហាញពីការរំលោភបំពាន ហើយត្រូវធ្វើលិខិតជូនដំណឹងអំពីការសម្រេចនេះទៅឲ្យទីភ្នាក់ងារសាមី អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់ទីភ្នាក់ងារ និងចម្លងជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**ប្រការ ២០ .–**

ការទទួលពាក្យស្នើសុំ ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួលនឹងចាប់ផ្តើមអនុវត្តបន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជ

និងយុវនីតិសម្បទា ជាមួយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល ស្តីពីការកំណត់ចំនួនទីភ្នាក់ងារសុំកូនអន្តរប្រទេសឡ ប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២១ .-**

ប្រកាសលេខ ១៨៥៧ ស.អ.យ. ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១១ ស្តីពីនីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ២២ .-**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ ប្រធានរដ្ឋបាលសុំកូនអន្តរប្រទេស ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្ត និងស្ថាប័នពាក់ព័ន្ធនានា មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

<u>**ចម្លងជូន:**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងពាក់ព័ន្ធ
- ដូចប្រការ ២២
- កាលប្បវត្តិ - ឯកសារ

# ព្រះរាជក្រម

នស/រកម/០២០៧/០០៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

1/3
6

# ច្បាប់
# ស្ដីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្ដីពីការការពារ កុមារនិងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស

**មាត្រា ១.–**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្ដីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ដែលធ្វើនៅទីក្រុងឡាអេ នាថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញាអន្តរជាតិនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី *២៦* ខែ *មករា* ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*៣រល.០៧០១.០២៤*

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
**ហត្ថលេខា**
**អ៊ិត សំហេង**

លេខៈ ៥៧ ទ.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ចិនកេន

# អនុសញ្ញាក្រុងឡាអេ
# ស្តីពី
# ការការពារកុមារ និង
# សហប្រតិបត្តិការទាក់ទងនឹង
# សុំកូនអន្តរប្រទេស

# អនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស

( អនុម័ត ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៣ )

## បុព្វកថា

**រដ្ឋជាហត្ថលេខីនៃអនុសញ្ញានេះ**

- ដោយទទួលស្គាល់ថាកុមារត្រូវចំរើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ នៅក្នុងបរិយាកាសនៃសុភមង្គល សេចក្តីស្រឡាញ់ និង កិត្តិយស សំរាប់ការចំរើនលូតលាស់ពេញលេញ និងយ៉ាងសុខដុម នៃបុគ្គលិកលក្ខណៈរបស់គេ
- ដោយរំលឹកឡើងវិញថារដ្ឋនីមួយៗ ជាអាទិភាពត្រូវចាត់វិធានការសមស្របដើម្បីឱ្យកុមារស្ថិតក្នុងការបីបាច់រក្សាពីសំណាក់គ្រួសារកំណើតរបស់គេ
- ដោយទទួលស្គាល់ថាសុំកូនអន្តរប្រទេសអាចផ្តល់អត្ថប្រយោជន៍នៃគ្រួសារអចិន្ត្រៃយ៍ដល់កុមារ ដោយសារគេមិនអាចរកគ្រួសារមួយសមស្របបាននៅក្នុងប្រទេសដើមរបស់កុមារនោះ
- ដោយជឿជាក់អំពី ភាពចាំបាច់ក្នុងការចាត់វិធានការ ដើម្បីធានាថាសុំកូនអន្តរប្រទេសគឺធ្វើឡើងក្នុងឧត្តមប្រយោជន៍របស់កុមារ និងដោយសេចក្តីគោរពសិទ្ធិមូលដ្ឋានរបស់កុមារ និងវិធានការដើម្បីបង្ការការចាប់ពង្រត់ ការលក់ ឬ ជួញដូរកុមារ
- ដោយមានសេចក្តីប្រាថ្នាចង់បង្កើតបញ្ញត្តិរួមសំរាប់បញ្ហាទាំងអស់នេះ ដោយពិចារណាដល់គោលការណ៍ចែងនៅក្នុងលិខិតូបករណ៍អន្តរជាតិ ជាពិសេសអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៩ និងសេចក្តីថ្លែងការណ៍នៃអង្គការសហប្រជាជាតិស្តីពីគោលការណ៍សង្គម និងច្បាប់ទាក់ទងនឹងការការពារសុខុមាលភាពកុមារ ដែលយោងជាពិសេសដល់ការដាក់កុមារអោយរស់នៅជាមួយគ្រួសារធម៌ និងសុំកូន នៅក្នុងប្រទេស និងក្រៅប្រទេស (សេចក្តីសំរេចមហាសន្និបាតលេខ ៤១/៨៥ ចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ១៩៨៦) បានព្រមព្រៀងគ្នាដូចតទៅនេះ :

## ជំពូកទី ១
## វិសាលភាពនៃអនុសញ្ញា

**មាត្រា ១**

គោលបំណងនៃអនុសញ្ញាគឺដើម្បី :

(ក) បង្កើតមធ្យោបាយការពារដើម្បីធានាថា សុំកូនអន្តរប្រទេសធ្វើឡើងក្នុងឧត្តមប្រយោជន៍របស់កុមារនិងដោយសេចក្តីគោរពចំពោះសិទ្ធិជាមូលដ្ឋានរបស់កុមារដូចបានទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិ ។

(ខ) បង្កើតប្រព័ន្ធសហប្រតិបត្តិការក្នុងចំណោមរដ្ឋជាភាគីដើម្បីធានាថា មធ្យោបាយការពារទាំងនោះត្រូវបានគោរព ហើយតាមរយៈប្រព័ន្ធនោះទប់ស្កាត់ ការចាប់ពង្រត់ ការលក់ ឬ ការជួញដូរកុមារ ។

(គ) ធានាអោយមានការទទួលស្គាល់នៅក្នុងរដ្ឋជាភាគីថា សុំកូនត្រូវប្រព្រឹត្តទៅស្របតាមអនុសញ្ញានេះ។

**មាត្រា ២**

១) អនុសញ្ញានេះត្រូវអនុវត្តក្នុងករណីកុមារម្នាក់មានទីលំនៅជាទៀងទាត់នៅក្នុងរដ្ឋជាភាគីមួយ (រដ្ឋដើម) ត្រូវបាន កំពុង ឬនឹងត្រូវបានយកទៅនៅរដ្ឋជាភាគីមួយទៀត (រដ្ឋទទួល) ក្រោយពីការសំរេចលើសុំកូន ដោយសហព័ទ្ធ ឬដោយជនម្នាក់ដែលមានទីលំនៅជាទៀងទាត់នៅក្នុងរដ្ឋទទួលបានប្រព្រឹត្តទៅនៅក្នុងរដ្ឋដើម ឬ ក្នុងគោលបំណងសុំកូននេះ ការសំរេចលើសុំកូនធ្វើឡើងនៅក្នុងរដ្ឋទទួលក្តី ឬរដ្ឋដើមក្តី ។

២) អនុសញ្ញានេះគ្របដណ្តប់តែលើសុំកូនទាំងឡាយណា ដែលបង្កើតទំនាក់ទំនងជា ឪពុក/ម្តាយ និងកូនជាអចិន្ត្រៃយ៍ប៉ុណ្ណោះ ។

**មាត្រា ៣**

អនុសញ្ញានេះលែងអនុវត្តបានទៅទៀត បើការព្រមព្រៀងដែលបញ្ជាក់នៅក្នុងមាត្រា១៧ អនុកថាខ័ណ្ឌគ មិនបានធ្វើមុនពេលកុមារឈានដល់អាយុដប់ប្រាំបីឆ្នាំ ។

## ជំពូកទី ២
## លក្ខខ័ណ្ឌតម្រូវសំរាប់សុំកូនអន្តរប្រទេស

**មាត្រា ៤**

សុំកូនដែលស្ថិតក្នុងវិសាលភាពនៃអនុសញ្ញានេះ អាចប្រព្រឹត្តទៅបានលុះត្រាណាតែអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋដើម :

(ក) បានកំណត់ថាកុមារមានលក្ខណៈសម្បត្តិអាចសុំយកទៅចិញ្ចឹមបាន ។

(ខ) បានសំរេចថា សុំកូនអន្តរប្រទេសជាឧត្តមប្រយោជន៍របស់កុមារ បន្ទាប់ពីបានពិចារណាជិតដល់នូវលទ្ធភាពនៃការទុកដាក់កុមារនោះនៅក្នុងរដ្ឋដើម ។

(គ) បានធានាថា ៖-

(១) ជន ស្ថាប័ន និង អាជ្ញាធរដែលចាំបាច់ត្រូវយល់ព្រមលើសុំកូនត្រូវបានពិគ្រោះយោបល់ បើជាការ ចាំបាច់ ហើយត្រូវបានជូនពតិមានឱ្យបានដឹងដោយត្រឹមត្រូវអំពីផលប៉ះពាល់នៃការយល់ព្រមរបស់គេជាពិសេស ឱ្យដឹងថាតើសុំកូននោះនឹងនាំឱ្យមានការបញ្ចប់ទំនាក់ទំនងតាមផ្លូវច្បាប់រវាងកុមារ និង គ្រួសារកំណើតរបស់កុមារ ឬយ៉ាងណា ។

(២) ជន ស្ថាប័ន និងអាជ្ញាធរនោះផ្តល់ការយល់ព្រមរបស់ខ្លួនដោយសេរី តាមរយៈទម្រង់ ដែលច្បាប់តម្រូវ និងបញ្ជាក់ ឬផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ ។

(៣) ការយល់ព្រមទាំងនោះមិនបានធ្វើឡើងដោយសារការផ្តល់ប្រាក់កាស ឬការទូទាត់គ្នាតាមបែបណាមួយឡើយ និងមិនត្រូវបានដកវិញឡើយ ។ ហើយនិង

(៤) ការយល់ព្រមរបស់ម្តាយត្រូវបានផ្តល់តែបន្ទាប់ពីកូនកើតរួចហើយប៉ុណ្ណោះ ក្នុងករណីដែលមានការតម្រូវឱ្យម្តាយយល់ព្រម ។ ហើយនិង

(ឃ) បានធានា បន្ទាប់ពីបានគិតដល់អាយុ និងកំរិតនៃមជ្ឈឹមវ័យរបស់កុមារ ថា ៖-

(១) កុមារនោះត្រូវបានពិគ្រោះយោបល់ និងត្រូវបានប្រាប់ឱ្យដឹងត្រឹមត្រូវអំពីផលនៃសុំកូន និងអំពីផល នៃការយល់ព្រមរបស់ខ្លួនចំពោះសុំកូន ក្នុងករណីតម្រូវឱ្យមានការយល់ព្រមបែបនេះ ។

(២) មានការយកចិត្តទុកដាក់ដល់សេចក្តីប្រាថ្នា និងមតិរបស់កុមារ ។

(៣) ការយល់ព្រមរបស់កុមារចំពោះសុំកូន ក្នុងករណីតម្រូវឱ្យមានការយល់ព្រមបែបនេះ ត្រូវបានផ្តល់ដោយសេរីតាមទម្រង់ដែលច្បាប់តម្រូវ និងបញ្ជាក់ ឬផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ ហើយនិង

(៤) ការយល់ព្រមនោះមិនបានធ្វើឡើងដោយសារការផ្តល់ប្រាក់កាស ឬការទូទាត់គ្នាតាមបែបណាមួយឡើយ ។

**មាត្រា ៥**

សុំកូននៅក្នុងវិសាលភាពនៃអនុសញ្ញានេះ អាចប្រព្រឹត្តទៅបានលុះត្រាណាតែអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋទទួល ៖-

(ក) បានសំរេចថា អនាគតឪពុកម្តាយចិញ្ចឹមនោះ មានលក្ខណៈសម្បត្តិត្រឹមត្រូវ និងសមស្របអាចយកកូនមក

ចិញ្ចឹមបាន ។

(ខ) បានធានាថា អនាគតឪពុកម្តាយចិញ្ចឹមនោះ ត្រូវបានពិគ្រោះយោបល់ បើជាការចាំបាច់ ។ ហើយនិង

(គ) បានសំរេចថា កុមារនោះត្រូវបាន ឬ នឹងត្រូវបានអនុញ្ញាតឱ្យចូល និង រស់នៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋនោះ ។

## ជំពូកទី ៣

## អាជ្ញាធរកណ្តាល និង អង្គការដែលបានទទួលស្គាល់ជាផ្លូវការ

### មាត្រា ៦

១) រដ្ឋជាភាគីត្រូវចាត់តាំងអាជ្ញាធរកណ្តាល ដើម្បីបំពេញករណីយកិច្ចដែលអនុសញ្ញានេះបានកំណត់ ។

២) រដ្ឋសហព័ន្ធ រដ្ឋដែលមានប្រព័ន្ធច្បាប់លើសពីមួយ ឬរដ្ឋដែលមានដែនដីស្វយ័តត្រូវមានសេរីភាពតែងតាំងអាជ្ញាធរកណ្តាលលើសពីមួយ និង បញ្ជាក់សមត្ថកិច្ចដែនដី ឬ សមត្ថកិច្ចបុគ្គលនៃមុខងាររបស់អាជ្ញាធរទាំងនោះ ។ ក្នុងករណីរដ្ឋមួយបានតែងតាំងអាជ្ញាធរកណ្តាលលើសពីមួយ រដ្ឋនោះត្រូវចង្អុលប្រាប់ថា អាជ្ញាធរកណ្តាលណាដែលគេអាចបញ្ជូនពត៌មានទៅអាជ្ញាធរកណ្តាលសមស្របនៅក្នុងរដ្ឋនោះ ។

### មាត្រា ៧

១) អាជ្ញាធរកណ្តាលទាំងឡាយត្រូវធ្វើសហប្រតិបត្តិការជាមួយគ្នាទៅវិញទៅមក ហើយត្រូវលើកស្ទួយសហប្រតិបត្តិការក្នុងចំណោមអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងរដ្ឋរបស់ខ្លួន ដើម្បីការពារកុមារ និងដើម្បីធ្វើឱ្យបានសំរេចគោលបំណងដទៃទៀតនៃអនុសញ្ញានេះ ។

២) អាជ្ញាធរកណ្តាលទាំងឡាយត្រូវចាត់វិធានការសមស្រប និងដោយផ្ទាល់ដើម្បី ៖-

(ក) ផ្តល់ពត៌មានអំពីច្បាប់នៃរដ្ឋទាំងឡាយរបស់ខ្លួនដែលពាក់ព័ន្ធនឹងសុំកូន និងពត៌មានទូទៅដទៃទៀត ដូចជាស្ថិតិ និងទម្រង់ជាបទដ្ឋាន ។

(ខ) អាជ្ញាធរកណ្តាលនីមួយៗបានដឹងទៅវិញទៅមកអំពីប្រតិបត្តិការនៃអនុសញ្ញានេះ ហើយបើអាចធ្វើទៅបាន កំចាត់ចោលឧបសគ្គទាំងឡាយនៃការអនុវត្តន៍អនុសញ្ញានេះ ។

### មាត្រា ៨

អាជ្ញាធរកណ្តាលទាំងឡាយ ដោយផ្ទាល់ក្តី ឬតាមរយៈអាជ្ញាធរសាធារណៈក្តី ត្រូវចាត់វិធានការទាំងអស់ដែលសមស្របដើម្បីទប់ស្កាត់ការកេងយកចំណេញមិនត្រឹមត្រូវផ្នែកហិរញ្ញវត្ថុ ឬ ការកេងយកចំណេញដទៃទៀតដែលទាក់ទងនឹងសុំកូន និងដើម្បីទប់ស្កាត់ការអនុវត្តន៍ទាំងអស់ដែលផ្ទុយនឹងគោលបំណងនៃអនុសញ្ញានេះ ។

**មាត្រា ៩**

អាជ្ញាធរកណ្ដាលទាំងឡាយ ដោយផ្ទាល់ក្ដី ឬតាមរយៈអាជ្ញាធរសាធារណៈក្ដី ឬអង្គការដែលបានទទួលស្គាល់ត្រឹមត្រូវជាផ្លូវការក្ដីនៅក្នុងរដ្ឋរបស់ខ្លួន ត្រូវចាត់វិធានការទាំងអស់ដែលសមស្របជាពិសេសដើម្បី ៖-

(ក) ប្រមូល រក្សាទុក និងផ្លាស់ប្ដូរពត៌មានអំពីស្ថានភាពកុមារ និងអនាគតឪពុកម្ដាយចិញ្ចឹម ក្នុងករណីចាំបាច់ដើម្បីបញ្ចប់សុំកូន ។

(ខ) ជួយសំរួល ប្រតិបត្តិតាម និងជំរុញនីតិវិធីឱ្យបានលឿនដើម្បីឱ្យបានការអនុញ្ញាតសុំកូន ។

(គ) លើកស្ទួយការបង្កើតសេវាកម្មផ្ដល់ការពិគ្រោះយោបល់ខាងសុំកូន និងសេវាកម្មក្រោយពេលសុំកូននៅក្នុងរដ្ឋរបស់ខ្លួន ។

(ឃ) ផ្ដល់របាយការណ៍វាយតម្លៃទូទៅដល់គ្នាទៅវិញទៅមក អំពីបទពិសោធន៍នៃសុំកូនអន្តរប្រទេស ។

(ង) ឆ្លើយតបក្នុងករណីច្បាប់នៃរដ្ឋរបស់ខ្លួនអនុញ្ញាត ចំពោះសេចក្ដីស្នើសុំដែលមានហេតុផលពីអាជ្ញាធរកណ្ដាលដទៃទៀត ឬ អាជ្ញាធរសាធារណៈដែលចង់បានពត៌មានអំពីស្ថានភាពពិសេសណាមួយនៃសុំកូន ។

**មាត្រា ១០**

ការទទួលស្គាល់ជាផ្លូវការត្រូវផ្ដល់ឱ្យ ហើយការទទួលស្គាល់នោះរក្សាបានចំពោះតែអង្គការណា ដែលបង្ហាញសមត្ថភាពរបស់ខ្លួនក្នុងការអនុវត្តន៍ត្រឹមត្រូវនូវភារកិច្ចដែលខ្លួនបានទទួល ។

**មាត្រា ១១**

អង្គការដែលបានទទួលស្គាល់ជាផ្លូវការត្រូវ ៖-

(ក) បំរើតែទិសដៅមិនរកកំរៃស្របទៅតាមលក្ខខ័ណ្ឌនិងក្នុងកំរិតព្រំដែន ដែលអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋទទួលស្គាល់នោះបានកំណត់ឱ្យ ។

(ខ) បានដឹកនាំដោយមនុស្ស និងមានបុគ្គលិកដែលមានគុណសម្បត្តិសមស្របតាមបទដ្ឋានសីលធម៌ ហើយអ្នកដឹកនាំ និងបុគ្គលិកទាំងនោះ ត្រូវទទួលបានការបណ្ដុះបណ្ដាល ឬមានបទពិសោធន៍ការងារនៅក្នុងវិស័យសុំកូនអន្តរប្រទេស ។ និង

(គ) ស្ថិតក្រោមការត្រួតពិនិត្យពីអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋនោះ លើសមាសភាព ប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ នៃអង្គការនោះ ។

**មាត្រា ១២**

អង្គការដែលបានទទួលស្គាល់ជាផ្លូវការនៅក្នុងរដ្ឋជាភាគីមួយ អាចបំពេញនាទីនៅក្នុងរដ្ឋជាភាគីមួយទៀតបានលុះត្រាណាតែអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋទាំងពីរបានអនុញ្ញាតឱ្យធ្វើដូច្នេះ ។

**មាត្រា ១៣**

រដ្ឋជាភាគីនីមួយៗត្រូវជូនពត៌មានទៅការិយាល័យអចិន្ត្រៃយ៍នៃសន្និសីទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិឯកជនអំពីការចាត់តាំងអាជ្ញាធរកណ្តាល ហើយក្នុងករណីសមស្របអំពីទំហំនៃមុខងាររបស់អាជ្ញាធរនោះ ព្រមទាំងឈ្មោះ និង អាសយដ្ឋាននៃអង្គការដែលបានទទួលស្គាល់ជាផ្លូវការ ។

## ជំពូកទី ៤

## លក្ខខណ្ឌផ្នែកនីតិវិធីសំរាប់សុំកូនអន្តរប្រទេស

**មាត្រា ១៤**

ជនដែលមានទីលំនៅជាទៀងទាត់នៅក្នុងរដ្ឋជាភាគីមួយ ដែលប្រាថ្នាចង់យកកុមារម្នាក់ដែលមានលំនៅជាទៀងទាត់នៅក្នុងរដ្ឋជាភាគីណាមួយទៀតទៅចិញ្ចឹម ត្រូវដាក់ពាក្យទៅអាជ្ញាធរកណ្តាលនៅក្នុងរដ្ឋជាទីលំនៅជាទៀងទាត់របស់ខ្លួន ។

**មាត្រា ១៥**

១) ប្រសិនបើអាជ្ញាធរកណ្តាលនៃរដ្ឋទទួលពេញចិត្តថាអ្នកដាក់ពាក្យនោះមានលក្ខណៈសម្បត្តិ និងសមស្របអាចយកកុមារមកចិញ្ចឹមបាន អាជ្ញាធរកណ្តាលនោះត្រូវរៀបចំរបាយការណ៍មួយដោយរួមបញ្ចូលពត៌មាន អំពីអត្តសញ្ញាណលក្ខណៈសម្បត្តិនិងភាពសមស្របអាចសុំកូនបាន ប្រវត្តិផ្ទាល់ខ្លួន ប្រវត្តិគ្រួសារ និង ប្រវត្តិផ្នែកពេទ្យ បរិយាកាសសង្គមហេតុផលសុំកូន សមត្ថភាពដើម្បីយកកុមារពីប្រទេសមួយទៀតមកចិញ្ចឹមរបស់អ្នកដាក់ពាក្យទាំងនោះ ព្រមទាំងចរិតលក្ខណៈនៃកុមារដែលគេអាចយកមកបីបាច់រក្សាបាន ។

២) អាជ្ញាធរកណ្តាល នៃរដ្ឋទទួលត្រូវផ្ញើរបាយការណ៍នេះទៅឱ្យអាជ្ញាធរកណ្តាលនៃរដ្ឋដើម ។

**មាត្រា ១៦**

១) បើអាជ្ញាធរកណ្តាលនៃរដ្ឋដើមពេញចិត្តថា កុមារនោះមានលក្ខណៈសម្បត្តិអាចអោយគេយកទៅចិញ្ចឹមបាន អាជ្ញាធរនោះត្រូវ ៖-

(ក) រៀបចំរបាយការណ៍មួយដោយរួមបញ្ចូលពត៌មានអំពីអត្តសញ្ញាណ ភាពអាចយកទៅចិញ្ចឹមជាកូនបាន

ប្រវត្តិ បរិយាកាសសង្គម ប្រវត្តិគ្រួសារ ប្រវត្តិផ្នែកពេទ្យរបស់កុមារ រួមទាំងប្រវត្តិផ្នែកពេទ្យរបស់គ្រួសារកុមារផង និង សេចក្តីត្រូវការពិសេសរបស់កុមារ ។

(ខ) ធ្វើការពិចារណាដិតដល់លើការចិញ្ចឹមបីបាច់កុមារ និង ប្រវត្តិជាតិពន្ធ សាសនា និងវប្បធម៌របស់កុមារនោះ ។

(គ) ធានាថា ការយល់ព្រមត្រូវបានស្របនឹងមាត្រា ៤ ។ ហើយនិង

(ឃ) សំរេចថា តើការទុកដាក់កុមារតាមការស្នើសុំនោះស្ថិតក្នុងឧត្តមប្រយោជន៍របស់កុមារដែរ ឬទេ ដោយសំអាងជាពិសេសលើរបាយការណ៍ទាក់ទងនឹងកុមារ និងអនាគតឪពុកម្តាយចិញ្ចឹម ។

២) អាជ្ញាធរកណ្តាលនៃរដ្ឋដើមត្រូវបញ្ជូនអោយអាជ្ញាធរកណ្តាលនៃរដ្ឋទទួលនូវរបាយការណ៍របស់ខ្លួន ស្តីពីកុមារ ភស្តុតាងដែលបញ្ជាក់ថាមានការយល់ព្រមជាចាំបាច់ និង ហេតុផលនៃការសំរេចរបស់ខ្លួនស្តីពីការអោយសុំកូននោះដោយយកចិត្តទុកដាក់មិនបញ្ចេញឱ្យដឹងអត្តសញ្ញាណនៃម្តាយនិងឪពុករបស់កុមារ ប្រសិនបើអត្តសញ្ញាណនេះមិនអាចបញ្ចេញឱ្យដឹងបាននៅក្នុងរដ្ឋដើម ។

**មាត្រា ១៧**

សេចក្តីសំរេចណាមួយនៅក្នុងរដ្ឋដើមដែលថា កុមារម្នាក់គួរតែបានប្រគល់អោយអនាគតឪពុកម្តាយចិញ្ចឹមថែទាំ នោះអាចធ្វើបានលុះត្រាណាតែ ៖-

(ក) អាជ្ញាធរកណ្តាលនៃរដ្ឋនោះបានធានាថាអនាគតឪពុកម្តាយចិញ្ចឹមបានព្រមព្រៀង

(ខ) អាជ្ញាធរកណ្តាលនៃរដ្ឋទទួលបានយល់ព្រមលើសេចក្តីសំរេចនោះ ក្នុងករណីច្បាប់នៃរដ្ឋនោះ ឬអាជ្ញាធរកណ្តាលនៃរដ្ឋដើមតម្រូវឱ្យមានការយល់ព្រមបែបនោះ

(គ) អាជ្ញាធរកណ្តាលនៃរដ្ឋទាំងពីរបានព្រមព្រៀងគ្នាថា សុំកូនអាចប្រព្រឹត្តទៅបាន ។ ហើយនិង

(ឃ) អាជ្ញាធរកណ្តាលនៃរដ្ឋដើមបានពិនិត្យឃើញថា អនាគតឪពុកម្តាយចិញ្ចឹមមានលក្ខណៈសម្បត្តិ និងសមស្រប អាចយកកុមារទៅចិញ្ចឹមបាន ហើយកុមារនោះត្រូវបាន ឬ នឹងត្រូវបានអនុញ្ញាតឱ្យចូលនិងរស់នៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋទទួលស្របតាមមាត្រា ៥ ។

**មាត្រា ១៨**

អាជ្ញាធរកណ្តាលនៃរដ្ឋទាំងពីរត្រូវចាត់វិធានការជាចាំបាច់ ដើម្បីបានការអនុញ្ញាតឱ្យកុមារចាកចេញពីរដ្ឋដើម និងចូល និងរស់នៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋទទួល ។

**មាត្រា ១៩**

១) ការផ្ទេរកុមារទៅរដ្ឋទទួលអាចអនុវត្តបាន លុះត្រាតែលក្ខខ័ណ្ឌទាំងឡាយនៃមាត្រា ១៧ ត្រូវបានបំពេញ ។

២) អាជ្ញាធរកណ្តាលនៃរដ្ឋទាំងពីរត្រូវធានាថា ការផ្ទេរនេះធ្វើឡើងនៅក្នុងកាលៈទេសៈធានាសន្តិសុខនិងសមស្រប ហើយប្រសិនបើអាចធ្វើបានដោយមានការរួមដំណើរនៃឪពុកម្តាយចិញ្ចឹម ឬ អនាគតឪពុកម្តាយចិញ្ចឹម ។

៣) បើការផ្ទេរកុមារនោះមិនបានធ្វើឡើងទេនោះ របាយការណ៍ដែលបានពោលនៅក្នុងមាត្រា ១៥ និង ១៦ ត្រូវធ្វើត្រឡប់មកឱ្យអាជ្ញាធរដែលបញ្ជូនរបាយការណ៍នោះវិញ ។

**មាត្រា ២០**

អាជ្ញាធរកណ្តាលត្រូវជូនពត៌មានគ្នាទៅវិញទៅមកឱ្យបានដឹងជានិច្ចអំពីដំណើរការសុំកូន និងវិធានការដើម្បីធ្វើឱ្យសុំកូននេះបានចប់សព្វគ្រប់ ព្រមទាំងអំពីដំណើរជឿនលឿននៃការទុកដាក់កុមារ បើមានការតម្រូវឱ្យមានរយៈពេលសាកល្បង ។

**មាត្រា ២១**

១) ក្នុងករណីសុំកូនត្រូវសំរេចនៅពេលក្រោយកុមារត្រូវបានផ្ទេរទៅរដ្ឋទទួល ហើយអាជ្ញាធរកណ្តាលនៃរដ្ឋនោះយល់ឃើញថា ការទុកដាក់កុមារបន្តទៅទៀតជាមួយនឹងអនាគតឪពុកម្តាយចិញ្ចឹម មិនបំរើឧត្តមប្រយោជន៍របស់កុមារ អាជ្ញាធរកណ្តាលនោះត្រូវចាត់វិធានការចាំបាច់ ដើម្បីការពារកុមារ ជាពិសេស ៖-

(ក) ធ្វើយ៉ាងណាដកកុមារចេញពីអនាគតឪពុកម្តាយចិញ្ចឹម ហើយរៀបចំឱ្យមានការចិញ្ចឹមបីបាច់បណ្តោះអាសន្ន ។

(ខ) ដោយពិគ្រោះយោបល់ជាមួយអាជ្ញាធរកណ្តាលនៃរដ្ឋដើម រៀបចំដោយគ្មានបង្អង់ឱ្យមានការទុកដាក់កុមារនេះជាថ្មី ក្នុងគោលបំណងសុំកូនជំដែល ឬបើរបៀបនេះមិនសមស្របទេនោះ រៀបចំឱ្យមានការថែទាំជំនួសរយៈពេលវែង ។ សុំកូនមិនអាចប្រព្រឹត្តទៅបានមុនពេលដែលអាជ្ញាធរកណ្តាលនៃរដ្ឋដើមបានទទួលពត៌មានត្រឹមត្រូវទាក់ទងនឹងអនាគតឪពុកម្តាយចិញ្ចឹមថ្មី ។

(គ) មធ្យោបាយចុងក្រោយបង្អស់គឺ ត្រូវរៀបចំបញ្ជូនកុមារទៅរដ្ឋដើមវិញ បើផលប្រយោជន៍របស់កុមារតម្រូវឱ្យធ្វើដូច្នោះ ។

២) ដោយយោលជាពិសេសទៅលើអាយុ និង កំរិតមធ្យ៉ឹមវ័យរបស់កុមារ កុមារត្រូវតែបានពិគ្រោះយោបល់ ហើយក្នុងករណីសមស្របត្រូវតែបានការយល់ព្រមពីកុមារ ទាក់ទងនឹងវិធានការដែលត្រូវចាត់តាមមាត្រានេះ ។

**មាត្រា ២២**

១) មុខងាររបស់អាជ្ញាធរកណ្តាលនៅក្រោមជំពូកនេះ អាចបំពេញដោយអាជ្ញាធរសាធារណៈ ឬ អង្គការដែលបានទទួលស្គាល់ជាផ្លូវការក្រោមជំពូកទី៣ ក្នុងកំរិតដែលអនុញ្ញាតដោយច្បាប់នៃរដ្ឋរបស់អាជ្ញាធរនោះ ។

២) រដ្ឋជាភាគីអាចប្រកាសចំពោះមន្ទីរដំកល់អនុសញ្ញានេះថា មុខងារនៃអាជ្ញាធរកណ្តាលនៅក្រោមមាត្រា១៥ ដល់មាត្រា ២១ អាចបំពេញបានផងដែរនៅក្នុងរដ្ឋនោះ (ក្នុងកំរិតដែលច្បាប់បានអនុញ្ញាត និង ដោយមានការត្រួតពិនិត្យពីអាជ្ញាធរមានសមត្ថកិច្ច នៃរដ្ឋនោះ) ដោយអង្គការ ឬ ជនដែល ៖-

(ក) បំពេញបាននូវលក្ខខ័ណ្ឌស្តីពីសុចរិតធម៌ សមត្ថភាពខាងវិជ្ជាជីវៈ បទពិសោធន៍ និងភាពទទួលខុសត្រូវតាមការកំណត់របស់រដ្ឋនោះ ។ ហើយនិង

(ខ) មានលក្ខណៈសម្បត្តិដោយសារបំពេញបាននូវបទដ្ឋានសីលធម៌ និងទទួលបានការបណ្តុះបណ្តាល ឬ មានបទពិសោធន៍ធ្វើការ ក្នុងវិស័យសុំកូនអន្តរប្រទេស ។

៣) រដ្ឋជាភាគីដែលធ្វើសេចក្តីប្រកាសដូចបានចែងក្នុងកថាខ័ណ្ឌ ២ ត្រូវឱ្យការិយាល័យអចិន្ត្រៃយ៍នៃសន្និសិទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិឯកជនបានដឹងអំពីឈ្មោះ និង អាសយដ្ឋាននៃអង្គការ និង ជនទាំងនេះ ។

៤) រដ្ឋជាភាគីអាចប្រកាសចំពោះមន្ទីរដំកល់អនុសញ្ញានេះថា ការសុំយកទៅចិញ្ចឹមនូវកុមារដែលមានទីលំនៅជាទៀងទាត់នៅក្នុងដែនដីរបស់ខ្លួន អាចប្រព្រឹត្តទៅបាន លុះត្រាណាតែមុខងារនៃអាជ្ញាធរកណ្តាល ត្រូវបានបំពេញស្របតាមកថាខ័ណ្ឌ ១ ។

៥) ថ្វីបើមានការប្រកាសណាមួយស្របតាមកថាខ័ណ្ឌ២ក្តី ក្នុងគ្រប់ករណីទាំងអស់របាយការណ៍ដែលចែងនៅក្នុងមាត្រា ១៥ និង ១៦ ត្រូវតែបានរៀបចំនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរកណ្តាល ឬអាជ្ញាធរដទៃទៀត ឬ អង្គការនានាស្របតាមកថាខ័ណ្ឌ ១ ។

## ជំពូកទី ៥

## ការទទួលស្គាល់ និង ផលនៃសុំកូន

**មាត្រា ២៣**

១) សុំកូនដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច នៃរដ្ឋដែលសំរេចលើសុំកូនថា បានធ្វើឡើងស្របតាមអនុសញ្ញានេះ ត្រូវតែបានទទួលស្គាល់ជាស្វ័យប្រវត្តិដោយច្បាប់នៅក្នុងរដ្ឋជាភាគីដទៃទៀត ។ លិខិតបញ្ជាក់នោះត្រូវបញ្ជាក់ពេល

វេលា និង អ្នកដែលផ្តល់ការព្រមព្រៀងស្របតាមមាត្រា ១៧ អនុកថាខ័ណ្ឌ គ ។

២) រដ្ឋជាភាគីនីមួយៗ នៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬចូលរួម ត្រូវផ្តល់ដំណឹងដល់មន្ទីរតំកល់អនុសញ្ញានេះអំពីអត្តសញ្ញាណ និងមុខងារនៃអាជ្ញាធរដែលមានសមត្ថកិច្ចក្នុងការធ្វើលិខិតបញ្ជាក់នៅក្នុងរដ្ឋនោះ។ រដ្ឋនោះក៏ត្រូវផ្តល់ដំណឹងដល់មន្ទីរតំកល់ដែរ អំពីការកែប្រែ ការតែងតាំងអាជ្ញាធរទាំងនេះ ។

**មាត្រា ២៤**

ការទទួលស្គាល់ស្មុំកូនអាចបដិសេធបាននៅក្នុងរដ្ឋជាភាគីណាមួយបាន លុះត្រាណាតែស្មុំកូននោះផ្ទុយជាក់ស្តែង នឹងនយោបាយសាធារណៈនៃរដ្ឋនោះ ដោយពិចារណាដល់ឧត្តមប្រយោជន៍របស់កុមារ ។

**មាត្រា ២៥**

រដ្ឋជាភាគីអាចប្រកាសចំពោះមន្ទីរតំកល់អនុសញ្ញាថា ខ្លួននឹងមិនជាប់កាតព្វកិច្ចនៅក្រោមអនុសញ្ញានេះ ដើម្បីទទួលស្គាល់ស្មុំកូនដែលធ្វើស្របតាមការព្រមព្រៀងណាមួយ ដែលបានសំរេចឡើងដោយការអនុវត្តន៍មាត្រា ៣៩ កថាខ័ណ្ឌ ២ ឡើយ ។

**មាត្រា ២៦**

១) ការទទួលស្គាល់ស្មុំកូនរួមបញ្ចូលការទទួលស្គាល់ :

(ក) ទំនាក់ទំនងផ្លូវច្បាប់ជា ឪពុក/ម្តាយ និងកូន រវាងកូន និងឪពុកម្តាយចិញ្ចឹមរបស់កុមារនោះ ។

(ខ) ការទទួលខុសត្រូវផ្នែកមេបានៃឪពុកម្តាយចិញ្ចឹមរបស់កុមារ ។

(គ) ការបញ្ចប់ទំនាក់ទំនងផ្លូវច្បាប់ដែលមានពីមុនមក រវាងកូន និងម្តាយ និងឪពុករបស់កុមារ បើស្មុំកូនមានផលដូច្នេះ នៅក្នុងរដ្ឋជាភាគីដែលសំរេចលើស្មុំកូននោះ។

២) ក្នុងករណីដែលស្មុំកូនមានផលបញ្ចប់ទំនាក់ទំនងផ្លូវច្បាប់ដែលមានពីមុនមក រវាងឪពុកម្តាយ និងកូន កុមារត្រូវទទួលបាននៅក្នុងរដ្ឋទទួល និង នៅក្នុងរដ្ឋជាភាគីដទៃទៀតដែលទទួលស្គាល់ស្មុំកូននូវសិទ្ធិស្មើគ្នា និង សិទ្ធិដែលកើតមកពីស្មុំកូនដែលមានផលដូច្នេះនៅក្នុងរដ្ឋនីមួយៗនោះ ។

៣) កថាខ័ណ្ឌមុនៗនេះ មិនត្រូវឱ្យខូចខាតដល់ការអនុវត្តន៍បញ្ញត្តិណាមួយដែលឱ្យអំណោយផលដល់កុមារច្រើនជាង ហើយដែលនៅជាធរមាននៅក្នុងរដ្ឋជាភាគីដែលទទួលស្គាល់ស្មុំកូនឡើយ ។

**មាត្រា ២៧**

១) ក្នុងករណីសុំកូនដែលត្រូវបានអនុញ្ញាតនៅក្នុងរដ្ឋដើម មិនមានផលបញ្ចប់ទំនាក់ទំនងផ្លូវច្បាប់ដែលមានពីមុន មករវាងឪពុក/ម្តាយ និងកូនទទេនោះ សុំកូននោះអាចកែប្រែទៅជាសុំកូនមួយដែលមានផលដូច្នោះនៅក្នុងរដ្ឋទទួល ដែលទទួលស្គាល់សុំកូននៅក្រោមអនុសញ្ញានេះ :

(ក) បើច្បាប់នៃរដ្ឋទទួលអនុញ្ញាតអោយកែប្រែដូច្នេះ ។ និង

(ខ) បើការយល់ព្រមដូចបានពោលនៅក្នុងមាត្រា ៤ អនុកថាខ័ណ្ឌ **គ** និង **ឃ** ត្រូវបានផ្តល់សំរាប់គោលបំណងនៃសុំកូននោះ ។

២) មាត្រា ២៣ អនុវត្តចំពោះសេចក្តីសំរេចស្តីពីការកែប្រែសុំកូន ។

## ជំពូកទី ៦
## បទប្បញ្ញត្តិទូទៅ

**មាត្រា ២៨**

អនុសញ្ញានេះមិនមានផលប៉ះពាល់ដល់ច្បាប់ណាមួយនៃរដ្ឋដើមដែលតម្រូវថា សុំកូនណាមួយដែលមានទីលំនៅជាទៀងទាត់នៅក្នុងរដ្ឋនោះ ត្រូវតែសំរេចនៅក្នុងរដ្ឋនោះទេ ឬដែលហាមឃាត់ការទុកដាក់កុមារ ឬផ្ទេរកុមារទៅរដ្ឋទទួល មុនពេលសំរេចលើសុំកូនទេ ។

**មាត្រា ២៩**

មិនត្រូវមានការជួបទាក់ទង រវាងអនាគតឪពុកម្តាយចិញ្ចឹម និងឪពុកម្តាយរបស់កុមារ ឬជនដទៃទៀត ដែលថាំនបីបាច់រក្សាកុមារទេ រហូតទាល់តែលក្ខខ័ណ្ឌនៃមាត្រា ៤ អនុកថាខ័ណ្ឌ**ក** ដល់**គ** និងមាត្រា ៥ អនុកថាខ័ណ្ឌ**ក** បានបំពេញរួច សិនលើកលែងតែសុំកូននោះកើតមាននៅក្នុងគ្រួសារមួយ ឬ លើកលែងតែការជួបទាក់ទងនោះស្របតាមលក្ខខ័ណ្ឌដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋដើម ។

**មាត្រា ៣០**

១) អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋជាភាគីត្រូវធានាថា ពត៌មានដែលខ្លួនរក្សាទុកទាក់ទងនឹងដើមកំណើតរបស់កុមារ ជាពិសេសពត៌មានទាក់ទងនឹងអត្តសញ្ញាណឪពុកម្តាយរបស់កុមារ ព្រមទាំងប្រវត្តិផ្នែកពេទ្យត្រូវបានរក្សាការពារ ។

២) អាជ្ញាធរមានសមត្ថកិច្ចទាំងនោះត្រូវធានាថាកុមារ ឬតំណាងរបស់កុមារមានសិទ្ធិទទួលបានពត៌មាននោះក្រោម

ការណែនាំដ៏សមស្របក្នុងករណីដែលច្បាប់នៃរដ្ឋនោះអនុញ្ញាត ។

**មាត្រា ៣១**

ដោយមិនប៉ះពាល់ដល់មាត្រា ៣០ ទិន្នន័យផ្ទាល់ខ្លួនដែលប្រមូលបាន ឬដែលត្រូវបានបញ្ជូនស្របតាមអនុសញ្ញានេះ ជាពិសេសទិន្នន័យដូចបានពោលក្នុងមាត្រា ១៥ និង ១៦ ត្រូវប្រើប្រាស់សំរាប់តែគោលបំណងដែលគេប្រមូល ឬ បញ្ជូនប៉ុណ្ណោះ ។

**មាត្រា ៣២**

១) គ្មានជនណាម្នាក់ទាញយកផលកំរៃផ្នែកហិរញ្ញវត្ថុ ឬផលកំរៃដទៃទៀតពីសកម្មភាពទាក់ទងនឹងសុំកូនអន្តរប្រទេសទេ ។

២) មានតែសោហ៊ុយនិងប្រាក់ចំណាយ រួមមានប្រាក់ឈ្នួលវិជ្ជាជីវៈសមរម្យរបស់ជនដែលពាក់ព័ន្ធក្នុងរឿងសុំកូនប៉ុណ្ណោះ ដែលអាចយកបាន ឬ ចំណាយបាន ។

៣) នាយក អភិបាល និងនិយោជិតនៃអង្គការដែលពាក់ព័ន្ធក្នុងរឿងសុំកូនមិនត្រូវទទួលលាភការដែលខ្ពស់មិនសមរម្យទាក់ទងនឹងសេវាកម្មដែលខ្លួនបានផ្តល់ទេ ។

**មាត្រា ៣៣**

អាជ្ញាធរមានសមត្ថកិច្ចដែលឃើញថាបញ្ញត្តិណាមួយនៃអនុសញ្ញានេះ មិនទាន់បានគោរព ឬឃើញថាអាចមានគ្រោះថ្នាក់ធ្ងន់ធ្ងរ បណ្តាលមកពីការមិនគោរពបញ្ញត្តិនោះ ត្រូវជូនពត៌មានជាបន្ទាន់ដល់អាជ្ញាធរកណ្តាលនៃរដ្ឋរបស់ខ្លួន ។ អាជ្ញាធរកណ្តាលនេះត្រូវទទួលខុសត្រូវក្នុងការធានាថា វិធានការសមស្របត្រូវបានប្រកាន់យក ។

**មាត្រា ៣៤**

បើអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋទទួលឯកសារស្នើសុំឱ្យបកប្រែឯកសារណាមួយ អត្ថបទបកប្រែដែលបានបញ្ជាក់ថាស្របគ្នានឹងអត្ថបទដើមហើយនោះត្រូវតែបានផ្តល់តាមការស្នើសុំ ។ លើកលែងតែមានចែងផ្សេងពីនេះ សោហ៊ុយនៃការបកប្រែនោះគឺជាបន្ទុករបស់អនាគតឪពុកម្តាយចិញ្ចឹម ។

**មាត្រា ៣៥**

អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋជាភាគីត្រូវចាត់ការដោយរួសរាន់នៅក្នុងដំណើរការសុំកូន ។

**មាត្រា ៣៦**

ទាក់ទងនឹងរដ្ឋមួយដែលមានប្រព័ន្ធច្បាប់ពីរឬច្រើនជាងនេះ ចំពោះរឿងសុំកូនដែលអនុវត្តនៅក្នុងដែនដីផ្សេងៗ :

(ក) ការនិយាយថា *ទីលំនៅជាទៀងទាត់នៅក្នុងរដ្ឋនោះ* ត្រូវបកស្រាយថា គេចង់និយាយសំដៅដល់ *ទីលំនៅជា*

*ទៀងទាត់នៅក្នុងដែនដីមួយនៃរដ្ឋនោះ* ។

(ខ) ការនិយាយថា *ច្បាប់នៃរដ្ឋនោះ* ត្រូវបកស្រាយថា គេចង់និយាយសំដៅដល់ *ច្បាប់ជាធរមាននៅក្នុងដែនដីមួយដែលពាក់ព័ន្ធនៅក្នុងរដ្ឋនោះ*។

(គ) ការនិយាយថា *អាជ្ញាធរមានសមត្ថកិច្ច ឬអាជ្ញាធរសាធារណៈនៃរដ្ឋនោះ* ត្រូវបកស្រាយថា គេចង់និយាយសំដៅដល់ *អាជ្ញាធរទាំងឡាយដែលត្រូវបានអនុញ្ញាតឱ្យបំពេញនាទីនៅក្នុងដែនដីមួយដែលពាក់ព័ន្ធនៅក្នុងរដ្ឋនោះ*។

(ឃ) ការនិយាយថា *អង្គការដែលបានទទួលស្គាល់ជាផ្លូវការនៅក្នុងរដ្ឋនោះ* ត្រូវបកស្រាយថាគេចង់និយាយសំដៅដល់ *អង្គការដែលបានទទួលស្គាល់ជាផ្លូវការនៅក្នុងដែនដីមួយដែលពាក់ព័ន្ធនៅក្នុងរដ្ឋនោះ* ។

**មាត្រា ៣៧**

ទាក់ទងនឹងរដ្ឋមួយក្នុងរឿងសុំកូនមានប្រព័ន្ធច្បាប់ពីរ ឬច្រើនជាងនេះដែលអាចអនុវត្តបានលើប្រភេទមនុស្សផ្សេងគ្នា ការនិយាយដល់ច្បាប់នៃរដ្ឋនោះ ត្រូវបកស្រាយថា គេចង់និយាយដល់ប្រព័ន្ធច្បាប់ដែលបញ្ជាក់ដោយច្បាប់នៃរដ្ឋនោះ ។

**មាត្រា ៣៨**

រដ្ឋមួយដែលក្នុងនោះដែនដីចំណុះផ្សេងៗគ្នាមានវិធាននៃច្បាប់របស់ខ្លួនរៀងៗខ្លួនទាក់ទងនឹងរឿងសុំកូន មិនត្រូវជាប់កាតព្វកិច្ចត្រូវអនុវត្តអនុសញ្ញានេះទេ ក្នុងករណីដែលរដ្ឋមួយដែលមានប្រព័ន្ធច្បាប់រួមមិនជាប់កាតព្វកិច្ចត្រូវអនុវត្តអនុសញ្ញានេះ ។

**មាត្រា ៣៩**

១) អនុសញ្ញានេះមិនមានផលប៉ះពាល់ដល់លិខិតូបករណ៍អន្តរជាតិណាមួយ ដែលរដ្ឋជាភាគីអនុសញ្ញានេះ ក៏ជាភាគីនៃលិខិតូបករណ៍នោះដែរ ហើយលិខិតូបករណ៍នោះមានបញ្ញត្តិអំពីរឿងទាំងឡាយ ដែលគ្រប់គ្រងដោយអនុសញ្ញានេះ លើកលែងតែរដ្ឋជាភាគីនៃលិខិតូបករណ៍នោះបានធ្វើសេចក្តីប្រកាសផ្ទុយពីនេះ ។

២) រដ្ឋជាភាគីមួយអាចចុះកិច្ចព្រមព្រៀងជាមួយរដ្ឋជាភាគីមួយ ឬច្រើនក្នុងទិសដៅធ្វើឱ្យប្រសើរឡើងដល់ការអនុវត្តន៍អនុសញ្ញានេះនៅក្នុងទំនាក់ទំនងគ្នាទៅវិញទៅមករវាងរដ្ឋទាំងនេះ។ កិច្ចព្រមព្រៀងទាំងនេះអាចចៀងខុសតែពីបញ្ញត្តិនៃមាត្រា ១៤ ដល់ ១៦ និង ១៨ ដល់ ២១ នៃអនុសញ្ញាប៉ុណ្ណោះ ។ រដ្ឋដែលបានចុះកិច្ចព្រមព្រៀងត្រូវបញ្ជូនសេចក្តីចម្លងនៃអត្ថបទកិច្ចព្រមព្រៀងនោះទៅមន្ទីរតំកល់អនុសញ្ញានោះ ។

**មាត្រា ៤០**

រដ្ឋជាភាគីត្រូវអនុវត្តអនុសញ្ញានេះទាំងស្រុង ដោយមិនអនុញ្ញាតឱ្យលើកលែងបទបញ្ញត្តិណាមួយឡើយ ។

**មាត្រា ៤១**

អនុសញ្ញានេះត្រូវអនុវត្តនៅគ្រប់ករណី កាលណាគេបានទទួលពាក្យសុំកូន ដូចមានចែងក្នុងមាត្រា ១៤ រួចហើយ និង ក្រោយពីអនុសញ្ញានេះបានចូលជាធរមាននៅក្នុងរដ្ឋទទួល និង រដ្ឋដើម ។

**មាត្រា ៤២**

អគ្គលេខាធិការនៃសន្និសិទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិឯកជន ត្រូវកោះប្រជុំនៅក្នុងចន្លោះពេលទៀងទាត់នូវគណៈកម្មការពិសេស ដើម្បីពិនិត្យមើលឡើងវិញ ពីដំណើរការអនុវត្តជាក់ស្តែងនៃអនុសញ្ញានេះ ។

## ជំពូកទី ៧

## ខអចសាន្ត

**មាត្រា ៤៣**

១) អនុសញ្ញានេះត្រូវទុកចំហរអោយចុះហត្ថលេខាដោយរដ្ឋ ដែលជាសមាជិកនៃសន្និសិទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិឯកជនពេលសម័យប្រជុំលើកទី ១៧ និង ដោយរដ្ឋដទៃទៀតដែលបានចូលរួមក្នុងសម័យប្រជុំនោះ ។

២) អនុសញ្ញានេះត្រូវបានផ្តល់សច្ចាប័ន ទទួលយក ឬយល់ព្រម ហើយលិខិតូបករណ៍នៃសច្ចាប័ន ការទទួលយក ឬការយល់ព្រម ត្រូវតំកល់ទុកនៅក្រសួងការបរទេសនៃព្រះរាជាណាចក្រហុល្លង់ នៅមន្ទីរតំកល់អនុសញ្ញានេះ ។

**មាត្រា ៤៤**

១) រដ្ឋដទៃទៀត អាចចូលរួមអនុវត្តអនុសញ្ញានេះ បន្ទាប់ពីអនុសញ្ញានេះបានចូលជាធរមានស្របតាមមាត្រា ៤៦ កថាខ័ណ្ឌ ១ ។

២) លិខិតូបករណ៍នៃការចូលរួមអនុវត្តត្រូវតំកល់ទុកនៅមន្ទីរតំកល់អនុសញ្ញានេះ ។

៣) ការចូលរួមអនុវត្តអានុសញ្ញា មានអនុភាពចំពោះតែទំនាក់ទំនងរវាងរដ្ឋចូលរួមអនុវត្ត និង រដ្ឋជាភាគីទាំងឡាយដែលមិនបានជំទាស់នឹងការចូលរួមនៃរដ្ឋនោះក្នុងរយៈពេល៦ខែ បន្ទាប់ពីទទួលសេចក្តីជូនដំណឹងដូចមានចែងនៅក្នុងអនុកថាខ័ណ្ឌខ នៃមាត្រា៤៨ ។ ការជំទាស់នោះក៏អាចធ្វើឡើងដោយរដ្ឋនានានៅពេលដែលរដ្ឋទាំងនោះផ្តល់សច្ចាប័នទទួលយក ឬយល់ព្រមអនុវត្តអនុសញ្ញាបន្ទាប់ពីការចូលរួមនៃរដ្ឋដទៃទៀតនោះ ។ ការជំទាស់បែបនេះត្រូវជូនដំណឹងដល់មន្ទីរតំកល់អនុសញ្ញា ។

**មាត្រា ៤៥**

១) បើរដ្ឋមួយមានដែនដីពីរ ឬច្រើនជាងនេះ ហើយដែនដីទាំងនោះមានប្រព័ន្ធច្បាប់ខុសៗគ្នា ដែលអនុវត្តចំពោះរឿងទាក់ទងនឹងអនុសញ្ញានេះ រដ្ឋនោះអាចប្រកាសនៅពេលទទួលយក យល់ព្រម ឬចូលរួមអនុវត្តអនុសញ្ញាថា អនុសញ្ញានេះត្រូវលាតសន្ធឹងដល់ដែនដីទាំងអស់នៃរដ្ឋនោះ ឬត្រឹមតែដែនដីមួយ ឬច្រើនក្នុងចំណោមដែនដីទាំងអស់នោះ ហើយអាចកែប្រែប្រកាសនេះដោយដាក់ជូនការប្រកាសមួយទៀតនៅពេលណាក៏បាន ។

២) ការប្រកាសបែបនោះត្រូវជូនដំណឹងទៅមន្ទីរតំកល់អនុសញ្ញា ហើយត្រូវបញ្ជាក់ឱ្យបានជាក់ច្បាស់ថា ដែនដីណាដែលអនុសញ្ញានេះអនុវត្ត ។

៣) បើរដ្ឋមួយមិនបានធ្វើការប្រកាសតាមមាត្រានេះទេនោះ អនុសញ្ញានេះនឹងត្រូវលាតសន្ធឹងដល់ដែនដីទាំងអស់នៃរដ្ឋនោះ ។

**មាត្រា ៤៦**

១) អនុសញ្ញានេះត្រូវចូលជាធរមាននៅថ្ងៃទីមួយនៃខែបន្ទាប់ពីការផុតកំណត់រយៈពេលបីខែ បន្ទាប់ពីថ្ងៃតំកល់លិខិតូបករណ៍ទីបីនៃសច្ចាប័ន ការទទួលយក ឬការយល់ព្រម ដែលបានចែងនៅក្នុងមាត្រា ៤៣ ។

២) បន្ទាប់ពីនោះមក អនុសញ្ញានេះត្រូវចូលជាធរមាន ៖-

(ក) ចំពោះរដ្ឋនីមួយៗដែលផ្តល់សច្ចាប័ន ទទួលយក ឬ យល់ព្រមអនុវត្ត អនុសញ្ញានេះនៅពេលក្រោយ មក ឬចំពោះរដ្ឋនីមួយៗដែលចូលរួមអនុវត្តអនុសញ្ញានេះ នៅថ្ងៃទីមួយ នៃខែបន្ទាប់ពីការផុតកំណត់រយៈពេលបីខែ បន្ទាប់ពីថ្ងៃតំកល់លិខិតូបករណ៍សច្ចាប័ន ទទួលយក យល់ព្រម ឬចូលរួមរបស់រដ្ឋនោះ។

(ខ) ចំពោះដែនដីមួយដែលអនុសញ្ញានេះបានលាតសន្ធឹងទៅដល់ ស្របតាមមាត្រា៤៥ នៅថ្ងៃទីមួយ នៃខែបន្ទាប់ពីការផុតកំណត់រយៈពេលបីខែ បន្ទាប់ពីការជូនដំណឹងដូចបានពោលក្នុងមាត្រានោះ។

**មាត្រា ៤៧**

១) រដ្ឋជាភាគីនៃអនុសញ្ញានេះ អាចសុំឈប់អនុវត្តអនុសញ្ញានេះវិញបានដោយធ្វើលិខិតជូនដំណឹងទៅមន្ទីរតំកល់អនុសញ្ញា ។

២) ការសុំឈប់អនុវត្តអនុសញ្ញាចូលជាធរមាននៅថ្ងៃទី មួយ នៃខែបន្ទាប់ពីផុតរយៈពេល ដប់ពីរ ខែបន្ទាប់ពីថ្ងៃដែលមន្ទីរតំកល់អនុសញ្ញាបានទទួលលិខិតជូនដំណឹង។ ក្នុងករណីដែលលិខិតជូនដំណឹងបញ្ជាក់ថា ការសុំឈប់អនុវត្តអនុសញ្ញា

នេះចូលជាធរមាននៅក្នុងរយៈពេលយូរជាងនេះ ការសុំឈប់អនុវត្តនោះចូលជាធរមាននៅថ្ងៃដែលផុតរយៈពេលយូរជាងនោះ បន្ទាប់ពីមន្ទីរតំកល់អនុសញ្ញាបានទទួលលិខិតជូនដំណឹង ។

**មាត្រា ៤៨**

មន្ទីរតំកល់អនុសញ្ញាត្រូវជូនដំណឹងដល់រដ្ឋជាសមាជិកនៃសន្និសីទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិឯកជន រដ្ឋដទៃទៀតដែលចូលរួមនៅក្នុងសម័យប្រជុំលើកទីដប់ប្រាំពីរ និងរដ្ឋដែលបានចូលរួមអនុវត្តស្របតាមមាត្រា ៤៤ នូវពតិមាន ដូចតទៅនេះ :

(ក) ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន ការទទួលយកនិងការយល់ព្រមដូចបានចែងក្នុងមាត្រា ៤៣

(ខ) ការចូលរួម និងការជំទាស់ចំពោះការចូលរួមដូចបានចែងក្នុងមាត្រា ៤៤

(គ) កាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមានស្របតាមមាត្រា ៤៦

(ឃ) ការប្រកាសនឹងការចាត់តាំងដូចបានចែងក្នុងមាត្រា ២២, ២៣, ២៥ និង ៤៥

(ង) កិច្ចព្រមព្រៀងដូចបានចែងក្នុងមាត្រា ៣៩

(ច) ការសុំឈប់អនុវត្តដូចបានចែងក្នុងមាត្រា ៤៧ ។

ដើម្បីជាសក្ខីភាព អ្នកមានឈ្មោះដូចខាងក្រោម ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ បានចុះហត្ថលេខាលើអនុសញ្ញានេះ ។

ធ្វើនៅទីក្រុងឡាអេ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ១៩៩៣ ជាភាសាអង់គ្លេស និងបារាំង ។ អត្ថបទទាំងពីរភាសានេះមានតម្លៃស្មើគ្នា ហើយមានតែមួយច្បាប់ដែលត្រូវបានតំកល់ទុកនៅបណ្ណសារនៃរដ្ឋាភិបាលនៃព្រះរាជាណាចក្រហុល្លង់ ។ អត្ថបទចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ ត្រូវបញ្ជូនតាមរយៈផ្លូវទូតដល់រដ្ឋដែលជាសមាជិកនៃសន្និសីទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិឯកជន នាសម័យប្រជុំលើកទីដប់ប្រាំពីរ និងដល់រដ្ឋដទៃទៀតដែលបានចូលរួមនៅក្នុងសម័យប្រជុំនោះ ។

x

*G:\Sokea\Law\ HagueConv Adoption.Kh.doc*